សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# បណ្តឹងទាស់នៅក្នុងរឿងរដ្ឋប្បវេណី

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ
សមណនិស្សិត **គឹម ពេជ្រ**

ណែនាំដោយ
លោក **ហេង មូរ៉ា**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ
ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩
ឆ្នាំសរសេរសារណា ២០២៣

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# បណ្តឹងទាស់នៅក្នុងរឿងរដ្ឋប្បវេណី

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ

សមណនិស្សិត **គីម ពេជ្រ**

ណែនាំដោយ

លោក **ហេង មូរ៉ា**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **គឹម ពេជ្រ** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី ២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៩-២០២៣។

**សូមសម្តែងនូវកតញ្ញូតាធម៌ និងសេចក្តីដឹងគុណជូនចំពោះ**

**លោកឪពុក អ្នកម្តាយ** ជាទីគោរពរបស់កូន ដែលលោកទាំងទ្វេបានផ្តល់កំណើតនិងចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅកូនប្រកបដោយព្រហ្មវិហារធម៌ និងទំនុកបម្រុងគ្រប់សព្វបែបយ៉ាង ទាំងផ្នែកសម្ភារៈនិងថវិកា ព្រមទាំងហ៊ានលះបង់ទាំងកម្លាំងកាយចិត្ត តស៊ូមិនខ្លាចការនឿយហត់ដើម្បីឱ្យកូនបានសិក្សារៀនសូត្រក្រេបជញ្ជក់យកចំណេះដឹងតាំងពីថ្នាក់បឋមសិក្សា រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រ។ គោលបំណងចង់ឱ្យកូនក្លាយជាបញ្ញវន្តមួយរូប ដែលជាកម្លាំងចលករក្នុងការជួយលើកស្ទួយសង្គមជាតិ។ ក្នុងនាមរូបខ្ញុំបាទជាកូនគ្មានអ្វីដែលនឹងតបស្នងសងគុណដើម្បីឱ្យសមនឹងការលះបង់របស់លោកឪពុក អ្នកម្តាយ បានទេ គឺមានតែការខិតខំប្រឹងប្រែងរៀនសូត្រឱ្យអស់ពីកម្លាំងកាយចិត្ត ដើម្បីកុំឱ្យកម្លាំងញើសឈាមរបស់លោកទាំងពីរបានចំណាយរសាត់បាត់បង់ដោយឥតន័យ។

**ឯកឧត្តមបណ្ឌិតលុយ ចណ្ណា សាកលវិទ្យាធិការ និងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំងលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ** នៃសាលកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអស់ពីសមត្ថភាពក្នុងការផ្ទេរនូវរាល់ចំណេះដឹងដល់រូបខ្ញុំបាទ ជាពិសេសជាការតម្រង់ទិស ដើម្បីធ្វើឱ្យរូបខ្ញុំក្លាយជាសិស្សល្អ កូនល្អ និងជាមនុស្សល្អ ប្រកបដោយគុណធម៌ សុជីវធម៌ សីលធម៌ ដើម្បីក្លាយជាធនធានមួយនៅក្នុងការចូលរួមអភិវឌ្ឍន៍សង្គមជាតិឱ្យមានភាពរីកចម្រើន។

លោកគ្រូ **ហេង មូរ៉ា** ដែលបានខិតខំយកចិត្តទុកដាក់ និងលះបង់ពេលវេលាដ៏មានតម្លៃ ដើម្បីជួយបណ្តុះបណ្តាលនិងពន្យល់ណែនាំផ្តល់ជាប្រទីបដើម្បីបំភ្លឺគំនិតដល់រូបខ្ញុំ ព្រមទាំងជួយកែសម្រួលនូវរាល់ចំណុចខ្វះខាតលើកិច្ចការសរសេរសារណាមួយនេះ តាំងពីពេលចាប់ផ្តើម រហូតដល់ខ្ញុំបានចងក្រងនូវសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រមួយនេះឡើងបានរួចរាល់ជាស្ថាពរ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធិពរជ័យជូនដល់**លោកអ្នកមានគុណទាំងពីរ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ និងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ** ទាំងអស់ នៃសាលកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំងលោកគ្រូ **ហេង មូរ៉ា** សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

ក្រោយពីបានឆ្លងកាត់ការបណ្តុះបណ្តាលថ្នាក់បរិបញ្ញាបត្រ ផ្នែកនីតិសាស្ត្រ អស់រយៈពេល០៤ឆ្នាំ នៅ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** នូវមុខវិជ្ជាជាច្រើន ដែលទាក់ទងនឹងវិស័យច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ហើយជាពិសេស ទាក់ទងនឹង**ក្រមរដ្ឋប្បវេណី** និង**ក្រមនីតិវិធីរដ្ឋប្បវេណី** ដែលធ្វើឱ្យរូបខ្ញុំបានទទួលចំណេះដឹងយ៉ាងទូលំទូលាយ ក្រោមការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់ពីសំណាក់លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ ដែលបង្ហាត់បង្រៀននៅទីនោះ។ ដោយមានការជ្រោមជ្រែង និងបានខិតខំអស់ពីសមត្ថភាពក្នុងការផ្ទេរនូវចំណេះដឹងដល់រូបខ្ញុំបាទពីសំណាក់លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យនេះហើយ ទើបរូបខ្ញុំបាទមានឱកាសបានសរសេរចងក្រងនូវសារណានេះឡើង ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី ២៣ និងបានចូលរួមចំណែកក្នុងការចែករំលែកនូវចំណេះដឹងតាមរយៈសមិទ្ធិផលនៃកិច្ចការស្រាវជ្រាវសារណានេះដល់សិស្ស និស្សិតជំនាន់ក្រោយៗផងដែរ។

ការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ ខ្ញុំបាទបានសម្រេចចិត្តជ្រើសរើសយកប្រធានបទស្តីពី **បណ្តឹងទាស់នៅក្នុងរឿងរដ្ឋប្បវេណី** ដែលជាប្រធានបទមួយមានទំនាក់ទំនងក្នុងការអនុវត្តនីតិវិធីយ៉ាងច្រើនលើសលប់ទៅតាមបទប្បញ្ញត្តិក្នុងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ នៃព្រះរាជាណាចក្រកម្ពុជា។ ការជ្រើសរើសប្រធានបទនេះ ក្នុងគោលបំណងដើម្បីពង្រឹងនូវការយល់ដឹងក្នុងវិស័យច្បាប់ដែលទាក់ទងនឹងរឿងក្តីរដ្ឋប្បវេណីឱ្យកាន់តែមានភាពច្បាស់លាស់ទៅលើចំណាត់ការនីតិវិធីរបស់តុលាការ និង ព្រមទាំងស្វែងយល់អំពីសិទ្ធិ កាតព្វកិច្ច និងជម្រើសរបស់ភាគីនៃបណ្តឹង ជាពិសេសលើបណ្តឹងទាស់ក្នុងរឿងក្តីរដ្ឋប្បវេណីនេះតែម្តង។ ហើយលទ្ធផលនៃសារណានេះ ខ្ញុំបាទសង្ឃឹមថានឹងបានក្លាយជាឯកសារដ៏សំខាន់មួយ សម្រាប់ទុកជាជំនួយស្មារតីដល់សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវក្នុងវិស័យច្បាប់ ឱ្យមានការយល់ដឹងបន្ថែមទៀត ទៅលើការអនុវត្តគោលការណ៍ និងការប្រព្រឹត្តិទៅនៃនីតិវិធីរបស់តុលាការចំពោះបណ្តឹងទាស់។ នៅក្នុងការរៀបរៀងចងក្រងនូវអត្ថបទនេះឡើងផងដែរ ពិតណាស់ថានឹងមានជាចំណុចខ្វះខាតនូវរាល់ពាក្យពេចន៍ក៏ដូចជាខ្លឹមសារ អត្ថន័យផ្សេងៗទៀតដែលអាចកើតមានឡើង ក៏ប៉ុន្តែខ្ញុំជឿជាក់ថាអត្ថបទស្រាវជ្រាវមួយនេះនឹងបានផ្តល់ជាប្រយោជន៍សម្រាប់មិត្តអ្នកអាន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវទាំងអស់ ដើម្បីជាចំណេះដឹងបន្ថែមទៀត។

ជាទីបញ្ចប់ ខ្ញុំបាទមានសេចក្តីសោមនស្សរីករាយនឹងសូមស្វាគមន៍ នូវរាល់មតិរិះគន់នៅក្នុងន័យស្ថាបនាពីសំណាក់លោកសាស្ត្រាចារ្យ មិត្តអ្នកអាន អ្នកសិក្សាស្រាវជ្រាវនៅគ្រប់មជ្ឈដ្ឋានទាំងអស់ ដោយក្តីគោរពសោមនស្សរីករាយបំផុត ពោលគឺដើម្បីឱ្យកម្រងឯកសារនៃកិច្ចការស្រាវជ្រាវមួយនេះកាន់តែមានអត្ថន័យ និង ខ្លឹមសារកាន់តែល្អ រឹតតែច្បាស់លាស់ និងមានភាពសុីជម្រៅថែមទៀត។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម**.......................................................................................................១
**១.លំនាំបញ្ហានៃការស្រាវជ្រាវ** ...............................................................................១
**២.ចំណោទបញ្ហានៃការដោះស្រាយ** ..........................................................................២
**៣.គោលបំណងនៃការស្រាវជ្រាវ** ..............................................................................២
**៤.ទំហំ និង ដែនកំណត់នៃការស្រាវជ្រាវ**......................................................................២
**៥.សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ** ....................................................................... ៣
**៦.វិធីសាស្រ្តនៃការសិក្សាស្រាវជ្រាវ** .......................................................................... ៣
**៧.រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ** ....................................................................... ៣

## ជំពូកទី១
## សញ្ញាណទូទៅនៃបណ្តឹងទាស់

**១.១.និយមន័យបណ្តឹងទាស់** ......................................................................................៤
**១.២.លក្ខខណ្ឌដែលអាចធ្វើបណ្តឹងទាស់** ......................................................................៥
១.២.១.សាលក្រមដែលអាចធ្វើបណ្តឹងទាស់ ..........................................................................៥
១.២.១.១.សាលក្រមកំបាំងមុខដើមចោទ...........................................................................៥
១.២.១.២.សាលក្រមកំបាំងមុខចុងចម្លើយ .........................................................................៦
១.២.២.អំឡុងពេលដែលអាចធ្វើបណ្តឹងទាស់បាន..................................................................៧
**១.៣.សិទ្ធិក្នុងការធ្វើបណ្តឹងទាស់** ...................................................................................៨
១.៣.១.សមត្ថភាពភាគីក្នុងការធ្វើបណ្តឹង ...........................................................................៨
១.៣.១.១. អនីតិជន និង ជននៅក្រោមអាណាព្យាបាលទូទៅ .....................................................៩
១.៣.១.២.ជននៅក្រោមហិតូបត្ថម្ភ ................................................................................ ១០
១.៣.១.៣.ជនបរទេស ..................................................................................................... ១១
១.៣.១.៤.អ្នកតំណាងដោយអាណត្តិ ................................................................................ ១១
១.៣.២. អានុភាពតាមផ្លូវច្បាប់នៃសមត្ថភាពក្នុងការធ្វើបណ្តឹងទាស់ ............................................ ១២
១.៣.២.១.ករណីខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹងទាស់ ........................................................... ១២
១.៣.២.២.ឥទ្ធិពលទៅលើបណ្តឹងនៃការខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹងទាស់............................. ១៣

១.៣.៣. ការលះបង់សិទ្ធិក្នុងការធ្វើបណ្តឹងទាស់ ..................... ១៣
**១.៤. របៀបធ្វើបណ្តឹងទាស់ និង អានុភាពនៃបណ្តឹងទាស់** ..................... ១៣
១.៤.១.របៀបធ្វើបណ្តឹងទាស់ ..................... ១៣
១.៤.២. អានុភាពនៃបណ្តឹងទាស់..................... ១៤

## ជំពូកទី២
## ចំណាត់ការលើនីតិវិធីបណ្តឹងទាស់

**២.១.ដំណាក់កាលនៃការដាក់ពាក្យបណ្តឹង** ..................... ១៦
២.១.១.សមត្ថកិច្ចរបស់តុលាការ ..................... ១៦
២.១.១.១.សមត្ថកិច្ចក្នុងការទទួលពាក្យបណ្តឹង ..................... ១៦
២.១.១.២. សមត្ថកិច្ចក្នុងការពិនិត្យពាក្យបណ្តឹង ..................... ១៦
២.១.២.អានុភាពនៃបណ្តឹងទាស់ដែលត្រូវបានទទួលស្គាល់ ..................... ១៧
**២.២.ការដកពាក្យបណ្តឹង និង ការកំណត់កាលបរិច្ឆេទថ្មីលើបណ្តឹងទាស់** ..................... ១៨
២.២.១.ការដកពាក្យបណ្តឹងទាស់ ..................... ១៨
២.២.១.១.ការដកពាក្យបណ្តឹងជាលាយល័ក្ខណ៍អក្សរ..................... ១៨
២.២.១.២.ការដកពាក្យបណ្តឹងដោយផ្ទាល់មាត់..................... ១៩
២.២.២. ការកំណត់កាលបរិច្ឆេទថ្មីក្នុងការវិនិច្ឆ័យលើបណ្តឹងទាស់..................... ១៩
២.២.៣.ការកោះហៅគូភាគី ..................... ២០
២.២.៣.១.ការបញ្ជូនដោយការប្រគល់..................... ២០
២.២.៣.២.ការបញ្ជូនដោយការជួបប្រទះ ..................... ២១
២.២.៣.៣.ការបញ្ជូនដោយបង្គ្រប់កិច្ច..................... ២១
២.២.៣.៤.ការបញ្ជូនដោយទុកចោល..................... ២២
២.២.៣.៥.ការបញ្ជូនដែលត្រូវធ្វើនៅបរទេស ..................... ២២
២.២.៣.៦.ការបញ្ជូនតាមការផ្សាយជាសារណៈ ..................... ២៣
**២.៣. ការសម្រេចសេចក្តីលើបណ្តឹងទាស់** ..................... ២៤
២.៣.១.ការវិនិច្ឆ័យ និង ការសម្រេចសេចក្តីលើបណ្តឹងទាស់..................... ២៤
២.៣.២. សាលក្រមថ្មីដែលសម្រេចលើបណ្តឹងទាស់..................... ២៥
**២.៤. សាលក្រមកំចាំងមុខលើកទី២**..................... ២៦

២.៤.១.មូលហេតុដែលមិនអាចនាំឱ្យចេញនូវសាលក្រមកំបាំងមុខលើកទី២ ........ ២៦
២.៤.១.១.ភាគីដែលមិនបានបង្ហាញខ្លួន ដោយមិនបានទទួលការកោះហៅស្របច្បាប់........ ២៧
២.៤.១.២.ភាគីដែលមិនបានបង្ហាញខ្លួន ដោយមានមូលហេតុដែលមិនអាចជៀសវាងបាន ........ ២៨
២.៤.១.៣.បណ្ដឹងមិនស្របច្បាប់ ........ ២៨
២.៤.១.៤.ការមិនបានជូនដំណឹងអំពីខ្លឹមសារនៃសេចក្ដីថ្លែងការណ៍របស់ដើមចោទទៅចុងចម្លើយ........ ២៩
២.៤.២.ការហាមឃាត់ក្នុងការធ្វើបណ្ដឹងទាស់ ចំពោះសាលក្រមកំបាំងមុខលើកទី២........ ៣០

## ជំពូកទី៣

## បញ្ហាប្រឈម និង ដំណោះស្រាយ

**៣.១.បញ្ហាប្រឈម** ........ ៣៣
៣.១.១.ភាពខ្វះចន្លោះនៃច្បាប់ ........ ៣៣
៣.១.២.ការយល់ដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋនៅមានកម្រិត........ ៣៤
៣.១.៣.ការកោះហៅមិនស្របច្បាប់ ........ ៣៥
៣.១.៤.អវត្តមានរបស់គូភាគី........ ៣៦
៣.១.៥.ការយឺតយ៉ាវក្នុងការជម្រះក្ដីលើបណ្ដឹងទាស់........ ៣៧
៣.១.៦.ការផុតរយៈពេលនៃការដាក់ពាក្យបណ្ដឹងទាស់........ ៣៨
**៣.២.ដំណោះស្រាយ** ........ ៣៩
៣.២.១.ការបង្កើតលិខិតបទដ្ឋានគតិយុត្តិឱ្យបានច្រើន ........ ៣៩
៣.២.២.ការបង្កើតប្រព័ន្ធផ្សព្វផ្សាយច្បាប់ឱ្យបានទូលំទូលាយ........ ៤០
៣.២.៣.ការកោះហៅភាគីឱ្យស្របតាមនីតិវិធីច្បាប់........ ៤០
៣.២.៤.ការជម្រុញឱ្យភាគីចូលរួមនីតិវិធីជម្រះក្ដីលើបណ្ដឹងទាស់ ........ ៤២
៣.២.៥.ការពន្លឿននីតិវិធីជម្រះក្ដីលើបណ្ដឹងទាស់ ........ ៤៤
៣.២.៦. ការពន្លឿននូវការដាក់ពាក្យបណ្ដឹងទាស់........ ៤៥
**សេចក្ដីសន្និដ្ឋាន** ........ ៤៦
**អនុសាសន៍**........ ៤៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

កម្ពុជា ជាប្រទេសដែលមានរបបដឹកនាំអាស្រ័យរដ្ឋធម្មនុញ្ញ ដែលមានការបែងចែកស្ថាប័នអំណាចដាច់ពីគ្នា រវាង**អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ** និង **អំណាចតុលាការ**។ ដោយស្ថាប័នអំណាចនីមួយៗមានតួនាទី និង ភារកិច្ចផ្សេងៗគ្នា ដើម្បីធានាមិនឱ្យមានការរំលោភអំណាចគ្នាទៅវិញទៅមក។

ក្នុងចំណោមស្ថាប័នអំណាចទាំងបីខាងលើនេះ **ស្ថាប័នតុលាការ** មានតួនាទីក្នុងការតាមដានការអនុវត្តច្បាប់ និងការដាក់ទណ្ឌកម្មចំពោះជនទាំងឡាយណាដែលល្មើសនឹងច្បាប់តាមរយៈការសម្រេចសេចក្ដីដោយសំអាងទៅលើបទប្បញ្ញត្តិច្បាប់ដែលមានជាធរមាន។ ប៉ុន្តែទន្ទឹមនឹងការអនុវត្តច្បាប់ និង ការដាក់ទណ្ឌកម្មចំពោះជនដែលបានល្មើសនឹងច្បាប់ ក៏ត្រូវតែមានការធានា ការគោរព និង ការការពារដល់សិទ្ធិសេរីភាពចំពោះជនគ្រប់រូបឱ្យស្របទៅតាមរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់រដ្ឋផងដែរ[១]។ ដោយមុននឹងសន្និដ្ឋានថាជននោះត្រូវទទួលទណ្ឌកម្ម លុះត្រាតែជននោះត្រូវបានតុលាការចេញសាលក្រម ឬ សាលដីកា បញ្ជាក់អំពីកំហុសដែលជននោះបានប្រព្រឹត្ត ឬ កំហុសដោយសារជននោះមិនបានអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនទៅលើករណីណាមួយ។ ប៉ុន្តែមុននឹងឈានដល់ការចេញសេចក្ដីសម្រេច តុលាការត្រូវគោរពនូវគោលការណ៍ចំពោះមុខដែលមានបញ្ញត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ដូច្នេះ តម្រូវឱ្យមានវត្តមានគូភាគីនៃរឿងក្ដីនៅគ្រប់ដំណាក់កាលនៃនីតិវិធី។ ប៉ុន្តែ ប្រសិនបើភាគីណាមួយបានទទួលការកោះហៅដោយស្របច្បាប់ហើយ តែបែរជាអវត្តមានដោយមិនមានមូលហេតុច្បាស់លាស់ តុលាការអាចចេញនូវសាលក្រមកំបាំងមុខភាគីនោះបាន។

ទន្ទឹមនឹងច្បាប់បើកសិទ្ធិឱ្យតុលាការអាចចេញសាលក្រមកំបាំងមុខ ច្បាប់ក៏បានទុកសិទ្ធិឱ្យភាគីដែលត្រូវបានតុលាការចេញនូវសាលក្រមកំបាំងមុខនោះ មានសិទ្ធិក្នុងការធ្វើបណ្ដឹងទាស់ចំពោះសាលក្រមកំបាំងមុខនោះបានផងដែរ។ ថ្វីត្បិតតែសាលក្រមកំបាំងមុខ ធ្វើឡើងចំពោះភាគីដែលអវត្តមាននៅកាលបរិច្ឆេទ ដែលតុលាការបានកំណត់នៅក្នុងកិច្ចនីតិវិធីណាមួយ ក៏ពិតមែន ប៉ុន្តែការចេញសេចក្ដីសម្រេចដោយមិនបានធ្វើការសាកសួរភាគីណាមួយនៃរឿងក្ដី វាក៏ជាហេតុដែលធ្វើឱ្យប៉ះពាល់ ឬ ខូចប្រយោជន៍របស់ភាគីនោះ ហេតុនេះហើយ ទើបច្បាប់ទុកសិទ្ធិឱ្យភាគី ដែលត្រូវបានតុលាការចេញសាលក្រមកំបាំងមុខនោះ អាចប្ដឹងទាស់នឹងសេចក្ដីសម្រេចនោះបានទៅតាមការកំណត់របស់ច្បាប់។ ដោយបានឃើញនូវលក្ខណៈពិសេសនៃសិទ្ធិរបស់ភាគី ដែលត្រូវបានតុលាការចេញសាលក្រមកំបាំងនោះ អាចធ្វើបណ្ដឹងប្រឆាំងនឹងសាលក្រមកំបាំងមុខខ្លួនដើម្បីប្ដឹងទាមទារឱ្យមានការលុបចោល ឬផ្លាស់ប្ដូរសាលក្រមកំបាំងមុខនោះ ទើបខ្ញុំបាទ បានសម្រេចជ្រើសរើស

[១]រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា

យកនូវបណ្តឹងទាស់នៅក្នុងរឿងរដ្ឋប្បវេណីនេះមកធ្វើជាប្រធានបទសារណា ដើម្បីបកស្រាយបង្ហាញក្នុងគោលបំណងលាតត្រដាងឱ្យឃើញពីសារៈសំខាន់នៃបណ្តឹងទាស់នៅក្នុងរឿងរដ្ឋប្បវេណី ដែលអាចធ្វើឡើងប្រឆាំងនឹងសាលក្រមកំបាំងមុខ។

## ២.ចំណោទបញ្ហានៃការដោះស្រាយ

ដើម្បីងាយស្រួលក្នុងការប្រមូលផ្តុំគោលគំនិតសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ និងឆ្លើយតបឱ្យមានភាពកាន់តែច្បាស់លាស់ទៅលើប្រធានបទខាងលើ ខ្ញុំបាទបានលើកឡើងនូវចំណោទបញ្ហាគតិយុត្តមួយចំនួនមកធ្វើការដោះស្រាយរួមមាន៖

១. តើភាគីដែលត្រូវតុលាការចេញនូវសាលក្រមកំបាំងមុខមានសិទ្ធិអ្វីខ្លះ ប្រសិនបើខ្លួនពុំយល់ស្រប ចំពោះសាលក្រមកំបាំងមុខនោះ?

២. តើតុលាការមានចំណាត់ការបែបណាខ្លះ ចំពោះបណ្តឹងទាស់ដែលបានធ្វើឡើងដោយភាគីអវត្តមាន?

៣. តើមានមូលហេតុអ្វីខ្លះនាំឱ្យកើតមានបណ្តឹងទាស់ ហើយត្រូវចាត់វិធានការដោះស្រាយ យ៉ាងដូចម្តេច ចំពោះបញ្ហាប្រឈមទាំងនោះ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

វត្ថុបំណងនៃការសម្រេចចិត្តជ្រើសរើសយកប្រធានបទស្តីពី " បណ្តឹងទាស់នៅក្នុងរឿងរដ្ឋប្បវេណី " យកមកសរសេរជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ គឺដើម្បីសិក្សាស្វែងយល់ឱ្យកាន់តែច្បាស់អំពីសិទ្ធិ កាតព្វកិច្ច និងជម្រើសរបស់ភាគី ដែលត្រូវបានតុលាការចេញសាលក្រមកំបាំងមុខ និងចំណាត់ការរបស់តុលាការទៅលើបណ្តឹងទាស់ដែលបានធ្វើឡើងដោយភាគីអវត្តមាននោះ។ ព្រមទាំងរកនូវមូលហេតុមិនប្រក្រតីមួយចំនួន ដែលបណ្តាលធ្វើឱ្យភាគីណាមួយមិនអាចចូលរួមបង្ហាញខ្លួននៅក្នុងដំណើរការនីតិវិធីរបស់តុលាការផងដែរ ដែលជាដើមចមនៃការកើតមាននូវបណ្តឹងទាស់នៅក្នុងរឿងរដ្ឋប្បវេណី ពីព្រោះតែការសម្រេចសេចក្តីកំបាំងមុខរបស់តុលាការ។

## ៤.ទំហំ និង ដែនកំណត់នៃការស្រាវជ្រាវ

វិសាលភាពនៃការសិក្សាស្រាវជ្រាវប្រធានបទនេះ ខ្ញុំបានធ្វើការកំណត់ទៅលើការសិក្សាស្រាវជ្រាវចាប់ពីដំណាក់កាលនៃការដាក់ពាក្យបណ្តឹងទាស់ រហូតដល់ការវិនិច្ឆ័យនិងសម្រេចសេចក្តីលើបណ្តឹងទាស់។ ហើយការស្រាវជ្រាវបានផ្អែកទៅលើឯកសារគោលគឺ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ និង រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា និងឯកសាររួមផ្សំដែលពាក់ព័ន្ធផ្សេងទៀត ដូចដែលបានលើកឡើងនៅក្នុងឯកសារយោងស្រាប់។ ជាងនេះទៅទៀត សាលក្រមកំបាំងមុខ និងពាក្យបណ្តឹងទាស់ដែលត្រូវលើកយកមកសិក្សាធ្វើជាអំណះអំណាងក្នុងសារណានេះ ដើម្បីឱ្យមានទឡ្ហីករណ៍កាន់តែច្បាស់លាស់ គឺខ្ញុំ

បានជ្រើសរើសយកចាប់ពីឆ្នាំ២០១៨ ដល់ ឆ្នាំ២០២៣ តែប៉ុណ្ណោះ ដើម្បីសិក្សាធ្វើជាសំអាងហេតុ។

## ៥.សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

លទ្ធផលដែលកើតចេញពីកិច្ចការសិក្សាស្រាវជ្រាវនេះនឹងបានរួមចំណែកជាប្រយោជន៍ បានជាពុទ្ធិដល់មិត្តអ្នកសិក្សាស្រាវជ្រាវ និងសាធារណៈជន ជាពិសេសជាទុនមួយដ៏សំខាន់សម្រាប់ជាឯកសារជំនួយស្មារតីដល់បងប្អូនសិស្ស និស្សិតដែលកំពុងសិក្សានៅក្នុងវិស័យច្បាប់ ឱ្យយល់ដឹងកាន់តែច្បាស់បន្ថែមទៀតទៅលើបណ្ដឹងទាស់នៅក្នុងរឿងរដ្ឋប្បវេណីនេះ។

## ៦.វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ដើម្បីសម្រេចបាននូវស្នាដៃចំពោះមុខនេះ ជៀសមិនផុតពីការសិក្សាស្រាវជ្រាវលើឯកសារ និងប្រភពព័ត៌មានផ្សេងៗទៀតដែលបង្កប់នូវខ្លឹមសារពាក់ព័ន្ធនានា ដើម្បីជាបង្អែកសម្រាប់ការបកស្រាយនូវចំណោទបញ្ហាគតិយុត្តខាងលើ។ ទិន្នន័យដែលប្រមូលបាន គឺយកមកវិភាគតាមរយៈពិពណ៌នាបែបគុណភាព ដោយប្រើទិន្នន័យទីមួយ ជាទិន្នន័យចម្បង ( Primary Data) និងទិន្នន័យពីរ ជាទិន្នន័យបន្ទាប់បន្សំ ( Secondary Data) បូករួមបញ្ចូលគ្នា ដើម្បីសម្រេចបាននូវសមិទ្ធផលនេះឡើង ដែលការបូករួមបញ្ចូលគ្នានោះមានដូចខាងក្រោមនេះ៖

- ទិន្នន័យទីមួយ (Primary Data) ជាប្រភេទទិន្នន័យផ្ទាល់ ដោយបានសាកសួរសំណួរមួយចំនួនទៅកាន់មន្ត្រីអនុវត្តច្បាប់ដែលបានធ្វើការនៅសាលាដំបូងរាជធានីភ្នំពេញ គឺលោកស្រីចៅក្រម **យី សុខវួច** និងកញ្ញា **អៀង គឹមណម** ជាក្រឡាបញ្ជី ព្រមទាំងលោកមេធាវី **អ៊ុរ ប៉ូលី និងលោកគ្រូណែនាំ ហេង បូរ៉ា។**

- ទិន្នន័យទីពីរ (Secondary Data) ជាប្រភេទទិន្នន័យមិនផ្ទាល់ ដែលបានមកពីការដកស្រង់នូវខ្លឹមសារសំខាន់ៗ និងពាក់ព័ន្ធចាំបាច់មួយចំនួនទៀត ដែលប្រមូលបានពីលិខិតបទដ្ឋានគតិយុត្តជាតិដែលមានជាធរមានដូចជា សៀវភៅមេរៀនទាក់ទងនឹងវិស័យច្បាប់ របាយការណ៍ នៅតាមបណ្ណាល័យនានា នៅក្នុងរាជធានីភ្នំពេញ ព្រមទាំងសេចក្តីកំណត់មាត្រានីមួយៗ និងសេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ដែលបានបោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ជាដើម ដែលខ្ញុំបានដាក់នៅក្នុងឧបសម្ព័ន្ធ និងឯកសារយោងស្រាប់។

## ៧.រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ដើម្បីបកស្រាយប្រធានបទបណ្ដឹងទាស់ក្នុងរឿងរដ្ឋប្បវេណីឱ្យបានគ្រប់ជ្រុងជ្រោយ និង សិក្សាឱ្យកាន់តែមានភាពស៊ីជម្រៅ ហើយច្បាស់លាស់ទៀតនោះ ព្រមទាំងឆ្លើយតបនឹងចំណោទបញ្ហាគតិយុត្តខាងលើ ខ្ញុំបាទបានធ្វើការបែងចែកអត្ថបទសារណានេះជា០៣ (បី) ជំពូកធំៗ ដែលសិក្សាលម្អិតទៅលើ៖

- **សេចក្តីផ្តើម** ៖ ផ្នែកនេះចង់បង្ហាញឱ្យឃើញអំពី លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ ចំណោទបញ្ហានៃការដោះស្រាយ គោលបំណងនៃការស្រាវជ្រាវ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការសិក្សា

ស្រាវជ្រាវ និងវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ព្រមទាំងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ ។

- **ជំពូកទី១**: **សញ្ញាណទូទៅនៃបណ្តឹងទាស់**៖ នៅក្នុងជំពូកនេះ នឹងបង្ហាញលោកអ្នកឱ្យបានយល់ដឹងអំពីនិយមន័យបណ្តឹងទាស់ (១.១) លក្ខខណ្ឌដែលអាចធ្វើបណ្តឹងទាស់ (១.២) សិទ្ធិក្នុងការធ្វើបណ្តឹងទាស់ (១.៣) របៀបធ្វើបណ្តឹងទាស់ និង អានុភាពនៃបណ្តឹងទាស់ (១.៤) ។

- **ជំពូកទី២**: **ចំណាត់ការលើនីតិវិធីនៃបណ្តឹងទាស់** ៖ នៅក្នុងជំពូកនេះ នឹងបង្ហាញឱ្យលោកអ្នកយល់ដឹងអំពីដំណាក់កាលនៃការដាក់ពាក្យបណ្តឹង (២.១) ការដកពាក្យបណ្តឹង និងការកំណត់កាលបរិច្ឆេទថ្មីលើបណ្តឹងទាស់ (២.២) ការសម្រេចសេចក្តីលើបណ្តឹងទាស់ (២.៣) និងសាលក្រមកំបាំងមុខលើកទី២ (២.៤) ។

- **ជំពូកទី៣**: **បញ្ហាប្រឈម និងដំណោះស្រាយ** ៖ នៅក្នុងជំពូកនេះ នឹងបង្ហាញឱ្យលោកអ្នកយល់ដឹងអំពីភាពខ្វះចន្លោះនៃច្បាប់ (៣.១.១) ការយល់ដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋនៅមានកម្រិត (៣.១.២) ការកោះហៅមិនស្របច្បាប់ (៣.១.៣) អវត្តមានរបស់ភាគី (៣.១.៤) ការយឺតយ៉ាវក្នុងការជម្រះក្តីលើបណ្តឹងទាស់ (៣.១.៥) និងការផុតរយៈពេលនៃការដាក់ពាក្យបណ្តឹងទាស់ (៣.១.៦) ។

- **សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ៖ ខ្ញុំបាទ បានធ្វើសេចក្តីសន្និដ្ឋានជារួមនៃប្រធានបទទាំងមូល និងលើកឡើងនូវអនុសាសន៍មួយចំនួន ដែលខ្ញុំបានមកពីការរកឃើញនៅក្នុងសារណានេះ។

# ជំពូកទី១
# សញ្ញាណទូទៅនៃបណ្តឹងអាស់

# ជំពូកទី១

# សញ្ញាណទូទៅនៃបណ្ដឹងទាស់

នៅក្នុងការអនុវត្តនីតិវិធីរដ្ឋប្បវេណី ការចូលរួមបង្ហាញខ្លួនរបស់គូភាគីនៃរឿងក្ដីនៅក្នុងនីតិវិធីរបស់តុលាការគឺជាភាពចាំបាច់បំផុត ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពក៏ដូចជាភាពត្រឹមត្រូវនិងយុត្តិធម៌ទៅលើការសម្រេចសេចក្ដីរបស់តុលាការ។ ប្រសិនបើច្បាប់អនុញ្ញាតឱ្យតុលាការអាចកោះហៅភាគីតែម្ខាងមកវិនិច្ឆ័យក្ដីនៅក្នុងកាលបរិច្ឆេទ ឬ ទីកន្លែងដែលអវត្តមានភាគីម្ខាងទៀត នោះទំនុកចិត្តលើការវិនិច្ឆ័យក្ដីអាចនឹងត្រូវបាត់បង់ ហេតុនេះហើយ ទើបការវិនិច្ឆ័យចាំបាច់ត្រូវបានធ្វើឡើងដោយគោរពតាមគោលការណ៍ចំពោះមុខ ដែលតម្រូវឱ្យមានវត្តមានរបស់គូភាគីនៅក្នុងកាលបរិច្ឆេទនោះ និងចំពោះមុខគ្នា[២]។ មានន័យថា ការគោរពតាមគោលការណ៍ចំពោះមុខដែលមានបញ្ញត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ដែលតម្រូវឱ្យមានវត្តមានភាគីតាមកាលបរិច្ឆេទដែលបានកំណត់ដោយតុលាការ ដើម្បីឱ្យភាគីធ្វើនូវសេចក្ដីថ្លែងការណ៍អះអាងអំពីអង្គហេតុ ដាក់មធ្យោបាយតទល់ នឹងធ្វើសកម្មភាពបណ្ដឹងនៅគ្រប់ដំណាក់កាលនៃនីតិវិធីរបស់តុលាការ។ គោលការណ៍ចំពោះមុខមានបំណងដើម្បីប្រមូលយកភស្តុតាងឱ្យបានគ្រប់សមល្មម ដែលអាចធ្វើឱ្យតុលាការចេញសេចក្ដីសម្រេចមួយមានភាពត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ។ ប៉ុន្តែ នៅពេលភាគីណាម្នាក់ដែលទទួលបានការកោះហៅត្រឹមត្រូវពីតុលាការឱ្យចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តែខ្លួនមិនបានចូលរួមនីតិវិធីតាមកាលបរិច្ឆេទដែលបានកំណត់ដោយគ្មានមូលហេតុច្បាស់លាស់ តុលាការអាចសម្រេចសេចក្ដីដោយចេញសាលក្រមកំបាំងមុខភាគីនោះបាន។

ដោយហេតុថាសាលក្រមកំបាំងមុខ មានការសម្រេចសេចក្ដីដោយមិនបានធ្វើការសាកសួរភាគី ដែលធ្វើឱ្យប៉ះពាល់ ឬ ខូចប្រយោជន៍របស់ភាគីនោះ ទើបក្រមនីតិវិធីរដ្ឋប្បវេណីបានទុកសិទ្ធិឱ្យភាគីដែលតុលាការបានចេញនូវសាលក្រមកំបាំងមុខ មានសិទ្ធិក្នុងការធ្វើបណ្ដឹងទាស់ចំពោះសាលក្រមកំបាំងមុខនោះបាន។ ប៉ុន្តែមុននឹងបកស្រាយលម្អិតអំពីសិទ្ធិក្នុងការធ្វើបណ្ដឹងទាស់ចំពោះសាលក្រមកំបាំងមុខ តើត្រូវមានលក្ខខណ្ឌចាំបាច់អ្វីខ្លះ ដែលអាចធ្វើបណ្ដឹងទាស់បានដូចការលើកឡើងលើនេះ ខ្ញុំសូមធ្វើការបកស្រាយទៅលើពាក្យថាបណ្ដឹងទាស់ជាមុនសិន ដើម្បីបានជាទុនមួយសម្រាប់យល់ដឹងឱ្យកាន់តែច្បាស់ទៅលើសិទ្ធិក្នុងការធ្វើបណ្ដឹងទាស់នៅក្នុងចំណុចនិយមន័យបណ្ដឹងទាស់ (១.១) ដូចខាងក្រោមនេះ។

## ១.១.និយមន័យបណ្ដឹងទាស់

បណ្ដឹងទាស់ គឺជាប្រភេទបណ្ដឹងមួយដែលធ្វើឡើងដោយភាគីណាមួយនៃរឿងក្ដី ដោយធ្វើឡើងប្រឆាំង

[២] មាត្រា៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

នឹងសាលក្រមកំបាំងមុខខ្លួន។ បណ្តឹងទាស់ គឺជាផ្លូវតវ៉ាដែលបើកសិទ្ធិឱ្យភាគីដែលមិនបានបង្ហាញខ្លួនតាមកាលបរិច្ឆេទ ប្តឹងទៅតុលាការដែលបានចេញសាលក្រម ឱ្យលើកយករឿងនេះមកចាត់ការឡើងវិញតាមនីតិវិធីត្រឹមពេលវត្តមានកើតឡើង បន្ទាប់ពីបានទទួលសាលក្រមកំបាំងមុខ ដោយមានមូលហេតុមិនអាចព្យាករណ៍បាន ឬ មានមូលហេតុមិនអាចជៀសវាងបាន[៣]។

បន្ទាប់ពីបានស្គាល់ថាអ្វីទៅជាបណ្តឹងទាស់ដូចបានបកស្រាយខាងលើរួចហើយ យើងក្រឡេកមកមើលអំពីលក្ខខណ្ឌក្នុងការធ្វើបណ្តឹងទាស់វិញម្តង ដែលការផ្តល់សិទ្ធិក្នុងការធ្វើបណ្តឹងទាស់ ក៏មានកំណត់អំពីលក្ខខណ្ឌមួយចំនួន ដើម្បីអាចធ្វើបណ្តឹងទាស់បានដោយត្រូវពិចារណាទៅលើចំណុចទាំងនោះរួមមានដូចជា៖ លក្ខខណ្ឌដែលអាចធ្វើបណ្តឹងទាស់(១.១) សិទ្ធិក្នុងការធ្វើបណ្តឹងទាស់ (១.២) និងរបៀបធ្វើបណ្តឹងទាស់និងអានុភាពនៃបណ្តឹងទាស់ (១.៣)។

## ១.២.លក្ខខណ្ឌដែលអាចធ្វើបណ្តឹងទាស់

បណ្តឹងទាស់ដែលអាចធ្វើឡើងបាន យើងត្រូវធ្វើការពិចារណាទៅលើលក្ខខណ្ឌពីរសំខាន់ៗគឺ ៖ ទី១ សាលក្រមដែលអាចធ្វើបណ្តឹងទាស់ (១.១.១) និងទី២ អំឡុងពេលដែលអាចធ្វើបណ្តឹងទាស់បាន(១.១.២)។

### ១.២.១.សាលក្រមដែលអាចធ្វើបណ្តឹងទាស់

សាលក្រមដែលអាចធ្វើបណ្តឹងទាស់បាន គឺសំដៅដល់សាលក្រមដែលតុលាការបានធ្វើការសម្រេចសេចក្តីកំបាំងមុខចំពោះភាគីណាមួយដែលបានទទួលការកោះហៅត្រឹមត្រូវតាមច្បាប់ ប៉ុន្តែភាគីនោះមិនបានចូលបង្ហាញខ្លួនតាមកាលបរិច្ឆេទដែលតុលាការបានកំណត់ ដោយពុំមានមូលហេតុច្បាស់លាស់ ជាហេតុនាំឱ្យតុលាការចេញនូវសាលក្រមកំបាំងមុខភាគីនោះ។ តាមរយៈករណីនេះ យើងឃើញថាបណ្តឹងទាស់គឺជាបណ្តឹងឧបាស្រ័យរបស់ភាគីដែលពុំយល់ស្របជាមួយសាលក្រមកំបាំងមុខរបស់ចៅក្រម ឬ តុលាការដើម្បីទាមទារឱ្យមានការលុបចោល ឬ ផ្លាស់ប្តូរសាលក្រមកំបាំងមុខនោះ។

ដូច្នេះ សាលក្រមដែលជាកម្មវត្ថុដែលអាចធ្វើបណ្តឹងទាស់បានរួមមាន ៖ សាលក្រមកំបាំងមុខដើមចោទ (១.២.១.១) និងសាលក្រមកំបាំងមុខចុងចម្លើយ (១.២.១.២) ដែលនឹងធ្វើការបកស្រាយលម្អិតសេចក្តីនៅចំណុចខាងក្រោមនេះ ទៅលើលក្ខខណ្ឌ ក៏ដូចជាមូលហេតុជាក់ស្តែងដែលនាំឱ្យតុលាការសម្រេចសេចក្តីដោយចេញនូវសាលក្រមកំបាំងមុខនេះឡើង ចំពោះភាគីណាមួយដែលអវត្តមាននោះ។

#### ១.២.១.១.សាលក្រមកំបាំងមុខដើមចោទ

សាលក្រមកំបាំងមុខដើមចោទ គឺជាសាលក្រមដែលធ្វើឡើងចំពោះដើមចោទ ដោយសារតែដើមចោទមិន

[៣]មាត្រា២០៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ និងសៀវភៅមេរៀន នីតិវិធីរដ្ឋប្បវេណីរបស់លោកសាស្ត្រាចារ្យ ហេង ប៉ូវ៉ា ឆ្នាំសិក្សា២០២១-២០២២ ទំព័រ៩៥

បានចូលបង្ហាញខ្លួននៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផល។ ករណីនេះ តុលាការត្រូវច្រានចោលការទាមទាររបស់ដើមចោទ ដោយការចេញនូវសាលក្រមកំបាំងមុខដើមចោទ[៤] ដោយសន្មត់ថាការមិនបង្ហាញខ្លួនរបស់ដើមចោទនាកាលបរិច្ឆេទទី១ ជាហេតុធ្វើឱ្យតុលាការយល់ឃើញថាដើមចោទមិនមានឆន្ទៈក្នុងការធ្វើនីតិវិធីបន្តទៀតទេ។ ការយល់ឃើញបែបនេះ នាំឱ្យតុលាការធ្វើការសម្រេចសេចក្តីច្រានចោលការទាមទាររបស់ដើមចោទដោយចេញសាលក្រមកំបាំងមុខ ដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នោះទេ។

ប្រសិនបើដើមចោទមិនបង្ហាញខ្លួន នៅកាលបរិច្ឆេទដើម្បីបន្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះទេ (អាចជានីតិវិធីត្រៀមលើកទី២ ឬលើសពីនេះ) តុលាការនឹងបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលភ្លាមៗ ដោយធ្វើការកំណត់កាលបរិច្ឆេទទី១ នៃការទាញហេតុផលដោយផ្ទាល់មាត់។ បន្ទាប់ពីកាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់ដែលបានកំណត់មកដល់ ភាគីដើមចោទនៅតែបន្តអវត្តមាន តុលាការនឹងធ្វើការច្រានចោលការទាមទាររបស់ដើមចោទ ដោយការចេញនូវសាលក្រមកំបាំងមុខដើមចោទ[៥]។

### ១.២.១.២.សាលក្រមកំបាំងមុខចុងចម្លើយ

សាលក្រមកំបាំងមុខចុងចម្លើយ គឺជាសាលក្រមដែលធ្វើឡើងចំពោះចុងចម្លើយ បើចុងចម្លើយមិនបានចូលបង្ហាញខ្លួននៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការត្រូវបញ្ឈប់នីតិវិធីសម្រាប់ការទាយហេតុផលដោយភ្លាមៗ ហើយកំណត់នូវកាលបរិច្ឆេទលើកទី១ នៃការទាញហេតុផលដោយផ្ទាល់មាត់។

ម្យ៉ាងទៀត ប្រសិនបើកាលបរិច្ឆេទនៃនីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់បានមកដល់ ហើយភាគីចុងចម្លើយមិនបានចូលបង្ហាញខ្លួនក្នុងការទាញហេតុផលដោយផ្ទាល់មាត់នោះទេ តុលាការត្រូវចាត់ទុកថាចុងចម្លើយបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទដែលទាក់ទងនឹងអង្គហេតុ។ ករណីនេះតុលាការអាចទទួលស្គាល់ការទាមទាររបស់ដើមចោទដោយសាលក្រមកំបាំងមុខចុងចម្លើយ ប្រសិនបើយល់ឃើញថាការទាមទាររបស់ដើមចោទមានភាពត្រឹមត្រូវ។ ផ្ទុយទៅវិញ បើតុលាការយល់ឃើញថា ការទាមទាររបស់ដើមចោទមិនត្រឹមត្រូវទេ តុលាការត្រូវច្រានចោលការទាមទារនោះ។ ប៉ុន្តែករណីនេះ មិនត្រូវបានអនុវត្តឡើយ ប្រសិនបើចុងចម្លើយធ្វើវិវាទលើការអះអាងរបស់ដើមចោទ នៅកាលបរិច្ឆេទនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ពីមុនមក[៦]។

---

[៤] មាត្រា ២០០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៥] មាត្រា ២០០ កថាខណ្ឌទី២ និងទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៦] មាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

**ឧទាហរណ៍៖** ចុងចម្លើយ បានចូលរួមកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងបានថ្លែងការណ៍បដិសេធចំពោះការអះអាងរបស់ដើមចោទ ដែលបានចោទថាខ្លួនបានខ្ចីប្រាក់ពីដើមចោទ ២០០០០ (ពីរម៉ឺន) ដុល្លារ និងបានទាមទាការប្រាក់ ១% ក្នុងមួយខែ និងការប្រាក់ពិន័យ ១% ក្នុងមួយខែ។ ចុងចម្លើយទទួលថាខ្លួនពិតជាបានខ្ចីប្រាក់ពីដើមចោទមែន ប៉ុន្តែ មិនមែន ២០០០០ (ពីរម៉ឺន) ដុល្លារនោះទេ គឺមានចំនួនត្រឹមតែ១៥០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារ និងមានការប្រាក់ត្រឹមតែ ០,៥% ក្នុងមួយខែ តែប៉ុណ្ណោះ។ ដើមចោទបានបដិសេធចំពោះការលើកឡើងរបស់ចុងចម្លើយ ហើយនៅតែអះអាងថា ចុងចម្លើយពិតជាបានខ្ចីខ្លួនចំនួន ២០០០០(ពីរម៉ឺន) ដុល្លារ ពិតប្រាកដមែន។ លុះនៅកាលបរិច្ឆេទ នៃការទាញហេតុផលដោយផ្ទាល់មាត់ ចុងចម្លើយបានទទួលដំណឹងពីដីកាកោះរួចហើយ ប៉ុន្តែមិនបានចូលរួមនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ដោយគ្មានមូលហេតុ ហើយតុលាការដំបូងសម្រេចចេញសាលក្រម។ ករណីនេះ តុលាការអាចចេញសាលក្រមដោយផ្អែកលើការអះអាងពីមុនរបស់ចុងចម្លើយ។ សាលក្រមនេះ មិនមែនជាសាលក្រមកំបាំងមុខទេ គឺសាលក្រមធម្មតា។

បន្ទាប់ពីតុលាការបានសម្រេចសេចក្តីចេញនូវសាលក្រមកំបាំងមុខ តុលាការបានទុកសិទ្ធិឱ្យភាគីនៃសាលក្រមកំបាំងមុខនោះ អាចធ្វើបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខខ្លួនបាន នៅក្នុងអំឡុងពេលដែលបានកំណត់សម្រាប់ធ្វើនូវបណ្តឹងទាស់ផងដែរ។

### ១.២.២.អំឡុងពេលដែលអាចធ្វើបណ្តឹងទាស់បាន

បណ្តឹងទាស់ គឺជាបណ្តឹងឧបាស្រ័យមួយប្រភេទដែលធ្វើឡើងប្រឆាំងនឹងសាលក្រមកំបាំងមុខខ្លួន ដើម្បីប្តឹងទាមទារឱ្យមានការលុបចោល ឬ ផ្លាស់ប្តូរសាលក្រមកំបាំងមុខនោះ ដែលមានកម្មវត្ថុទាមទារឱ្យតុលាការដែលបានជម្រះក្តី ឱ្យធ្វើការវិនិច្ឆ័យសារជាថ្មីម្តងទៀតទៅលើសាលក្រមកំបាំងមុខ។

បណ្តឹងទាស់ត្រូវធ្វើឡើងក្នុងកំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលទទួលការបញ្ជូនសាលក្រមកំបាំងមុខ[៧]។ លើសពីនេះទៅទៀត អំឡុងពេលសម្រាប់ធ្វើបណ្តឹងទាស់ពុំអាចពន្យារបានឡើយ។ ប៉ុន្តែ ប្រសិនបើសាលក្រមកំបាំងមុខត្រូវបានបញ្ជូនតាមរយៈការផ្សាយជាសាធារណៈ ឬ តាមរយៈការបញ្ជូនដែលធ្វើនៅបរទេស តុលាការត្រូវកំណត់អំឡុងពេលដែលអាចធ្វើបណ្តឹងទាស់នៅក្នុងសាលក្រមកំបាំងមុខនោះតែម្តង[៨]។ ជាមួយនឹងការកំណត់អំពីអំឡុងពេលសម្រាប់ធ្វើនូវបណ្តឹងទាស់ ក៏តម្រូវឱ្យភាគីដែលធ្វើបណ្តឹងទាស់មានសិទ្ធិក្នុងការធ្វើបណ្តឹងទាស់ ដែលសិទ្ធិទាំងនោះនឹងត្រូវលើកយកមកធ្វើការបកស្រាយលម្អិតឱ្យមានសេចក្តីច្បាស់លាស់នៅក្នុងចំណុចបន្ទាប់។

[៧] មាត្រា ២០៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៨] មាត្រា ២០៤ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

## ១.៣.សិទ្ធិក្នុងការធ្វើបណ្តឹងទាស់

សិទ្ធិក្នុងការធ្វើបណ្តឹងទាស់ គឺជាលក្ខខណ្ឌមួយដ៏សំខាន់ ដែលតម្រូវឱ្យភាគីដាច់ខាតត្រូវតែមាននៅពេលធ្វើបណ្តឹង។ បើភាគីដែលមានបំណងក្នុងការធ្វើបណ្តឹងទាស់ មិនមានសមត្ថភាពក្នុងការបំពេញឱ្យបានគ្រប់គ្រាន់ទៅតាមលក្ខខណ្ឌច្បាប់តម្រូវឱ្យមាននោះទេ គាត់ក៏មិនមានសិទ្ធិក្នុងការធ្វើនូវបណ្តឹងទាស់បានដែរ។

ចំពោះលក្ខខណ្ឌដើម្បីទទួលបាននូវសិទ្ធិក្នុងការធ្វើបណ្តឹងទាស់ឱ្យមានភាពត្រឹមត្រូវទៅតាមច្បាប់ដែលបានកំណត់ ត្រូវតែសិក្សាស្វែងយល់នូវចំណុចសមត្ថភាពភាគីក្នុងការធ្វើបណ្តឹងជាមុនសិន ព្រោះជាចំណុចសំខាន់ដែលយើងត្រូវតែយល់ដឹងជាចាំបាច់។

### ១.៣.១.សមត្ថភាពភាគីក្នុងការធ្វើបណ្តឹង

សមត្ថភាពភាគីក្នុងការធ្វើបណ្តឹង គឺជាលក្ខណសម្បត្តិ ឬ បុគ្គលដែលពាក់ព័ន្ធក្នុងនីតិវិធីបណ្តឹងអាចធ្វើសកម្មភាពដោយខ្លួនឯងបានឱ្យមានអានុភាព ឬ ទទួលនូវសកម្មភាពបណ្តឹងរបស់តុលាការ និងភាគីម្ខាងទៀតតាមផ្លូវច្បាប់[៩] ។

ទោះបីជាបុគ្គលនោះមានសមត្ថភាពក៏ដោយ តែប្រសិនបើសាមីខ្លួនពុំមានសមត្ថភាពអាចយល់បាននូវគោលគំនិត ឬ អានុភាពនៃសកម្មភាពនៅពេលដែលបានធ្វើ ឬ ទទួលសកម្មភាពនៃនីតិវិធីបណ្តឹងបានទេ អាចនិយាយបានយ៉ាងពិតប្រាកដថាបុគ្គលនោះ មិនអាចការពារផលប្រយោជន៍របស់ខ្លួនតាមបណ្តឹងបានឡើយ ហើយអាចបាត់បង់នូវផលប្រយោជន៍នោះទៀតផង។ ថ្វីត្បិតតែនៅក្នុងគោលការណ៍ក្រមនីតិវិធីរដ្ឋប្បវេណីបានផ្តល់ និងធានាឱ្យបុគ្គលគ្រប់រូបមានសិទ្ធិទទួលបានការពឹងពាក់តុលាការចំពោះវិវាទរដ្ឋប្បវេណី[១០] ក៏ពិតមែន ក៏ប៉ុន្តែ មិនមែនបានន័យថាបុគ្គលគ្រប់រូបនោះ អាចមានសមត្ថភាពធ្វើបណ្តឹងដោយខ្លួនឯងបានឡើយ។ ដោយឃើញថាបុគ្គលមួយចំនួនមិនអាចធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងបាន ឬ មិនអាចការពារនូវផលប្រយោជន៍របស់ខ្លួនបាន ទើបច្បាប់បានបើកសិទ្ធិឱ្យបុគ្គលដែលមិនអាចធ្វើសកម្មភាពបានដោយខ្លួនឯងផ្ទាល់ ឬ បុគ្គលដែលមិនអាចការពារនូវផលប្រយោជន៍របស់ខ្លួននោះ អាចជ្រើសរើសអ្នកតំណាងក្នុងការធ្វើសកម្មភាពការពារនូវផលប្រយោជន៍របស់ខ្លួនបាន។

ជាទូទៅ ភាគីដែលពុំមានសមត្ថភាពគ្រប់គ្រាន់ មិនអាចឆ្លើយតបភ្លាមៗចំពោះការអះអាងរបស់ភាគីម្ខាងទៀត ឬដាក់ភស្តុតាងដើម្បីបញ្ជាក់ការអះអាងរបស់ខ្លួនបានទេ កត្តានេះនឹងនាំឱ្យភាគីដែលពុំមានសមត្ថភាពចាញ់ទាំងខ្លួនមានលទ្ធភាពក្នុងការឈ្នះក្តី។ ដូច្នេះ ដើម្បីការពារបុគ្គលដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអះអាង និងការពារផលប្រយោជន៍របស់ខ្លួនតាមបណ្តឹង ច្បាប់បានបង្កើតនូវរបបនៃសមត្ថភាពក្នុងការធ្វើបណ្តឹង

[៩] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ ស្តីពី នីតិវិធីបណ្តឹង (ឆ្នាំ ២០០៨) របស់ក្រសួងយុត្តិធម៌ ត្រង់ទំព័រទី២៤

[១០] មាត្រា ២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ដោយចាត់ទុកថាបុគ្គលទាំងនោះពុំមានលក្ខណសម្បត្តិធ្វើសកម្មភាពក្នុងការធ្វើបណ្តឹងបានទេ ដោយឱ្យអ្នកតំណាងដែលច្បាប់បានកំណត់ធ្វើសកម្មភាពបណ្តឹងជំនួសបុគ្គលទាំងនោះ[១១]។ ជាគោលការណ៍ ការកំណត់លើបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើបណ្តឹង ត្រូវកំណត់តាមបញ្ញត្តិនៃច្បាប់សារធាតុ (ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧) មកធ្វើជាមូលដ្ឋាន។ នៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នេះផងដែរ បានបញ្ញត្តិអំពីលក្ខខណ្ឌ និងកម្រិតសមត្ថភាពក្នុងការធ្វើបណ្តឹងរបស់អនីតិជន និងជននៅក្រោមអាណាព្យាបាលទូទៅ (១.២.១.១)ជននៅក្រោមហិតូបត្ថម្ភ (១.២.១.២) ជនបរទេស (១.២.១.៣) និងអ្នកតំណាងដោយអាណត្តិ (១.២.១.៤)។

### ១.៣.១.១. អនីតិជន និង ជននៅក្រោមអាណាព្យាបាលទូទៅ

អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ[១២] ។ ចំណែកឯជននៅក្រោមអាណាព្យាបាលទូទៅ សំដៅដល់ជនដែលតុលាការបានប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ដោយមូលហេតុជននោះ ស្ថិតនៅក្នុងស្ថានភាពជានិរន្តន៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។ ប៉ុន្តែលើកលែងចំពោះករណីដែលសាមីខ្លួនមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ នៅពេលដែលមានពាក្យសុំ[១៣] ត្រូវហៅថាជននៅស្ថិតក្រោមអាណាព្យាបាលទូទៅ ហើយត្រូវស្ថិតនៅក្រោមអ្នកអាណាព្យាបាលទូទៅ[១៤]។

ក្នុងចំណោមជនដែលត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាព[១៥] អនីតិជន និងជនដែលនៅក្រោមអាណាព្យាបាលទូទៅ ជាគោលការណ៍ពុំមានសមត្ថភាពក្នុងការធ្វើបណ្តឹងទេ ហើយអាចធ្វើសកម្មភាពបណ្តឹងសុពលបានលុះត្រាតែត្រូវបានធ្វើតាមអ្នកតំណាងដែលច្បាប់បានកំណត់[១៦]។ ករណីនេះ សកម្មភាពបណ្តឹងអាចត្រូវបានលុបចោល ប្រសិនបើអនីតិជន ឬ ជនដែលនៅក្រោមអាណាព្យាបាលទូទៅបានធ្វើសកម្មភាពបណ្តឹងដោយមិនបានទទួលការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់[១៧]។

---

[១១] មាត្រា ៣២ កថាខណ្ឌទី២ និង កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[១២] មាត្រា ១៧ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[១៣] មាត្រា ២៤ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[១៤] មាត្រា ២៥ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[១៥] មាត្រា ១៦ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[១៦] មាត្រា ៣២ កថាខណ្ឌទី ៣ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[១៧] មាត្រា ១៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ក៏ប៉ុន្តែ ទោះបីជាអនីតិជនក៏ដោយ ប៉ុន្តែ ក្នុងករណីដែលជននោះត្រូវបានចាត់ទុកថាដល់នីតិភាពដោយសារអាពាហ៍ពិពាហ៍[១៨] ជននោះមានសមត្ថភាពក្នុងការធ្វើបណ្តឹងជាទូទៅ ម្យ៉ាងទៀត ក្នុងករណីដែលអនីតិជនត្រូវបានអនុញ្ញាតឱ្យចាត់ចែងចំពោះទ្រព្យសម្បត្តិត្រឹមទំហំនោះ[១៩] ជននោះមានសមត្ថភាពក្នុងការធ្វើបណ្តឹងបាន ចំពោះបណ្តឹងដែលទាក់ទងនឹងទ្រព្យសម្បត្តិនោះ ឬ អាជីវកម្មនោះ[២០]។

**១.៣.១.២.ជននៅក្រោមហិតូបត្ថម្ភ**

ជននៅក្រោមហិតូបត្ថម្ភ សំដៅដល់ជន ដែលត្រូវបានតុលាការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ តាមពាក្យសុំរបស់សាមីខ្លួន សហព័ន្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ[២១] ដោយមូលហេតុមានសមត្ថភាពតិចតួចក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។

ដើម្បីធ្វើសកម្មភាពបណ្តឹង អ្នកនៅក្រោមហិតូបត្ថម្ភត្រូវទទួលការយល់ព្រមពីហិតូបត្ថម្ភកៈ[២២] ដូច្នេះដើម្បីដាក់បណ្តឹង ឬ ធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ អ្នកនៅក្រោមហិតូបត្ថម្ភត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈ។ ការយល់ព្រមនេះត្រូវធ្វើការបញ្ជាក់ដោយលាយល័ក្ខណ៍អក្សរ[២៣]។ ក៏ប៉ុន្តែ ដើម្បីធ្វើសកម្មភាពតបចំពោះបណ្តឹង ឬបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដែលត្រូវបានធ្វើឡើងដោយភាគីម្ខាងទៀត មិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈទេ[២៤]។ ប្រសិនបើចាំបាច់ឱ្យមានការយល់ព្រមពីហិតូបត្ថម្ភកៈ ហើយប្រសិនជាពុំបានទទួលការយល់ព្រមនោះទេ ភាគីម្ខាងទៀតពុំអាចដាក់ពាក្យបណ្តឹង ឬ ធ្វើការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បានទេ ( ហិតូបត្ថម្ភកៈពុំមែនជាអ្នកតំណាងដែលច្បាប់បានកំណត់ទេ ដូច្នេះហើយ មិនអាចឱ្យហិតូបត្ថម្ភៈតំណាងបានទេ )។ ក៏ប៉ុន្តែ ចំពោះសកម្មភាពដកពាក្យបណ្តឹង ឬ ដាក់បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ការផ្សះផ្សាជាដើម ដែលជាសកម្មភាពបញ្ចប់បណ្តឹងដោយមិនឆ្លងកាត់តាមសាលក្រម ឬ សាលដីកា ជននៅក្រោមហិតូបត្ថម្ភចាំបាច់ត្រូវមានការយល់ព្រមពិសេសជានិច្ច[២៥]។

---

[១៨] មាត្រា ៩៦៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[១៩] មាត្រា ១៩ និង មាត្រា២០ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[២០] មាត្រា ៣២ កថាខណ្ឌទី៣ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[២១] មាត្រា ២៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[២២] មាត្រា ៣០ ចំណុច ឃ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[២៣] មាត្រា ៣៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[២៤] មាត្រា ៣៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[២៥] មាត្រា ៣៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

**១.៣.១.៣.ជនបរទេស**

ដោយគោរពតាមគោលការណ៍អធិបតេយ្យនៃរដ្ឋមួយ មាត្រា៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ឱ្យជនបរទេស ដែលចង់ធ្វើសកម្មភាពបណ្តឹងត្រូវតែគោរពនិងប្រតិបត្តិតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះ ជនបរទេសត្រូវចាត់ទុកជាបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹង ប្រសិនបើជនបរទេសនោះមានសមត្ថភាពក្នុងការធ្វើបណ្តឹងដោយយោងតាមបញ្ញត្តិច្បាប់កម្ពុជា ទោះបីជាពុំមានសមត្ថភាពតាមច្បាប់របស់ប្រទេសខ្លួនក៏ដោយ[២៦]។

**១.៣.១.៤.អ្នកតំណាងដោយអាណត្តិ**

ជាគោលការណ៍អ្នកតំណាងដោយអាណត្តិត្រូវតែជាមេធាវី[២៧]។ ក្នុងករណីដែលជនក្រៅពីមេធាវី បានធ្វើសកម្មភាពបណ្តឹងក្នុងនាមជាអ្នកតំណាងដោយអាណត្តិ នោះជាអំពើខុសច្បាប់ ហើយរាល់សកម្មភាពបណ្តឹងជននោះបានធ្វើក្នុងនាមជាភាគីពុំមានសុពលភាពឡើយ លើកលែងតែភាគីបានផ្តល់សច្ចានុមតិសកម្មភាពបណ្តឹងនោះ ទើបអាចមានសុពលភាពបាន[២៨]។ ប៉ុន្តែមានករណីលើកលែងមួយចំនួនដែលច្បាប់ទទួលស្គាល់ការជ្រើសតាំងជនក្រៅពីមេធាវីឱ្យធ្វើជាអ្នកតំណាងដោយអាណត្តិ ដូចជា៖[២៩]

- ច្បាប់អនុញ្ញាតឱ្យតតិយជនដែលមិនមែនជាមេធាវី ធ្វើសកម្មភាពបណ្តឹងជំនួសភាគី
- បុគ្គលិកនៃស្ថាប័នរដ្ឋត្រូវតែងតាំងជាអ្នកតំណាងដោយអាណត្តិឱ្យស្ថាប័នដែលជាភាគី
- តុលាការអនុញ្ញាតឱ្យមានការតំណាងដោយតតិយជន ដែលមិនមែនជាមេធាវីក្នុងរឿងក្តីចំនួនទឹកប្រាក់តិចដែលតម្លៃកម្មវត្ថុនៃបណ្តឹងមិនលើសពី ១.០០០.០០០ (មួយលាន) រៀល ។

ការតំណាងដោយអាណត្តិត្រូវធ្វើឡើងដោយការបង្ហាញឆន្ទៈរបស់ភាគី ប៉ុន្តែទោះបីជាភាគីបានប្រគល់សិទ្ធិតំណាងឱ្យទៅអ្នកតំណាងដោយអាណត្តិក៏ដោយ ក៏ភាគីនៅតែអាចចូលតុលាការដើម្បីទាញហេតុផលដោយផ្ទាល់មាត់ដោយខ្លួនឯងបាន[៣០]។ សិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ[៣១]។ ចំពោះសកម្មភាពបណ្តឹងដែលធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិ មានអានុភាពដូចសកម្មភាពដែលធ្វើដោយភាគីដែរ ប៉ុន្តែអ្នកតំណាងដោយអាណត្តិមិនទទួលនូវអានុភាពនៃសាលក្រមដូចភាគីនោះទេ។

---

[២៦] មាត្រា ៣៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[២៧] មាត្រា ៥៣ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[២៨] មាត្រា ៥៧ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[២៩] មាត្រា ៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៣០] មាត្រា ៥២ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៣១] មាត្រា ៥៣ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ម្យ៉ាងទៀត ប្រសិនបើអ្នកតំណាងដោយអាណត្តិបានសារភាព ឬ ផ្តល់ចម្លើយទាក់ទងនឹងអង្គហេតុ ចម្លើយរបស់អ្នកតំណាងដោយអាណត្តិមិនមានអានុភាពឡើយ ប្រសិនបើភាគីដែលជាម្ចាស់សិទ្ធិបានលុបចោល ឬ កែតម្រូវភ្លាមៗចំពោះសកម្មភាពនោះ[៣២]។

**១.៣.២. អានុភាពតាមផ្លូវច្បាប់នៃសមត្ថភាពក្នុងការធ្វើបណ្តឹងទាស់**

សមត្ថភាពក្នុងការធ្វើបណ្តឹង គឺជាលក្ខខណ្ឌសុពលភាពនៃសកម្មភាពបណ្តឹងនីមួយៗ ហើយសកម្មភាពរបស់ជនដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹងនឹងត្រូវចាត់ទុកជាមោឃៈ ដែលហេតុនាំឱ្យមិនមានស្ថិរភាពក្នុងនីតិវិធីនៃបណ្តឹង។ ដូចនេះ ដើម្បីឱ្យមានស្ថិរភាពក្នុងនីតិវិធីបណ្តឹង តុលាការអាចធ្វើការស្រាវជ្រាវអំពីអត្ថិភាព ឬ នត្ថិភាពនៃសមត្ថភាពក្នុងការធ្វើបណ្តឹងដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន[៣៣] ។

ដើម្បីឱ្យនីតិវិធីនៃរឿងក្តីមានអានុភាពតាមផ្លូវច្បាប់ ភាគីនៃរឿងក្តីត្រូវជៀសវាងនូវចំណុចមួយចំនួនដែលត្រូវបានហាមឃាត់ ក្នុងនោះរួមមាន ៖ ករណីខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹង (១.៣.២.១) និង ឥទ្ធិពលទៅលើបណ្តឹងនៃការខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹង (១.៣.២.២)។

**១.៣.២.១.ករណីខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹងទាស់**

ទោះបីជាសកម្មភាពបណ្តឹងរបស់ជន ដែលមានកង្វះសកម្មភាពក្នុងការធ្វើបណ្តឹងក៏ដោយ មិនមែនមានន័យថាជននោះបាត់បង់នូវផលប្រយោជន៍រាល់ពេលទេ ហេតុនេះហើយ ប្រសិនបើអ្នកតំណាងដែលច្បាប់បានកំណត់ ឬ ភាគីដែលមានសមត្ថភាពក្នុងការធ្វើបណ្តឹងវិញ បានផ្តល់សច្ចានុមតិ សកម្មភាពនោះនឹងមានអនុភាពប្រតិសកម្មតាំងពីពេលនោះត្រូវបានធ្វើឡើង[៣៤] ។

ករណីដែលតុលាការរកឃើញថា មានការខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹង ឬ សិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ ការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្តឹង តុលាការក៏មិនត្រូវបដិសេធសកម្មភាពនោះភ្លាមៗទេ ត្រូវបង្គាប់ឱ្យកែតម្រូវនូវចំណុចដែលខ្វះខាត ដោយកំណត់អំឡុងពេលមួយសម្រាប់កែតម្រូវ។[៣៥] ក្នុងករណីដែលបានបង្គាប់ឱ្យកែតម្រូវ ត្រូវបង្អាក់នូវនីតិវិធីរហូតដល់អំឡុងពេលសម្រាប់ធ្វើការកែតម្រូវនោះបានកន្លងផុតទៅ។ ក៏ប៉ុន្តែ ក្នុងករណីដែលអាចមានការខូចប្រយោជន៍ដោយសារការយឺតយ៉ាវក្នុងអំឡុងពេលបង្អាក់បើមិនធ្វើសកម្មភាពបណ្តឹងណាមួយ តុលាការអាចឱ្យធ្វើសកម្មភាពបណ្តឹងនោះជាបណ្តោះអាសន្នបាន។[៣៦]

---

[៣២] មាត្រា ៥២ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៣៣] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ ស្តីពី នីតិវិធីបណ្តឹង (ឆ្នាំ ២០០៨) របស់ក្រសួងយុត្តិធម៌ ត្រង់ទំព័រទី២៧

[៣៤] មាត្រា ៣៥ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៣៥] មាត្រា ៣៥ កថាខណ្ឌទី ១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៣៦] មាត្រា ៣៥ កថាខណ្ឌទី ១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

### ១.៣.២.២.ឥទ្ធិពលទៅលើបណ្តឹងនៃការខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹងទាស់

ក្នុងករណីដែលដើមចោទពុំមានសមត្ថភាពក្នុងការធ្វើបណ្តឹង នៅពេលដាក់ពាក្យបណ្តឹង ឬ ចុងចម្លើយពុំមានសមត្ថភាពក្នុងការធ្វើបណ្តឹង នៅពេលដែលបានទទួលនូវការបញ្ជូនពាក្យបណ្តឹងនោះ តុលាការត្រូវលើកចោលពាក្យបណ្តឹងនោះដោយសារមូលហេតុមិនស្របច្បាប់ ប្រសិនបើពុំមានការកែតម្រូវនូវចំណុចដែលខ្វះចំពោះបណ្តឹងនោះទេ[៣៧]។

ម៉្យាងទៀត ក្នុងករណីដែលកង្វះនូវសមត្ថភាពក្នុងការធ្វើបណ្តឹងកើតមានឡើង ក្រោយពេលបានចាត់ការបណ្តឹងនោះ ដូចជាបាត់បង់នូវសមត្ថភាពក្នុងការធ្វើបណ្តឹង ឬ មរណភាពរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ឬ ការរំលត់នូវសិទ្ធិតំណាងនោះ នីតិវិធីបណ្តឹងត្រូវផ្អាក ហើយបុគ្គលដែលត្រូវបន្តនីតិវិធីនៃបណ្តឹងគឺអ្នកតំណាងដែលច្បាប់បានកំណត់ដែលត្រូវជ្រើសតាំងថ្មី ឬភាគីមានសមត្ថភាពក្នុងការធ្វើបណ្តឹងឡើងវិញ[៣៨]។

ទន្ទឹមនឹងការកំណត់ឱ្យបំពេញនូវលក្ខខណ្ឌដើម្បីទទួលបាននូវសិទ្ធិក្នុងការធ្វើបណ្តឹងទាស់ ច្បាប់ក៏បានទុកសិទ្ធិឱ្យភាគីក្នុងការសម្រេចចិត្តដើម្បីធ្វើបណ្តឹងទាស់ ឬ ក៏លះបង់សិទ្ធិក្នុងការធ្វើបណ្តឹងទាស់ ដោយធ្វើបណ្តឹងឧទ្ធរណ៍តែម្តង។ ករណីនេះនឹងត្រូវលើកយកមកបកស្រាយលម្អិតនៅចំណុចបន្ទាប់ដូចខាងក្រោមនេះ។

### ១.៣.៣. ការលះបង់សិទ្ធិក្នុងការធ្វើបណ្តឹងទាស់

ការលះបង់សិទ្ធិក្នុងការធ្វើបណ្តឹងទាស់ គឺជាសិទ្ធិមួយដែលច្បាប់បានផ្តល់ឱ្យភាគីក្នុងការសម្រេចថាខ្លួនគួរធ្វើបណ្តឹងទាស់ ឬ ក៏មិនគួរធ្វើបណ្តឹងទាស់ដោយធ្វើបណ្តឹងឧទ្ធរណ៍តែម្តង តាមការជ្រើសរើសរបស់ភាគីដែលត្រូវបានតុលាការចេញនូវសាលក្រមកំបាំងមុខ។ ច្បាប់មិនបានចាប់បង្ខំឱ្យភាគីដែលត្រូវបានតុលាការចេញនូវសាលក្រមកំបាំងមុខត្រូវតែធ្វើបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខនោះទេ។

## ១.៤. របៀបធ្វើបណ្តឹងទាស់ និង អានុភាពនៃបណ្តឹងទាស់

បន្ទាប់ពីបានបំពេញនូវលក្ខខណ្ឌក្នុងការធ្វើបណ្តឹងទាស់ ភាគីដែលមានបំណងធ្វើបណ្តឹងទាស់អាចដាក់ពាក្យបណ្តឹងតាមរបៀបនៃការធ្វើបណ្តឹងទាស់ (១.៣.១) ដែលនឹងរៀបរាប់នៅចំណុចខាងក្រោម។ មួយវិញទៀតនៅពេលដែលពាក្យបណ្តឹងត្រូវបានដាក់តាមរបៀបនៃការធ្វើបណ្តឹងទាស់រួចហើយ បណ្តឹងទាស់នោះនឹងបង្កើតនូវអានុភាពមួយចំនួនដែលនឹងធ្វើការបង្ហាញនៅក្នុងចំណុចស្តីពីអានុភាពនៃការធ្វើបណ្តឹងទាស់(១.៣.២)។

### ១.៤.១.របៀបធ្វើបណ្តឹងទាស់

ការធ្វើបណ្តឹងទាស់ ត្រូវធ្វើឡើងដោយវិធីដាក់ពាក្យបណ្តឹងទាស់ទៅតុលាការដែលបានចេញសាលក្រមកំបាំងមុខ ដោយត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយពាក្យបណ្តឹងនោះត្រូវបំពេញលក្ខខណ្ឌស្របទៅតាមទម្រង់

[៣៧] មាត្រា ៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៣៨] មាត្រា១៧៣ កថាខណ្ឌទី ១ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ដែលច្បាប់បានកំណត់។ ដូច្នេះហើយដើម្បីឱ្យការធ្វើបណ្តឹងទាស់មានអានុភាពនឹងត្រូវបានតុលាការទទួលស្គាល់ ការធ្វើបណ្តឹងទាស់ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

- ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់គូភាគី ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

- សញ្ញាណសាលក្រមកំបាំងមុខដែលជាកម្មវត្ថុនៃការប្តឹងទាស់។

- បំណងនៃការប្តឹងទាស់ចំពោះសាលក្រមដែលជាកម្មវត្ថុនៃការប្តឹងទាស់។

- មូលហេតុដែលមិនអាចមកបង្ហាញខ្លួនតាមកាលបរិច្ឆេទទាន់ពេលវេលា។[៣៩]

### ១.៤.២. អានុភាពនៃបណ្តឹងទាស់

ក្នុងករណីដែលភាគីណាមួយត្រូវបានតុលាការចេញនូវសាលក្រមកំបាំងមុខ បានធ្វើនូវបណ្តឹងទាស់ ហើយពាក្យបណ្តឹងទាស់នោះត្រូវបានទទួលស្គាល់ នៅពេលដែលពាក្យបណ្តឹងទាស់នោះត្រូវបានទទួលដោយលេខាធិការដ្ឋាននៃសាលាដំបូងដែលបានចេញនូវសាលក្រមកំបាំងមុខ ដែលជាអ្នកទទួលបន្ទុកក្នុងការទទួលពាក្យបណ្តឹងទាស់។ បន្ទាប់ពីបានដាក់ពាក្យបណ្តឹងទាស់ទៅលេខាធិការដ្ឋាននៃសាលាដំបូងដែលមានសមត្ថកិច្ចក្នុងការទទួល និងវិនិច្ឆ័យលើបណ្តឹងទាស់រួចមក បណ្តឹងទាស់នឹងកើតមានអានុភាព ដែលអានុភាពនៃបណ្តឹងទាស់មាន ២ (ពីរ) យ៉ាងគឺ៖

ទី១. បណ្តឹងទាស់មានអានុភាពផ្អាកនូវការចូលជាស្ថាពរនៃសាលក្រមកំបាំងមុខ៖ មានន័យថា ទោះបីជាអំឡុងពេលសម្រាប់ធ្វើបណ្តឹងទាស់ត្រូវបានផុតក៏ដោយ ក៏សាលក្រមកំបាំងមុខនោះមិនអាចចូលស្ថាពរបានដែរ ហើយសេចក្តីសម្រេចនៃសាលក្រមកំបាំងមុខនោះ ក៏មិនអាចអនុវត្តបានឡើយ។

ទី២. បណ្តឹងទាស់បានបង្កើតឱ្យមាននូវគោលការណ៍អវិភាគ៖ មានន័យថា ទោះបីជាភាគីដែលបានធ្វើនូវបណ្តឹងទាស់នោះ បានប្តឹងទាស់តែផ្នែកណាមួយនៃសាលក្រមកំបាំងមុខក៏ដោយ ក៏អានុភាពនៃការផ្អាកការចូលជាស្ថាពរនៃសាលក្រមកំបាំងមុខមានគ្រប់ផ្នែកទាំងអស់នៃសាលក្រមកំបាំងមុខ។

[៣៩] មាត្រា ២០៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

# ជំពូកទី២

# ចំណាត់ការលើនីតិវិធីបណ្តឹងទាស់

# ជំពូកទី២
# ចំណាត់ការលើនីតិវិធីបណ្តឹងទាស់

នៅពេលភាគីណាមួយ ដែលត្រូវបានតុលាការចេញនូវសាលក្រមកំបាំងមុខមានបំណងធ្វើបណ្តឹងទាស់ ភាគីនោះត្រូវដាក់ពាក្យបណ្តឹងទៅតុលាការ ដើម្បីឱ្យតុលាការធ្វើចំណាត់ការលើពាក្យបណ្តឹងទៅតាមនីតិវិធីដែលច្បាប់បានកំណត់។ ចំពោះចំណាត់ការទាំងនោះមានទៅតាមដំណាក់កាលដូចជា ៖ ដំណាក់កាលនៃការដាក់ពាក្យបណ្តឹង (២.១) ការដកពាក្យបណ្តឹង និង ការកំណត់កាលបរិច្ឆេទថ្មីក្នុងការវិនិច្ឆ័យលើបណ្តឹងទាស់ (២.២) ការសម្រេចសេចក្តីលើបណ្តឹងទាស់ (២.៣) និង សាលក្រមកំបាំងមុខលើកទី២ (២.៤) ។

## ២.១.ដំណាក់កាលនៃការដាក់ពាក្យបណ្តឹង

នៅពេលដែលពាក្យបណ្តឹងទាស់ដាក់ទៅកាន់តុលាការ ដើម្បីឱ្យបណ្តឹងទាស់មានអានុភាព ភាគីត្រូវដាក់ពាក្យបណ្តឹងទាស់នោះ ទៅតុលាការដែលមានសមត្ថកិច្ចក្នុងការទទួលពាក្យបណ្តឹង និង សមត្ថកិច្ចក្នុងការពិនិត្យពាក្យបណ្តឹង ។

### ២.១.១.សមត្ថកិច្ចរបស់តុលាការ

#### ២.១.១.១.សមត្ថកិច្ចក្នុងការទទួលពាក្យបណ្តឹង

តុលាការដែលមានសមត្ថកិច្ចក្នុងការទទួលពាក្យបណ្តឹង គឺជាតុលាការដែលបានចេញនូវសាលក្រមកំបាំងមុខ[៤០] (តុលាការសាមី)។ សមត្ថកិច្ចនេះជាសមត្ថកិច្ចផ្តាច់មុខ មានន័យថា មានតែតុលាការដែលបានចេញសាលក្រមកំបាំងមុខនោះទេ ដែលមានសមត្ថកិច្ចក្នុងការទទួលពាក្យបណ្តឹងទាស់។ ដូចនេះ ក្រៅពីតុលាការដែលបានចេញនូវសាលក្រមកំបាំងមុខ គឺមិនមានសមត្ថកិច្ចក្នុងការទទួលនូវពាក្យបណ្តឹងទាស់ ចំពោះសាលក្រមកំបាំងមុខនោះឡើយ ។

#### ២.១.១.២. សមត្ថកិច្ចក្នុងការពិនិត្យពាក្យបណ្តឹង

តុលាការនៃបណ្តឹងទាស់ គឺជាតុលាការដែលមានសមត្ថកិច្ចក្នុងការពិនិត្យពាក្យបណ្តឹងទាស់។ បន្ទាប់ពីទទួលពាក្យបណ្តឹងទាស់រួចមក តុលាការនៃបណ្តឹងទាស់ ដែលជាតុលាការមានសមត្ថកិច្ចក្នុងការពិនិត្យពាក្យបណ្តឹងទាស់ ត្រូវពិនិត្យអំពីភាពត្រឹមត្រូវនៃទម្រង់ដែលច្បាប់បានកំណត់មានដូចជា[៤១]៖

- ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់គូភាគី ហើយនិង ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

- សញ្ញាណសាលក្រមកំបាំងមុខដែលជាកម្មវត្ថុនៃការប្តឹងទាស់។

[៤០] មាត្រា២០៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៤១] មាត្រា២០៥កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

- បំណងនៃការប្តឹងទាស់ចំពោះសាលក្រមដែលជាកម្មវត្ថុនៃការប្តឹងទាស់។

- មូលហេតុដែលមិនអាចមកបង្ហាញខ្លួនតាមកាលបរិច្ឆេទទាន់ពេលវេលា។

ក្នុងករណីដែលពាក្យបណ្តឹងទាស់មិនស្របតាមចំណុចណាមួយ ដែលបានរៀបរាប់ខាងលើនេះទេ តុលាការនឹងធ្វើការបង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតនៃពាក្យបណ្តឹងទាស់នោះ ដោយកំណត់អំឡុងពេលសមរម្យសម្រាប់ធ្វើការកែតម្រូវនូវចំណុចដែលខ្វះខាតទាំងនោះ។ ប្រសិនបើ ក្នុងករណីភាគីដែលទទួលបានការកំណត់អំឡុងពេលសម្រាប់ធ្វើការកែតម្រូវនូវចំណុចខ្វះខាតហើយ តែភាគីដែលធ្វើបណ្តឹងទាស់នោះមិនបានកែតម្រូវចំណុចខ្វះខាតទេ តុលាការនឹងលើកបណ្តឹងទាស់នោះចោលដោយដីកាសម្រេច។ ដីកាសម្រេចលើកបណ្តឹងចោលនេះអាចប្តឹងជំទាស់បាន[៤២] ក្នុងរយៈពេល១ សប្តាហ៍ បន្ទាប់ពីបានទទួលដំណឹងអំពីដីកាសម្រេចលើកចោលបណ្តឹងទាស់[៤៣]។ ប៉ុន្តែប្រសិនបើពាក្យបណ្តឹងទាស់ស្របតាមទម្រង់ដែលមានកំណត់ក្នុងបញ្ញត្តិមាត្រា ២០៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឬពាក្យបណ្តឹងទាស់ត្រូវបានភាគីធ្វើការកែតម្រូវតាមការបង្គាប់តុលាការនោះ បណ្តឹងទាស់នឹងកើតមានឡើងនូវអានុភាព។

### ២.១.២.អានុភាពនៃបណ្តឹងទាស់ដែលត្រូវបានទទួលស្គាល់

បន្ទាប់ពីពាក្យបណ្តឹងទាស់ដាក់ទៅកាន់តុលាការដែលមានសមត្ថកិច្ចនៃបណ្តឹងទាស់ ហើយត្រូវបានទទួលស្គាល់អំពីភាពត្រឹមត្រូវលើទម្រង់នៃបណ្តឹងទាស់ អំឡុងពេលធ្វើបណ្តឹងទាស់ និងមូលហេតុជាមូលដ្ឋានក្នុងការធ្វើបណ្តឹងទាស់រួចមក បណ្តឹងទាស់នឹងមានអានុភាព។ នៅពេលពាក្យបណ្តឹងទាស់មានអានុភាព នីតិវិធីនៃបណ្តឹងត្រូវត្រឡប់ទៅសភាពដើមវិញ ដោយត្រូវចាប់ផ្តើមត្រឹមពេលដែលអវត្តមានរបស់ភាគីកើតមានឡើង។

ហេតុដូច្នេះ តុលាការត្រូវកំណត់កាលបរិច្ឆេទថ្មី ដើម្បីចាប់ផ្តើមអនុវត្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ដើម្បីចាប់ផ្តើមធ្វើការទាញហេតុផលដោយផ្ទាល់មាត់ឡើងវិញ ហើយត្រូវជូនដំណឹងនេះទៅឱ្យភាគី[៤៤]។ មានន័យថា ប្រសិនបើតុលាការបានចេញសាលក្រមកំបាំងមុខភាគីណាមួយ ដោយហេតុថាអវត្តមានចាប់តាំងពីនីតិវិធីត្រៀមសម្រាប់ទាញហេតុផល រហូតដល់នីតិវិធីទាញហេតុដោយផ្ទាល់មាត់បណ្តឹងទាស់ ត្រូវបានធ្វើឡើង ពេលនោះនីតិវិធីត្រូវចាប់ផ្តើមសារឡើងវិញ ចាប់ពីនីតិវិធីត្រៀមសម្រាប់ទាញហេតុផល។ ក៏ប៉ុន្តែប្រសិនបើភាគីទើបតែអវត្តមាននាកាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់ នីតិវិធីត្រូវចាប់ជាថ្មីចាប់ពីនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់តែប៉ុណ្ណោះ។ បន្ទាប់ពីពាក្យបណ្តឹងទាស់មានអានុភាពដែលត្រូវបានទទួលស្គាល់ តុលាការត្រូវចាប់ផ្តើមអនុវត្តនីតិវីធីនៃបណ្តឹងទាស់នោះ ដោយតុលាការត្រូវបញ្ជូនពាក្យបណ្តឹងទាស់ទៅ

[៤២] មាត្រា២០៦ កថាខណ្ឌទី១,២,៣, នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៤៣] មាត្រា៣០៣កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៤៤] មាត្រា២០៨កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ភាគីម្ខាងទៀត ហើយកំណត់កាលបរិច្ឆេទថ្មីដើម្បីវិនិច្ឆ័យបណ្តឹងទាស់ និងធ្វើការកោះហៅគូភាគី[៤៥]។

## ២.២.ការដកពាក្យបណ្តឹង និង ការកំណត់កាលបរិច្ឆេទថ្មីលើបណ្តឹងទាស់

នៅពេលភាគីដែលត្រូវបានតុលាការចេញនូវសាលក្រមកំបាំងមុខ បានធ្វើនូវបណ្តឹងទាស់ឡើងក្នុងគោលបំណងដើម្បីឱ្យតុលាការមានការផ្លាស់ប្តូរ ឬលុបចោលសេចក្តីសម្រេចដើមនោះ។ បន្ទាប់ពីមានការពិនិត្យពាក្យបណ្តឹងថាមានភាពត្រឹមត្រូវរួចហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទថ្មីដើម្បីវិនិច្ឆ័យនឹងកោះហៅគូភាគី។ ប៉ុន្តែ ទន្ទឹមនឹងភាគីដែលត្រូវបានតុលាការចេញសាលក្រមកំបាំងមុខ មានសិទ្ធិក្នុងការធ្វើនូវបណ្តឹងទាស់ ភាគីនោះ ក៏មានសិទ្ធិក្នុងការដកពាក្យបណ្តឹងរបស់ខ្លួនវិញបានផងដែរ ដោយចាប់ពីពេលដែលបានដាក់ពាក្យបណ្តឹងរហូតដល់សាលក្រមនៃបណ្តឹងទាស់ត្រូវបានប្រកាស។ ហើយការដកពាក្យបណ្តឹងនេះផងដែរ ចាំបាច់ត្រូវមានការយល់ព្រមពីចុងចម្លើយ[៤៦]។

ដូច្នេះ ដើម្បីឱ្យកាន់តែច្បាស់ទៅលើចំណុចដែលបានធ្វើការរៀបរាប់ខាងលើ ខ្ញុំបាទសូមធ្វើការបកស្រាយទៅលើចំណុចនៃការដកពាក្យបណ្តឹងទាស់ជាមុនសិន នឹងបន្ទាប់មកគឺការកំណត់កាលបរិច្ឆេទថ្មីក្នុងការវិនិច្ឆ័យលើបណ្តឹងទាស់ ដែលត្រូវធ្វើការបកស្រាយលម្អិតនៅក្នុងចំណុចខាងក្រោមនេះជាបន្តបន្ទាប់។

### ២.២.១.ការដកពាក្យបណ្តឹងទាស់

ការដកពាក្យបណ្តឹង គឺជាសកម្មភាពដកមួយភាគ ឬ ទាំងស្រុងនូវពាក្យសុំទាមទារឱ្យចេញសាលក្រមតាមរយៈបណ្តឹងដោយដើមចោទ។ ចំពោះការដកពាក្យបណ្តឹងទាស់ គឺអាចធ្វើបានរហូតដល់ពេលដែលសាលក្រមចុងក្រោយរបស់តុលាការនៃបណ្តឹងទាស់ត្រូវបានប្រកាស[៤៧]។ ចំពោះនីតិវិធីនៃការដកពាក្យបណ្តឹងទាស់ត្រូវបានអនុវត្តដូចគ្នាទៅនិងការដកពាក្យបណ្តឹងឧទ្ធរណ៍[៤៨] ដែលការដកពាក្យបណ្តឹងទាស់ត្រូវបានធ្វើការបែងចែកជា២ (ពីរ) ប្រភេទ៖

#### ២.២.១.១.ការដកពាក្យបណ្តឹងជាលាយល័ក្ខណ៍អក្សរ

ការដកពាក្យបណ្តឹងត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ[៤៩]។ នៅពេលដែលមានការដកពាក្យបណ្តឹងជាលាយល័ក្ខណ៍អក្សរ តុលាការត្រូវធ្វើការបញ្ជូនលិខិតដកពាក្យបណ្តឹងទៅចុងចម្លើយ[៥០]។ ប្រសិនបើចុងចម្លើយ

[៤៥] មាត្រា២០៦កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៤៦] មាត្រា ២១៧ កថាខណ្ឌទី ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៤៧] មាត្រា២១២កថាខណ្ឌទី១ និង ២៦៩កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៤៨] មាត្រា២១២កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៤៩] មាត្រា ២១៧ កថាខណ្ឌទី ៣ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៥០] មាត្រា ២១៧ កថាខណ្ឌទី៣ និងទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

មិនបានតវ៉ាក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ បន្ទាប់ពីបានទទួលការបញ្ជូនលិខិតស្តីពីការដកពាក្យបណ្តឹងនោះទេ ត្រូវបានចាត់ទុកថាចុងចម្លើយបានយល់ព្រមពីការដកពាក្យបណ្តឹង[៥១]។ ប៉ុន្តែ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ការដកពាក្យបណ្តឹងអាចធ្វើឡើងដោយផ្ទាល់មាត់ក៏បាន[៥២]។

**២.២.១.២.ការដកពាក្យបណ្តឹងដោយផ្ទាល់មាត់**

នៅពេលដែលមានការដកពាក្យបណ្តឹងដោយផ្ទាល់មាត់ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវធ្វើការបញ្ជូនឯកសារចម្លងកំណត់ហេតុនៃកាលបរិច្ឆេទក្នុងនីតិវិធីនោះទៅចុងចម្លើយ ក្នុងករណីដែលចុងចម្លើយអវត្តមាន។ ច្បាប់បានទុកសិទ្ធិឱ្យចុងចម្លើយធ្វើការតវ៉ាក្នុងអំឡុងពេល២ (ពីរ) សប្តាហ៍ បន្ទាប់ពីទទួលបានការបញ្ជូនឯកសារចម្លងកំណត់ហេតុនៃកាលបរិច្ឆេទក្នុងនីតិវិធីនោះ ប្រសិនបើចុងចម្លើយមិនបានធ្វើការតវ៉ាក្នុងអំឡុងពេល២ (ពីរ) សប្តាហ៍ បន្ទាប់ពីទទួលបានការបញ្ជូនឯកសារចម្លងកំណត់ហេតុនៃកាលបរិច្ឆេទក្នុងនីតិវិធីនោះទេ ត្រូវបានចាត់ទុកថាចុងចម្លើយបានយល់ព្រមនឹងការដកពាក្យបណ្តឹង[៥៣]។

ប្រសិនបើការដកពាក្យបណ្តឹងដោយផ្ទាល់មាត់ ត្រូវបានធ្វើឡើងនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ចុងចម្លើយមានវត្តមាននៅក្នុងកាលបរិច្ឆេទនោះ តុលាការមិនចាំបាច់ធ្វើការចម្លងឯកសារកំណត់ហេតុនៃកាលបរិច្ឆេទក្នុងនីតិវិធីនោះទេ ព្រោះចុងចម្លើយបានដឹងពីការដកពាក្យនោះហើយ[៥៤]។ ច្បាប់បានទុកសិទ្ធិឱ្យចុងចម្លើយធ្វើការតវ៉ាក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ បន្ទាប់ពីថ្ងៃដែលមានការដកពាក្យបណ្តឹង ប្រសិនបើចុងចម្លើយមិនបានធ្វើការតវ៉ាក្នុងអំឡុងពេល ២ (ពីរ)សប្តាហ៍ បន្ទាប់ពីថ្ងៃដែលមានការដកពាក្យបណ្តឹងនោះទេ ត្រូវចាត់ទុកថាចុងចម្លើយបានយល់ព្រមនឹងការដកពាក្យបណ្តឹងនោះហើយ[៥៥]។

**២.២.២. ការកំណត់កាលបរិច្ឆេទថ្មីក្នុងការវិនិច្ឆ័យលើបណ្តឹងទាស់**

ចំពោះការកំណត់កាលបរិច្ឆេទថ្មីក្នុងការវិនិច្ឆ័យបណ្តឹងទាស់ ត្រូវកំណត់ក្នុងអំឡុងពេល៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្តឹងទាស់ត្រូវបានដាក់ទៅតុលាការ លើកលែងតែក្នុងករណីដែលមានមូលហេតុ

---

[៥១] មាត្រា ២១៧ កថាខណ្ឌទី៥ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៥២] មាត្រា ២១៧ កថាខណ្ឌទី៣ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៥៣] មាត្រា ២១៧ កថាខណ្ឌទី ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៥៤] មាត្រា ២១៧ កថាខណ្ឌទី ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៥៥] មាត្រា ២១៧ កថាខណ្ឌទី ៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ពិសេស។ បន្ទាប់ពីតុលាការបានកំណត់អំពីកាលបរិច្ឆេទថ្មីក្នុងការវិនិច្ឆ័យបណ្ដឹងទាស់រួច តុលាការត្រូវធ្វើការកោះហៅគូភាគី។ ចំពោះនីតិវិធីនៃការកោះហៅគូភាគីនេះនឹងត្រូវធ្វើការបកស្រាយនៅចំណុចក្រោមនេះ។

### ២.២.៣.ការកោះហៅគូភាគី

ការកោះហៅគូភាគី គឺជានីតិវិធីមួយដែលប្រើសម្រាប់ជូនដំណឹងទៅភាគីដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍។ នីតិវិធីនៃការកោះហៅទៅភាគីតម្រូវឱ្យធ្វើការបញ្ជូន ទើបជានីតិវិធីមួយត្រឹមត្រូវតាមបញ្ញត្តិច្បាប់ដែលបានកំណត់ ។

ចំពោះការបញ្ជូន គឺជាការជូនដំណឹងដែលធ្វើឡើងតាមវិធីដែលច្បាប់បានកំណត់ ដើម្បីជូនដំណឹងអំពីខ្លឹមសារនៃឯកសារតាមផ្លូវបណ្ដឹងចំពោះភាគី និងអ្នកដទៃទៀតដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍។ ហើយស្ថាប័នដែលទទួលបន្ទុកក្នុងការបញ្ជូននេះរួមមាន មន្ត្រីរដ្ឋបាលទទួលបន្ទុកការបញ្ជូន និងមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន។ មន្ត្រីរដ្ឋបាលទទួលបន្ទុកការបញ្ជូនគឺក្រឡាបញ្ជី ដែលមានមុខងាររៀបចំការផ្ញើ ឬទទួលស្គាល់នូវឯកសារសម្រាប់បញ្ជូន ហើយប្រគល់អំណាចនេះទៅឱ្យមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន និងទទួលមកវិញនូវរបាយការណ៍ស្ដីពីការបញ្ជូនដើម្បីរក្សាទុកក្នុងសំណុំរឿង។ មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនមានដូចជា មន្ត្រីប៉ុស្តិ៍ប្រៃសណីយ៍ អាជ្ញាសាលា ឬ ក្រឡាបញ្ជី ដែលត្រូវធ្វើសកម្មភាពបញ្ជូនដោយផ្ទាល់ចំពោះជនដែលត្រូវទទួលបន្ទុកការបញ្ជូន[៥៦] ហើយទទួលបន្ទុកធ្វើរបាយការណ៍ស្ដីពីសកម្មភាពនេះ ទៅឱ្យមន្ត្រីរដ្ឋបាលទទួលបន្ទុកនៃការបញ្ជូនវិញ។ ចំពោះវិធីនៃការបញ្ជូនត្រូវបានធ្វើការបែងចែកជា ៦ (ប្រាំមួយ) ប្រភេទរួមមាន៖ ការបញ្ជូនដោយការប្រគល់ (២.២.៣.១) ការបញ្ជូនដោយការជួបប្រទះ (២.២.៣.២) ការបញ្ជូនដោយបង្គ្រប់កិច្ច (២.២.៣.៣) ការបញ្ជូនដោយទុកចោល (២.២.៣.៤) ការបញ្ជូនទៅបរទេស (២.២.៣.៥) និង ការបញ្ជូនតាមការផ្សាយជាសារណៈ (២.២.៣.៦)។

#### ២.២.៣.១.ការបញ្ជូនដោយការប្រគល់

ការបញ្ជូនដោយប្រគល់ ជាគោលការណ៍ គឺជាការបញ្ជូនត្រូវធ្វើតាមវិធីប្រគល់ឯកសារទៅឱ្យជនដែលត្រូវទទួលនូវការបញ្ជូននោះ លើកលែងតែមានករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់[៥៧] ដូចជាបញ្ញត្តិនៃមាត្រា២៤៨ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលបានចែងថាការបញ្ជូនទៅអ្នកជាប់ពន្ធនាគារត្រូវធ្វើទៅចំពោះប្រធានពន្ធនាគារ។ ការបញ្ជូនដោយប្រគល់ គឺធ្វើឡើងទៅលំនៅដ្ឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការរបស់ជនដែលត្រូវទទួលការបញ្ជូននោះ។ ម្យ៉ាងវិញទៀត ការបញ្ជូនក៏អាចធ្វើទៅអ្នកតំណាងដែល

[៥៦] មាត្រា ២៤៦ កថាខណ្ឌទី២ និងទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៥៧] មាត្រា ២៤៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ច្បាប់បានកំណត់ អាចធ្វើទៅទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការរបស់អ្នកតំណាងនោះបាន[៥៨]។

**២.២.៣.២.ការបញ្ជូនដោយការជួបប្រទះ**

ការបញ្ជូនដោយការជួបប្រទះ ត្រូវបានធ្វើឡើងក្នុងករណីពុំច្បាស់ថា ជនដែលត្រូវទទួលការបញ្ជូមាន លំនៅដ្ឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការនៅក្នុងប្រទេសកម្ពុជាទេ ការបញ្ជូនអាចធ្វើបាននៅកន្លែងដែលបានជួបប្រទះនោះបាន លើកលែងតែមានករណីដែលមានភាគីបានជូនដំណឹងពីទីកន្លែងនោះ។[៥៩] ម្យ៉ាងវិញទៀត ទោះបីជាជនដែលត្រូវទទួលការបញ្ជូននោះ មានលំនៅដ្ឋាន ទីសំណាក់ ទីកន្លែង អាជីវកម្ម ឬ ទីស្នាក់ការនៅក្នុងប្រទេសកម្ពុជាច្បាស់លាស់ ឬ មានការជូនដំណឹងពីទីកន្លែងដែលត្រូវបញ្ជូនក៏ដោយ បើភាគីមិនប្រកែកចំពោះការបញ្ជូននៅកន្លែងដែលជួបប្រទះទេ គឺអាចធ្វើការបញ្ជូនដោយការជួបប្រទះបាន នេះហៅថា ការបញ្ជូនដោយការជួបប្រទះ[៦០]។

**ឧទាហរណ៍ ៖** ទូរសព្ទ័ប្រាប់ភាគីមកតុលាការ ឬ ណាត់ជួបនៅកន្លែងណាមួយក្រៅពីលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការហើយប្រគល់ឯកសារនៃការបញ្ជូន ដោយមានការយល់ព្រមពីអ្នកទទួលការបញ្ជូននោះ។

**២.២.៣.៣.ការបញ្ជូនដោយបង្គ្រប់កិច្ច**

ការបញ្ជូនដោយបង្គ្រប់កិច្ច ជាការបញ្ជូនដោយប្រគល់នូវឯកសារដែលត្រូវធ្វើការបញ្ជូនទៅជនដទៃទៀត ផ្សេងពីអ្នកត្រូវទទួលការបញ្ជូន នៅកន្លែងដែលត្រូវទទួលការបញ្ជូននោះ។ មានន័យថា ប្រសិនបើមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនធ្វើការបញ្ជូនទៅតាមទីកន្លែងដែលត្រូវបញ្ជូន ប៉ុន្តែពុំបានជួបជនដែលត្រូវទទួលការបញ្ជូននៅទីកន្លែងដែលត្រូវបញ្ជូននោះទេ មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនអាចប្រគល់ឯកសារដែលត្រូវបញ្ជូននោះទៅឱ្យអ្នកបម្រើ ឬ អ្នកផ្សេងទៀតដែលធ្វើការនៅទីនោះ ឬ អ្នកនៅជាមួយដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនោះបាន[៦១]។ ចំពោះអ្នកដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារ គឺជាអ្នកដែលយល់ច្បាស់អំពីសារៈសំខាន់នៃការបញ្ជូន ឬ យល់ដឹងពីអត្ថន័យនៃឯកសារដែលបានទទួល ហើយមានសមត្ថភាពអាចយកឯកសារនោះទៅប្រគល់ឱ្យជនដែលត្រូវទទួលការបញ្ជូនបាន។

**ឧទាហរណ៍៖** ភរិយា អាចទទួលជំនួសប្តីដែលជាបុគ្គលដែលត្រូវទទួលការបញ្ជូនបាន។ ប៉ុន្តែ បើភរិយាជាអ្នកប្តឹងប្តី នោះការទទួលការបញ្ជូនរបស់ភរិយាជំនួសប្តីនឹងត្រូវចាត់ទុកជាមោឃៈ ព្រោះមានទំនាស់

[៥៨] មាត្រា ២៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៥៩] មាត្រា ២៥០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៦០] មាត្រា ២៥១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៦១] មាត្រា ២៥២ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ផលប្រយោជន៍ ម្យ៉ាងទៀតយើងមិនរំពឹងថាភរិយានឹងយកឯកសារដែលត្រូវបញ្ជូននោះទៅឱ្យប្តីទេ ឬ ករណីដែលចុងចម្លើយជាក្រុមហ៊ុន ត្រូវបញ្ជូនទៅបុគ្គលិករបស់ក្រុមហ៊ុននោះបាន។

**២.២.៣.៤.ការបញ្ជូនដោយទុកចោល**

ការបញ្ជូនដោយទុកចោល គឺជាវិធីនៃការបញ្ជូនមួយ ដែលមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនធ្វើការបញ្ជូនទៅតាមទីកន្លែងដែលត្រូវបញ្ជូន ក្នុងករណីដែលជនដែលត្រូវទទួលការបញ្ជូន ឬ អ្នកដែលត្រូវទទួលការប្រគល់ឯកសារតាមរយៈការបញ្ជូនដោយបង្គ្រប់កិច្ច មិនព្រមទទួលការបញ្ជូនដោយគ្មានមូលហេតុត្រឹមត្រូវ ហេតុដូច្នេះឯកសារដែលត្រូវធ្វើការបញ្ជូននោះ មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនអាចទុកចោលនៅកន្លែងដែលត្រូវបញ្ជូននោះបាន[៦២]។ ប៉ុន្តែប្រសិនបើការបដិសេធមិនព្រមទទួលការបញ្ជូន ដោយមាននូវមូលហេតុត្រឹមត្រូវច្បាស់លាស់ ឯកសារដែលត្រូវធ្វើការបញ្ជូនមិនអាចទុកចោលបានទេ ។

**ឧទាហរណ៍៖** ដីកាកោះត្រូវបញ្ជូនទៅឱ្យលោក **A** ពេលអាជ្ញាសាលាយកឯកសារនោះទៅដល់ផ្ទះលោក **A** មិនបានជួបលោក **A** ទេ ជួបតែកញ្ញា **B** ដែលជាអ្នកបម្រើរបស់លោក **A** អាជ្ញាសាលាក៏ប្រគល់ឯកសារនោះឱ្យទៅកញ្ញា **B** ដើម្បីទុកឱ្យលោក **A** ប៉ុន្តែកញ្ញា **B** បានបដិសេធមិនទទួល ដោយសំអាងថាខ្លួនជាអ្នកបម្រើមិនហ៊ានទទួល ការសំអាងបែបនេះ គឺមិនមានមូលហេតុត្រឹមត្រូវទេ អាជ្ញាសាលាក៏បានទុកឯកសារនៅទីនោះ គឺនៅចំពោះមុខកញ្ញា **B**។ ករណីឧទាហរណ៍នេះដដែល បើកញ្ញា **B** បានបដិសេធ មិនទទួលដោយសំអាងថាលោក **A** និងក្រុមគ្រួសារគាត់ទាំងអស់មិននៅទេ ពួកគាត់បានទៅបរទេសអស់ហើយ ទាល់តែ២ (ពីរ) ខែក្រោយបានមកវិញ ហើយខ្លួនគ្មានមធ្យោបាយអាចទាក់ទងគាត់បានទេ ការសំអាងបែបនេះ គឺមានមូលហេតុត្រឹមត្រូវ នោះមិនអាចទុកឯកសារនៅកន្លែងនោះបានទេ។

**២.២.៣.៥.ការបញ្ជូនដែលត្រូវធ្វើនៅបរទេស**

ការបញ្ជូនដែលត្រូវធ្វើនៅបរទេស ត្រូវបានធ្វើឡើងក្នុងករណីដែលជនត្រូវទទួលការបញ្ជូនមានទីលំនៅនៅបរទេស ហើយពុំមានទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការដែលអាចធ្វើការបញ្ជូនបាននៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ការបញ្ជូនទៅជនដែលត្រូវទទួលការបញ្ជូនអាចធ្វើឡើង២(ពីរ) របៀប ៖[៦៣]

- របៀបទី១៖ ករណីជនដែលត្រូវទទួលការបញ្ជូនជាជនជាតិបរទេស គប្បីបញ្ជូនដោយប្រគល់ឱ្យក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចតាមផ្លូវច្បាប់ (ស្ថាប័នទទួលការប្រគល់) ឬ ស្ថាប័នកណ្តាលនៃប្រទេសនោះជាអ្នកអនុវត្តការបញ្ជូន ។

- របៀបទី២៖ ករណីជនដែលត្រូវទទួលការបញ្ជូនជាជនជាតិខ្មែរតែរស់នៅបរទេស ត្រូវធ្វើការបញ្ជូនដោយ

[៦២] មាត្រា ២៥២ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៦៣] មាត្រា ២៥៣ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ប្រគល់ឱ្យឯកអគ្គរាជទូត ភារធារី ឬ កុងស៊ុលរបស់ព្រះរាជាណាចកកម្ពុជាប្រចាំប្រទេសនោះ ជាអ្នកអនុវត្តការបញ្ជូន។ នីតិវិធីនៃការបញ្ជូននេះ ត្រូវធ្វើឡើងដោយចៅក្រមទទួលបណ្ដឹង ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិដោយប្រគល់កិច្ចការបញ្ជូននេះឱ្យស្ថាប័នដែលមានសមត្ថកិច្ចនេះបាន។

ប៉ុន្តែ មុននឹងធ្វើការបញ្ជូន តុលាការគប្បីពិនិត្យមើលអនុសញ្ញា ឬ សន្ធិសញ្ញារវាងប្រទេសនោះជាមួយនិងប្រទេសកម្ពុជា កិច្ចព្រមព្រៀងផ្សេងទៀត ឬ ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ដោយផ្អែកលើទំនៀមទម្លាប់ ព្រោះករណីខ្លះក្នុងបទដ្ឋានគតិយុត្តទាំងនេះមានកំណត់អំពីរបៀបនៃការបញ្ជូន។ ប៉ុន្តែ ចំពោះការបញ្ជូនទៅជនជាតិបរទេសដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវប្រើតាមវិធីនៃការបញ្ជូនដូចជាការបញ្ជូនចំពោះជនជាតិខ្មែរផងដែរ។

**២.២.៣.៦.ការបញ្ជូនតាមការផ្សាយជាសាធារណៈ**

ការបញ្ជូនតាមការផ្សាយជាសាធារណៈ ត្រូវបានធ្វើឡើងនៅពេលដែលមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនបានធ្វើឡើងនៅក្នុងករណីដែលបានខិតខំប្រឹងប្រែងស្រាវជ្រាវយ៉ាងណាក៏ដោយ ក៏មិនអាចដឹងអំពីទីកន្លែងដែលត្រូវធ្វើការបញ្ជូន ឬ ក្នុងករណីដែលមិនអាចធ្វើការបញ្ជូនទៅបរទេសដោយការប្រគល់កិច្ចការជាដើម ឬបានធ្វើការបញ្ជូនស្ទើរតែគ្រប់វិធីនៃការបញ្ជូនទាំងអស់នៅតែមិនអាចទទួលបានលទ្ធផល ទើបការបញ្ជូនត្រូវបានធ្វើតាមរយៈការផ្សាយជាសាធារណៈ ដែលវិធីនេះជាវិធីចុងក្រោយក្នុងការបញ្ជូន[៦៤]។

ការបញ្ជូនតាមការផ្សាយជាសាធារណៈ ត្រូវធ្វើឡើងដោយវិធីដែលក្រឡាបញ្ជីបិទប្រកាសនៅទីកន្លែងសម្រាប់បិទប្រកាសរបស់តុលាការ ឬ ទីកន្លែងដែលតុលាការទទួលស្គាល់ថាសមស្រប (អាចជាប៉ុស្តិ៍ សាលាឃុំជាដើម) និងត្រូវប្រកាសថាក្រឡាបញ្ជីជាអ្នករក្សាទុកនូវឯកសារដែលធ្វើការបញ្ជូន ហើយអាចប្រគល់ឯកសារនោះឱ្យជនដែលត្រូវទទួលការបញ្ជូននៅពេលណាក៏បានដែរ (ក្នុងម៉ោងធ្វើការ)[៦៥]។ លើសពីនេះ តុលាការអាចចុះនៅក្នុងរាជកិច្ច ឬ ក្នុងសារព័ត៌មាន ផ្សាយថាបានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈនេះ[៦៦]។ ការបញ្ជូនតាមការផ្សាយជាសាធារណៈនេះ ជាគោលការណ៍ត្រូវធ្វើដោយក្រឡាបញ្ជី តុលាការ តាមពាក្យសុំរបស់ភាគី[៦៧]។ ប៉ុន្តែដើម្បីជៀសវាងនូវការយឺតយ៉ាវ តុលាការក៏អាចបង្គាប់ឱ្យក្រឡាបញ្ជីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈដោយឆន្ទានុសិទ្ធិ ទោះបីជាគ្មានពាក្យសុំរបស់ភាគីក៏ដោយ ក្នុងករណីដែលតុលាការយល់ឃើញថាមានការចាំបាច់តាមបញ្ញត្តិមាត្រា២៥៥ កថាខណ្ឌទី១ និងទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

[៦៤] មាត្រា ២៥៥ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៦៥] មាត្រា ២៥៦ កថាខណ្ឌទី១ និងទី២ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៦៦] មាត្រា ២៥៦ កថាខណ្ឌទី៣ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៦៧] មាត្រា ២៥៥ កថាខណ្ឌទី១ វាក្យខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ម្យ៉ាងវិញទៀត បើការបញ្ជូនតាមការផ្សព្វផ្សាយជាសាធារណៈ ត្រូវបានធ្វើឡើងក្នុងករណីដែលលក្ខខណ្ឌនៃការបញ្ជូនដោយបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោលត្រូវបានបំពេញហើយ តែនៅតែមិនអាចបញ្ជូនបាន នោះក្រឡាបញ្ជីគប្បីជូនដំណឹងដោយរបៀបសមរម្យ(តាមទូរស័ព្ទ ផ្ញើរតាមប៉ុស្តិ៍ប្រៃសណីយ៍ ឬបិទនៅលំនៅដ្ឋានទីសំណាក់របស់អ្នកដែលត្រូវទទួលការបញ្ជូនជាដើម) អំពីហេតុដែលនាំឱ្យធ្វើការបញ្ជូនជាសាធារណៈទៅភាគីដែលត្រូវទទួលការបញ្ជូននោះ[៦៨]។ ការបញ្ជូនតាមការផ្សាយជាសាធារណៈចាប់ពី២ (ពីរ) លើកឡើងទៅចំពោះភាគីដដែល តុលាការត្រូវធ្វើដោយឆន្ទានុសិទ្ធិ ប៉ុន្តែ ចំពោះករណីការបញ្ជូនទៅជនដែលនៅបរទេសត្រូវតែមានពាក្យសុំរបស់ភាគីរាល់លើកនៃការផ្សាយជាសាធារណៈ[៦៩]។

ការបញ្ជូនដោយការផ្សាយជាសាធារណៈនឹងមានអានុភាព ជាការបញ្ជូននៅក្រោយអំឡុងពេល២ (ពីរ) សប្តាហ៍កន្លងហួស ដោយគិតចាប់ពីថ្ងៃដែលបានបិទប្រកាសនោះ[៧០]។ ក៏ប៉ុន្តែការបញ្ជូនតាមការផ្សាយជាសាធារណៈពីលើកទីពីរទៅនឹងមានអានុភាពពីថ្ងៃបន្ទាប់ពីការបិទប្រកាសនោះ[៧១]។

## ២.៣. ការសម្រេចសេចក្តីលើបណ្តឹងទាស់

បន្ទាប់ពីតុលាការបានកំណត់កាលបរិច្ឆេទក្នុងការវិនិច្ឆ័យលើបណ្តឹងទាស់ និងបានធ្វើការកោះហៅគូភាគីរួចមក តុលាការអាចធ្វើការវិនិច្ឆ័យ និងការសម្រេចសេចក្តីលើបណ្តឹងទាស់។ ចំណុចទាំងនេះនឹងត្រូវលើកយកមកបកស្រាយលម្អិតនៅចំណុចបន្ទាប់ ។

### ២.៣.១.ការវិនិច្ឆ័យ និង ការសម្រេចសេចក្តីលើបណ្តឹងទាស់

មុននឹងធ្វើការវិនិច្ឆ័យ និងសម្រេចសេចក្តីលើបណ្តឹងទាស់ តុលាការអាចធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់ខ្លួន អំពីភាពត្រឹមត្រូវនៃពាក្យបណ្តឹងទាស់តាមទម្រង់ និងអំឡុងពេលដែលច្បាប់បានកំណត់ និងអំពីភាពត្រឹមត្រូវនៃមូលហេតុបណ្តឹងទាស់[៧២]។ បន្ទាប់ពីតុលាការធ្វើការស្រាវជ្រាវរួច ប្រសិនបើយល់ឃើញថាពាក្យបណ្តឹងទាស់នោះមិនត្រឹមត្រូវតាមច្បាប់ចំពោះទម្រង់ ឬ អំឡុងពេលនៃការធ្វើបណ្តឹងទាស់ តុលាការនឹងចេញនូវដីកាសម្រេចលើកចោលនូវបណ្តឹងទាស់។ ម៉្យាងទៀត ប្រសិនបើតុលាការយល់ឃើញថាពាក្យបណ្តឹងទាស់គ្មានមូលហេតុត្រឹមត្រូវទេ តុលាការនឹងចេញនូវដីកាសម្រេចច្រានចោលបណ្តឹងទាស់[៧៣]។

[៦៨] មាត្រា ២៥៥ កថាខណ្ឌទី៣ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៦៩] មាត្រា ២៥៥ កថាខណ្ឌទី៤ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៧០] មាត្រា ២៥៧ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៧១] មាត្រា ២៥៧ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៧២] មាត្រា ២០៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៧៣] មាត្រា ២០៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ផ្ទុយទៅវិញ ប្រសិនបើតុលាការយល់ឃើញថា ពាក្យបណ្តឹងទាស់មានភាពត្រឹមត្រូវតាមទម្រង់ ធ្វើឡើងក្នុងអំឡុងពេលដែលច្បាប់បានកំណត់ មាននូវមូលហេតុត្រឹមត្រូវដែលជាមូលដ្ឋានគ្រឹះក្នុងការធ្វើបណ្តឹងទាស់ តុលាការនឹងធ្វើការវិនិច្ឆ័យ និងសម្រេចសេចក្តីដោយចេញនូវសាលក្រមសម្រេចលើបណ្តឹងទាស់ ។

ក្រោយពីតុលាការបានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់រួចមក តុលាការអាចធ្វើការប្រកាសសាលក្រមភ្លាមៗក្រោយពីបញ្ចប់នីតិវិធី ឬ លើកពេលសម្រាប់ការប្រកាសសាលក្រមដោយការកំណត់អំឡុងពេលមិនឱ្យលើសពី ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់នូវនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។ ក្នុងអំឡុងពេលដែលមិនទាន់បានប្រកាសសាលក្រមលើបណ្តឹងទាស់ ភាគីដើមអាចធ្វើការដកពាក្យបណ្តឹងបានរហូតដល់ពេលសាលក្រមលើបណ្តឹងទាស់ត្រូវបានប្រកាស ។

### ២.៣.២. សាលក្រមថ្មីដែលសម្រេចលើបណ្តឹងទាស់

សាលក្រមសម្រេចលើបណ្តឹងទាស់ ដែលចេញដោយតុលាការបន្ទាប់ពីយល់ឃើញថាបណ្តឹងទាស់មានភាពត្រឹមត្រូវតាមទម្រង់ អំឡុងពេលសម្រាប់ធ្វើបណ្តឹងទាស់ត្រឹមត្រូវតាមច្បាប់ដែលបានកំណត់ និងមានមូលហេតុត្រឹមត្រូវ តុលាការមានសមត្ថកិច្ចលើបណ្តឹងទាស់ធ្វើការសម្រេចសេចក្តីដោយចេញនូវសាលក្រម ២ (ពីរ) ប្រភេទ៖

- សាលក្រមសម្រេចលើបណ្តឹងទាស់ ដោយតម្កល់សាលក្រមកំបាំងមុខទុកជាបានការ[៧៤]។ មានន័យថា សាលក្រមដែលសម្រេចលើបណ្តឹងទាស់ ដោយតម្កល់សាលក្រមកំបាំងមុខទុកជាបានការ ជាសាលក្រមដែលតុលាការសម្រេចដោយផ្អែកលើការជំនុំជម្រះវិនិច្ឆ័យជាថ្មីម្តងទៀត ក្រោយពេលបន្តនីតិវិធីនោះ។ បន្ទាប់ពីបានចាប់ផ្តើមអនុវត្តនីតិវិធីឡើងវិញហើយ ទទួលបានលទ្ធផលដូចគ្នាទៅនឹងសាលក្រមកំបាំងមុខដែរ តុលាការត្រូវចេញសាលក្រមចុងក្រោយ ដែលប្រកាសថា តម្កល់សាលក្រមកំបាំងមុខនោះទុកជាបានការ។

- សាលក្រមដែលសម្រេចលើបណ្តឹងទាស់។ សាលក្រមសម្រេចលើបណ្តឹងទាស់ ជាសាលក្រមដែលតុលាការសម្រេចដោយផ្អែកលើការជំនុំជម្រះជាថ្មីម្តងទៀត ក្រោយពីបានចាប់ផ្តើមអនុវត្តនីតិវិធីឡើងវិញ ទទួលបាននូវលទ្ធផលមិនដូចគ្នាទៅនឹងសាលក្រមកំបាំងមុខឡើយ។ បានសេចក្តីថា ការជំនុំជម្រះជាថ្មីម្តងទៀតនោះប្រសិនបើមានលទ្ធផលមិនត្រូវគ្នាទេ តុលាការត្រូវចេញសាលក្រមថ្មី ដែលលុបចោលនូវសាលក្រមកំបាំងមុខ ហើយធ្វើការវិនិច្ឆ័យដោយផ្ទាល់ ចំពោះការទាមទាររបស់ដើមចោទនៅក្នុងសាលក្រមថ្មីនោះ[៧៥]។

មួយវិញទៀត ទោះបីជាសាលក្រមកំបាំងមុខ ដែលបានធ្វើឡើងស្របតាមទម្រង់ដែលច្បាប់បានកំណត់ ហើយត្រូវលុបចោលសាលក្រមនោះ ដោយផ្អែកលើពាក្យបណ្តឹងទាស់ក៏ដោយ ក៏សោយហ៊ុយដែលកើតឡើង

[៧៤] មាត្រា ២០៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៧៥] មាត្រា ២០៩ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ដោយសារអវត្តមាន ត្រូវជាបន្ទុករបស់ភាគីដែលមិនបានបង្ហាញខ្លួននោះ។ សោហ៊ុយដែលកើតឡើងដោយសារអវត្តមាននោះរួមមានដូចជា សោហ៊ុយសម្រាប់ការបញ្ជូនពាក្យបណ្តឹងទាស់ សោហ៊ុយស្រាវជ្រាវមូលហេតុនៃបណ្តឹងទាស់ជាដើម ត្រូវជាបន្ទុករបស់ភាគីអវត្តមាន ដោយហេតុថា ភាគីម្ខាងទៀតមិនមានកំហុសនាំឱ្យមានការចំណាយបន្ថែមនោះឡើយ លើកលែងតែករណីដែលសោហ៊ុយនោះបានកើតឡើង ដោយសារសកម្មភាពបណ្តឹងមិនត្រឹមត្រូវរបស់ភាគីម្ខាងទៀត[៧៦]។

ក្រោយពីយើងបានយល់ដឹងអំពីការវិនិច្ឆ័យ និងការសម្រេចសេចក្តីលើបណ្តឹងទាស់ដូចបានបកស្រាយខាងលើរួចមក យើងមកក្រឡេកមើលទៅលើចំណាត់ការនីតិវិធីលើបណ្តឹងទាស់បន្ថែមទៀត នៅពេលដែលនីតិវិធីនោះត្រូវចាប់ផ្តើមឡើងវិញ។ បន្ទាប់ពីតុលាការបានធ្វើការកោះហៅហើយ ប្រសិនបើករណីដែលភាគីដែលបានប្តឹងទាស់នោះ មិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទដំបូងនៃនីតិវិធីដែលត្រូវចាប់ផ្តើមអនុវត្តឡើងវិញទេ តើតុលាការត្រូវមានចំណាត់ការបែបណា ចំពោះភាគីនៃបណ្តឹងទាស់ដែលអវត្តមាននោះ? បញ្ហានេះនឹងធ្វើការបកស្រាយលម្អិតនៅចំណុចខាងក្រោមអំពីសាលក្រមកំបាំងមុខលើកទី២ ។

## ២.៤. សាលក្រមកំបាំងមុខលើកទី២

សាលក្រមកំបាំងមុខជាលើកទី ២ គឺជាសាលក្រមដែលត្រូវបានតុលាការចេញចំពោះភាគីដែលបានធ្វើនូវបណ្តឹងទាស់ នៅក្នុងករណីដែលមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទដំបូងក្រោយពេលបើកនីតិវិធីថ្មី តុលាការអាចចេញនូវសាលក្រមកំបាំងចំពោះភាគីនោះបាន។ ដោយសារមូលហេតុនេះ តុលាការនឹងសម្រេចច្រានចោលបណ្តឹងទាស់ដោយចេញនូវសាលក្រមកំបាំងមុខម្តងទៀត[៧៧] ចំពោះសាលក្រមកំបាំងមុខម្តងទៀតនេះ គេហៅថាសាលក្រមកំបាំងមុខលើកទី២។ ប៉ុន្តែ ស្របពេលដែលតុលាការអាចចេញសាលក្រមកំបាំងមុខលើកទី២ ក៏មានមូលហេតុមួយចំនួន ដែលតុលាការមានសមត្ថកិច្ចលើបណ្តឹងទាស់មិនអាចចេញនូវសាលក្រមកំបាំមុខលើកទី២បានផងដែរ ។ ចំពោះមូលហេតុទាំងនោះនឹងត្រូវលើកយកមកបកស្រាយឱ្យបានច្បាស់លាស់ទៅលើមូលហេតុជាដើមចមដែលធ្វើឱ្យតុលាការមិនអាចសម្រេចសេចក្តីច្រានចោលបណ្តឹងទាស់ ដោយចេញនូវសាលក្រមកំបាំងមុខលើកទី២ បានទេ នៅចំណុចខាងក្រោម ៖

### ២.៤.១.មូលហេតុដែលមិនអាចនាំឱ្យចេញនូវសាលក្រមកំបាំងមុខលើកទី២

ប្រសិនបើភាគីដែលបានធ្វើនូវបណ្តឹងទាស់មិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទដំបូងនៃនីតិវិធីដែលត្រូវចាប់ផ្តើមឡើងវិញក៏ដោយ ក៏តុលាការមិនអាចសម្រេចច្រានចោលបណ្តឹងទាស់ ដោយសាលក្រមកំបាំងមុខ

[៧៦] មាត្រា ២១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៧៧] មាត្រា ២១១ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

លើកទី២ បានទេ[៧៨]។ ប្រសិនបើ ករណីដែលភាគីនៃបណ្តឹងទាស់នោះមិនបង្ហាញខ្លួន ដោយសារមូលហេតុដូចជា៖[៧៩] ភាគីដែលមិនបានបង្ហាញខ្លួនដោយមិនបានទទួលការកោះហៅស្របច្បាប់(២.៤.១.១) ភាគីដែលមិនបង្ហាញខ្លួនដោយមានមូលហេតុដែលមិនអាចជៀសវាងបាន (២.៤.១.២) បណ្តឹងមិនស្របច្បាប់ (២.៤.១.៣) និងការមិនបានជូនដំណឹងអំពីខ្លឹមសារនៃសេចក្តីថ្លែងការណ៍របស់ដើមចោទទៅចុងចម្លើយ (២.៤.១.៤)។

**២.៤.១.១.ភាគីដែលមិនបានបង្ហាញខ្លួនដោយមិនបានទទួលការកោះហៅស្របច្បាប់**

ក្នុងករណីដែលភាគីទទួលបានការកោះហៅដោយត្រឹមត្រូវស្របច្បាប់ ប៉ុន្តែភាគីនោះមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទដំបូងនៃនីតិវិធីដែលត្រូវចាប់ផ្តើមឡើងវិញដែលបានកំណត់ដោយតុលាការទេ នោះជាហេតុនាំឱ្យតុលាការអាចចេញនូវសាលក្រមកំបាំងមុខលើកទី ២ ចំពោះភាគីនោះបាន។ ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើភាគីនោះមិនទទួលបាននូវការកោះហៅដោយស្របច្បាប់វិញ ដែលនាំឱ្យភាគីពុំបានដឹងនៅកាលបរិច្ឆេទត្រូវបង្ហាញខ្លួននៅក្នុងកិច្ចនីតិវិធីដែលតុលាការបានកំណត់ឡើង[៨០] ដូច្នេះ ការចេញនូវសាលក្រមកំបាំងមុខលើកទី២ មិនត្រូវបានអនុញ្ញាតនោះឡើយ។ ការមិនបានទទួលការកោះហៅដោយស្របច្បាប់របស់ភាគី អាចមានស្ថានភាពជាទូទៅដូចជា៖

**ក.មន្ត្រីដែលទទួលបន្ទុកកិច្ចការបញ្ជូន និងមន្ត្រីដែលប្រតិបត្តិការបញ្ជូន មិនបានធ្វើការបញ្ជូនដីកាកោះហៅទៅដល់ភាគី**

មន្ត្រីដែលទទួលបន្ទុកកិច្ចការបញ្ជូន និងមន្ត្រីដែលប្រតិបត្តិការបញ្ជូនមិនបានធ្វើការបញ្ជូននូវដីកាកោះហៅទៅដល់ភាគី ដោយសារតែមន្ត្រីទទួលបន្ទុកនៃកិច្ចការបញ្ជូនមានការយឺតយ៉ាវក្នុងការរៀបចំដីកាកោះហៅនោះ ឬមន្ត្រីដែលប្រតិបត្តិការបញ្ជូន មិនបានធ្វើការបញ្ជូនទៅបុគ្គលដែលត្រូវទទួលការបញ្ជូនដោយរកមិនឃើញនូវអាសយដ្ឋានរបស់បុគ្គលនោះ។

**ខ.ភាគីទទួលបានការកោះហៅដោយមិនស្របច្បាប់**

ភាគីបានទទួលការកោះហៅមិនស្របច្បាប់ ដោយសារមន្ត្រី ឬ បុគ្គលិកដែលប្រតិបត្តិការបញ្ជូនមិនមែនជាមន្ត្រី ឬ បុគ្គលដែលច្បាប់បានកំណត់។ ចំពោះមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនដែលច្បាប់កំណត់រួមមាន ក្រឡាបញ្ជី អាជ្ញាសាលា និងបុគ្គលិកប្រៃសណីយ៍[៨១] ហើយចំពោះបុគ្គលផ្សេងពីបុគ្គលដែលបានលើកបង្ហាញនេះ មិនមានសមត្ថកិច្ចក្នុងប្រតិបត្តិការបញ្ជូនឡើយ។ ដូច្នេះ មូលហេតុដែលនាំឱ្យដីកាកោះហៅដែលបញ្ជូនទៅ

[៧៨] មាត្រា ២០២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៧៩] មាត្រា ២១១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៨០] មាត្រា ២០២ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៨១] មាត្រា ២៤៦ កថាខណ្ឌទី២ និងទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ភាគីនោះមិនស្របច្បាប់ អាចបណ្តាលមកពីការបញ្ជូនដីកាកោះទៅភាគីត្រូវបានធ្វើឡើងតាមរយៈមេឃុំ ចៅសង្កាត់ នគរបាល កងរាជអាវុធហត្ថ ជាអាទិ៍។

**គ.បុគ្គលដែលទទួលការបញ្ជូន ជាបុគ្គលដែលគ្មានសមត្ថភាពក្នុងការទទួល**

ការបញ្ជូនដីកាកោះហៅដោយមិនស្របច្បាប់ ដោយសារជនដែលទទួលការបញ្ជូនជាបុគ្គលដែលគ្មានសមត្ថភាពក្នុងការទទួលការបញ្ជូន មានន័យថា ការបញ្ជូននេះអាចជាការបញ្ជូនតាមរយៈការបញ្ជូនបង្គ្រប់កិច្ច ឬការបញ្ជូនដោយទុកចោល ទៅដល់អ្នកនៅជាមួយ ឬកូនរបស់ភាគីដែលត្រូវទទួលការបញ្ជូននោះ។ ហើយបុគ្គលទាំងនោះអាចជាជនដែលអសមត្ថភាពក្នុងការធ្វើបណ្តឹងមានដូចជា៖ អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ។ ពីព្រោះបុគ្គលទាំងនេះ គឺជាបុគ្គលដែលមិនមានការយល់ដឹង ឬមានការយល់ដឹងមិនគ្រប់គ្រាន់ដោយសារសតិបញ្ញាស្មារតី ដែលជាហេតុនាំឱ្យបុគ្គលទាំងនេះមិនអាចយល់ដឹងអំពីអត្ថន័យនៃឯកសារដែលបានទទួលដីកាកោះហៅ ឬ មិនអាចនាំយកដីកាកោះហៅនោះ ប្រគល់ទៅឱ្យភាគីដែលត្រូវទទួលការកោះហៅនោះឡើយ ជាហេតុនាំឱ្យដីកាកោះហៅដែលត្រូវបានបញ្ជូននោះ ពុំមានភាពស្របច្បាប់ឡើយ។ ដូច្នេះ តុលាការមិនអាចចេញសាលក្រមកំបាំងមុខលើកទី២ បានទេ ព្រោះនេះមិនមែនជាកំហុសរបស់ភាគីនោះទេ ហេតុនេះតុលាការត្រូវពន្យារកាលបរិច្ឆេទនៃនីតិវិធី។

**២.៤.១.២.ភាគីដែលមិនបានបង្ហាញខ្លួន ដោយមានមូលហេតុដែលមិនអាចជៀសវាងបាន**

នៅពេលដែលភាគីបានទទួលនូវដីកាកោះហៅដោយត្រឹមត្រូវស្របតាមច្បាប់ ប៉ុន្តែ ភាគីនោះមិនបានបង្ហាញខ្លួនដោយមានមូលហេតុដែលអាចទទួលស្គាល់ថាពិតជាមិនអាចបង្ហាញខ្លួនបានពិតមែន ដោយសារគ្រោះមហន្តរាយធម្មជាតិ (រញ្ជួយដី ឬទឹកជំនន់ជាដើម) ឬ កាលៈទេសៈផ្សេងទៀតដែលមិនអាចជៀសវាងបាន ដូចជាឪពុកម្តាយ ឬ សាច់ញាតិជួបគ្រោះថ្នាក់ធ្ងន់ធ្ងរដែលប៉ះពាល់ដល់ជីវិត ឬ បាត់បង់ជីវិតជាអាទិ៍។ ដែលជាហេតុមិនអាចជៀសវាងបាន ដោយហេតុការណ៍នេះបានកើតឡើងក្រៅឆន្ទៈរបស់ភាគី[៤២]។ ក្នុងករណីនេះ តុលាការមិនអាចចេញនូវសាលក្រមកំបាំងមុខលើកទី២ បានឡើយ ទោះបីជាភាគីនោះមិនបានចូលបង្ហាញខ្លួនក៏ដោយ ក៏ព្រោះតែហេតុការណ៍នោះបានកើតឡើងដោយមិនអាចជៀសវាងបាន ឬ យើងហៅថាព្រឹត្តិការណ៍ដែលកើតឡើងក្រៅឆន្ទៈរបស់ភាគី។

**២.៤.១.៣.បណ្តឹងមិនស្របច្បាប់**

បណ្តឹងមិនស្របច្បាប់ គឺជាបណ្តឹងមួយដែលធ្វើឡើងមិនស្របទៅតាមទម្រង់ច្បាប់ដែលបានកំណត់។ ហើយបណ្តឹងមិនស្របច្បាប់នោះអាចធ្វើឡើងដោយ៖

- ការដាក់ពាក្យបណ្តឹងទាស់ ទៅកាន់តុលាការដែលគ្មានសមត្ថកិច្ចផ្តាច់មុខ ក្នុងការទទួលបណ្តឹងទាស់។

[៤២] មាត្រា ២០២ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

មានន័យថា តុលាការដែលមានសមត្ថកិច្ចផ្ដាច់មុខ ចំពោះបណ្ដឹងទាស់ គឺជាតុលាការដែលបានចេញសាលក្រមកំបាំងមុខ[៨៣]។

- ភាគីដែលបានធ្វើបណ្ដឹង ជាភាគីដែលខ្វះសមត្ថភាពក្នុងការធ្វើបណ្ដឹង
- បុគ្គលដែលជាអ្នកតំណាងចំពោះភាគីដែលអសមត្ថភាពក្នុងការធ្វើបណ្ដឹង ខ្វះនូវសិទ្ធិតំណាង
- ពាក្យបណ្ដឹងទាស់ ធ្វើឡើងមិនមានលក្ខណៈគ្រប់គ្រាន់តាមទម្រង់ដែលច្បាប់បានកំណត់[៨៤]

មូលហេតុដែលបានលើកខាងឡើងនេះ ជាហេតុធ្វើឱ្យបណ្ដឹងទាស់ដែលបានធ្វើឡើងមានលក្ខណៈមិនស្របច្បាប់ ដែលករណីនេះតុលាការមិនអាចចេញនូវសាលក្រមកំបាំងមុខលើកទី២ បានទេ។ បានសេចក្ដីថា នៅពេលដែលបណ្ដឹងទាស់ធ្វើឡើងដោយមិនស្របច្បាប់ ជាហេតុនាំឱ្យតុលាការមិនអាចចេញនូវសេចក្ដីសម្រេចច្រានចោលបណ្ដឹងទាស់នោះ ដោយសាលក្រមកំបាំងមុខលើកទី២ បានឡើយ។

**២.៤.១.៤.ការមិនបានជូនដំណឹងអំពីខ្លឹមសារនៃសេចក្ដីថ្លែងការណ៍របស់ដើមចោទទៅចុងចម្លើយ**

ការមិនបានជូនដំណឹងអំពីខ្លឹមសារនៃសេចក្ដីថ្លែងការណ៍របស់ដើមចោទ ទៅចុងចម្លើយនេះ មានន័យថា នៅពេលដែលខ្លឹមសារនៃសេចក្ដីថ្លែងការណ៍ ដែលដើមចោទបានធ្វើនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដែលចុងចម្លើយមិនបានបង្ហាញខ្លួន មិនត្រូវបានជូនដំណឹងទៅចុងចម្លើយមុនកាលបរិច្ឆេទនោះទេ ក៏តុលាការមិនអាចចេញសាលក្រមកំបាំងមុខលើកទី២ បានឡើយ[៨៥]។ តាមរយៈសេចក្ដីនេះ ប្រសិនបើតុលាការចេញសាលក្រមកំបាំងមុខ ដោយចាត់ទុកថាចុងចម្លើយបានសារភាពអំពីសេចក្ដីថ្លែងការណ៍របស់ដើមចោទនៅកាលបរិច្ឆេទនោះ ទៅចំពោះចុងចម្លើយ គឺដូចជាការវាយឆ្មក់មួយដែរ ហេតុនេះហើយ ដើម្បីជៀសវាងនូវការវាយឆ្មក់នេះ មិនអនុញ្ញាតឱ្យតុលាការចេញសាលក្រមកំបាំងមុខទេ។ **ឧទាហរណ៍**៖ ចំពោះបណ្ដឹង ដែលចំណុចនីមួយៗដែលត្រូវសរសេរក្នុងពាក្យបណ្ដឹងគ្មានភាពស៊ីសង្វាក់គ្នា ទោះបីជាដើមចោទអះអាងអង្គហេតុដែលមិនត្រូវបានសរសេរនៅក្នុងឯកសារត្រៀម នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដែលដើមចោទបានចូលរួម តែចុងចម្លើយមិនបានបង្ហាញខ្លួន ហើយបណ្ដឹងនេះមានភាពស៊ីសង្វាក់គ្នាវិញ ដោយសារការអះអាងអង្គហេតុថ្មីនោះក៏ដោយ ក៏តុលាការមិនអាចចេញសាលក្រមកំបាំងមុខ ដែលទទួលស្គាល់ការទាមទាររបស់ដើមចោទឡើយ ដោយសារការដែលដើមចោទអះអាងអង្គហេតុនោះ មិនត្រូវបានជូនដំណឹងជាមុនទៅចុងចម្លើយ។ ក្នុងករណីនេះ ដោយសារបណ្ដឹងរបស់ដើមចោទមានភាពស៊ីសង្វាក់គ្នាវិញ ដោយការអះអាង

[៨៣] មាត្រា២០៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៨៤] មាត្រា២០៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៨៥] មាត្រា ២០២ ចំណុច ឃ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

អង្គហេតុថ្មី តុលាការមិនអាចចេញសាលក្រមដែលច្រានចោលការទាមទារបានឡើយ ហេតុដូច្នេះ តុលាការត្រូវបន្តនីតិវិធីនៃការវិនិច្ឆ័យ។

សរុបមក តុលាការមិនអាចចេញនូវសាលក្រមកំបាំងមុខលើកទី ២ បានឡើយ ប្រសិនបើ ករណីដែលភាគីមិនបានបង្ហាញខ្លួនដោយសារមូលហេតុណាមួយនៅក្នុងចំណោមមូលហេតុទាំង ០៤(បួន) ចំណុចដែលមានខ្លឹមសារដូចបានធ្វើការបកស្រាយខាងលើបានកើតមានឡើង។ ដោយសារមូលហេតុមិនបានបង្ហាញខ្លួនបានមិនមែនជាកំហុសរបស់ភាគី ជាមូលហេតុដែលមិនអាចជៀសវាងបានក្រៅឆន្ទៈរបស់ភាគី ជាពិសេសដោយសារតែក្នុងក្រមនីតិវិធីរដ្ឋប្បវេណី គោរពនូវគោលការណ៍ចំពោះមុខ ដោយបានកំណត់ថា តុលាការមិនអាចជំនុំជម្រះក្តីដោយមិនបានធ្វើការសាកសួរ ឬមិនបានកោះហៅភាគីឡើយ។ ទោះបីជាក្នុងករណីណាក៏ដោយ តុលាការត្រូវគោរពនូវគោលការណ៍ចំពោះមុខ។

បន្ថែមលើសពីនេះ ទោះបីជាក្នុងករណីដែលអ្នកធ្វើបណ្តឹងទាស់ មិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទដែលតុលាការកំណត់ក៏ដោយ ប្រសិនបើយល់ឃើញថាអំឡុងពេលរវាងកាលបរិច្ឆេទ និង ពេលដែលបានកោះហៅនោះខ្លីពេក ឬ យល់ឃើញថាភាគីមិនអាចបង្ហាញខ្លួនដោយគ្មានកំហុសទេ តុលាការអាចពន្យារពេលកាលបរិច្ឆេទ ហើយកំណត់នូវកាលបរិច្ឆេទថ្មី ដោយមិនចេញសាលក្រមកំបាំងមុខលើកទី២ ដើម្បីធ្វើការវិនិច្ឆ័យបន្តទៀត[៨៦]។ ចំពោះការពន្យារកាលបរិច្ឆេទនេះ គឺមានគោលបំណងទុកឱកាសសមរម្យឱ្យភាគីមានលទ្ធភាពចូលមកបង្ហាញខ្លួនតាមកាលបរិច្ឆេទបានដើម្បីស្របតាមគោលការណ៍ចំពោះមុខ[៨៧]។

### ២.៤.២.ការហាមឃាត់ក្នុងការធ្វើបណ្តឹងទាស់ ចំពោះសាលក្រមកំបាំងមុខលើកទី២

ចំពោះករណីហាមឃាត់នេះ កើតមានឡើងក្រោយពីតុលាការបានចេញសាលក្រមកំបាំងមុខលើកទី ២ ដោយសារតែភាគីនៃបណ្តឹងទាស់មិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទដំបូងនៃនីតិវិធីដែលត្រូវចាប់ផ្តើមឡើងវិញ ហើយចំពោះការអវត្តមានរបស់ភាគីនៃបណ្តឹងទាស់នេះទៀតសោត ដោយពុំមានមូលហេតុច្បាស់លាស់ដែលអាចធ្វើឱ្យតុលាការជឿថាភាគីនោះ មានឆន្ទៈក្នុងការធ្វើទៅតាមនីតិវិធីនៃបណ្តឹងទេ តុលាការនឹងត្រូវច្រានចោលបណ្តឹងទាស់ដោយសាលក្រមកំបាំងមុខលើកទី ២ ។ សាលក្រមកំបាំងមុខលើកទី ២ មិនអនុញ្ញាតឱ្យប្តឹងទាស់បានទៀតទេ[៨៨] ប្រសិនបើការមិនបង្ហាញខ្លួនរបស់ភាគីនៃបណ្តឹងទាស់នោះ មិនមានមូលហេតុច្បាស់លាស់ណាមួយដែលអាចឱ្យតុលាការជឿបានថា ការដែលមិនបានបង្ហាញខ្លួននៅក្នុងកាលបរិច្ឆេទដំបូងនោះ ព្រោះការមិនទទួលបានការកោះហៅស្របច្បាប់ មិនបង្ហាញខ្លួនដោយសារគ្រោះមហន្តរាយធម្មជាតិ ឬកាលៈទេសៈផ្សេង

[៨៦] មាត្រា ២០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៨៧] មាត្រា ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៨៨] មាត្រា ២០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ទៀត ឬ ការមិនបានទទួលនូវខ្លឹមសារនៃសេចក្តីថ្លែងការណ៍របស់ដើមចោទ នៃកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់នោះទេ ភាគីដែលត្រូវបានតុលាការសម្រេចសេចក្តីដោយសាលក្រមកំបាំងមុខលើកទី២នោះ គឺពុំអាចធ្វើបណ្តឹងទាស់ ចំពោះសាលក្រមកំបាំងមុខលើកទី២នេះ បានទៀតទេ។ នេះគឺជាបទដ្ឋានដែលមានគោលបំណងការពារកុំឱ្យមានការអវត្តមាន ហើយដាក់បណ្តឹងទាស់ជាបន្តបន្ទាប់ដើម្បីបន្លាយនីតិវិធី។ ប៉ុន្តែប្រសិនបើ ភាគីនោះបង្ហាញខ្លួននៅកាលបរិច្ឆេទដំបូងហើយអវត្តមាននៅកាលបរិច្ឆេទក្រោយទៀត ក្នុងករណីនេះ តុលាការមិនអាចចេញសាលក្រមកំបាំងមុខលើកទី ២ ទេ គឺចេញសាលក្រមកំបាំងមុខធម្មតា ដូចនេះបញ្ញត្តិនៃកថាខណ្ឌទី២ នៃមាត្រា២១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មិនត្រូវយកមកអនុវត្តឡើយ។

ក្រោយពីបានសិក្សាស្វែងយល់ និង បន្ទាប់ពីបានធ្វើការអត្ថាធិប្បាយតាំងពីជំពូកទី១ " សញ្ញាណទូទៅនៃបណ្តឹងទាស់ " និងជំពូកទី២ " ចំណាត់ការលើនីតិវិធីលើបណ្តឹងទាស់ " រួចហើយ យើងឃើញថាតថភាពនៃការអនុវត្តនូវក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា និងការអនុវត្តជាក់ស្តែងពីសំណាក់អ្នកវិជ្ជាជីវៈរួមទាំងប្រជាពលរដ្ឋ នៅពេលដែលបានពឹងពាក់តុលាការជួយដោះស្រាយវិវាទតាមផ្លូវច្បាប់ យើងសម្គាល់ឃើញថាមានភាពមិនប្រក្រតីមួយចំនួនដែលបានចោទជាបញ្ហាបានកើតឡើង និងមានភាពស្មុគស្មាញបង្កឱ្យកើតមាននូវបញ្ហាប្រឈមជាច្រើនទៅតាមស្ថានភាពជាក់ស្តែងនៃរឿងក្តីនីមួយៗ។ ភាពអវិជ្ជមាននេះ ជាមូលហេតុដែលគួរលើកយកមកពិចារណាដើម្បីរកដំណោះស្រាយសមស្របមួយក្នុងការអនុវត្តច្បាប់ឱ្យមានភាពល្អប្រសើរ និងត្រឹមត្រូវទៅតាមច្បាប់កំណត់។ ខាងក្រោមនេះគឺជាចំណុចដែលយើងនឹងសិក្សាស្វែងយល់នូវភាពមិនប្រក្រតីទាំងនោះដើម្បីកំណត់ដឹងអំពីបញ្ហាប្រឈម និងចាត់នូវវិធានការដោះស្រាយឱ្យបានទាន់ពេលវេលា ដើម្បីធានាបាននូវភាពយុត្តិធម៌តាមគោលការណ៍ច្បាប់។

# ជំពូកទី៣

# បញ្ហាប្រឈម និង ដំណោះស្រាយ

# ជំពូកទី៣
# បញ្ហាប្រឈម និង ដំណោះស្រាយ

## ៣.១.បញ្ហាប្រឈម

បញ្ហាប្រឈមក្នុងទីនេះ សំដៅដល់គ្រឿងរារាំង ឬ ផលរំខានដល់ការអនុវត្តនូវនីតិវិធីនៃការជំនុំជម្រះក្តីតាមផ្លូវតុលាការ ដែលបង្កធ្វើឱ្យកើតមាននូវបណ្តឹងទាស់ ដែលបានធ្វើឡើងប្រឆាំងនឹងសេចក្តីសម្រេចកំបាំងមុខរបស់តុលាការ ឬ ធ្វើឱ្យដំណើរការនីតិវិធីនៃបណ្តឹងទាស់នោះ មិនអាចប្រព្រឹត្តិទៅដោយរលូន។ ដោយបញ្ហាប្រឈមទាំងនោះ ត្រូវលើកយកមកពិចារណា រួមមាន៖ ភាពខ្វះចន្លោះនៃច្បាប់ (៣.១.១) ការយល់ដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋនៅមានកម្រិត(៣.១.២) ការកោះហៅមិនស្របច្បាប់ (៣.១.៣) អវត្តមានរបស់គូភាគី (៣.១.៤) និងការយឺតយ៉ាវក្នុងការជម្រះក្តីលើបណ្តឹងទាស់ (៣.១.៥) ព្រមទាំងការផុតរយៈពេលនៃការដាក់ពាក្យបណ្តឹងទាស់ (៣.១.៦)។ ដើម្បីស្វែងយល់ឱ្យបានកាន់តែច្បាស់លាស់អំពីបញ្ហាប្រឈមទាំងនេះ យើងនឹងសិក្សាលម្អិតលើបញ្ហានេះទៅតាមចំណុចនីមួយៗ ជាបន្តបន្ទាប់ដូចតទៅ៖

### ៣.១.១.ភាពខ្វះចន្លោះនៃច្បាប់

យោងតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភាបានអនុម័តនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៣ និងត្រូវបានប្រកាសអនុវត្តឱ្យប្រើប្រាស់ទូទាំងប្រទេសនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧។

ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ នៃព្រះរាជាណាចក្រកម្ពុជា មានចំនួន ៥៨៨មាត្រា និងមាន៩គន្ថី៖

- គន្ថីទី១: បទប្បញ្ញត្តិទូទៅ និងមាន ៥ ជំពូក
- គន្ថីទី២: នីតិវិធីនៃការជម្រះលើកទី១ និងមាន ៩ ជំពូក
- គន្ថីទី៣: បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និងមាន ៤ ជំពូក
- គន្ថីទី៤: ការជំនុំជម្រះសាជាថ្មី និងមានជំពូកទោល
- គន្ថីទី៥: នីតិវិធីដាសតឿន និងមានជំពូកទោល
- គន្ថីទី៦: ការអនុវត្តដោយបង្ខំ និងមាន ៤ ជំពូក
- គន្ថីទី៧: ការចាត់ចែងរក្សាការពារ និងមាន ៣ ជំពូក
- គន្ថីទី៨: អន្តរបញ្ញត្តិ និងមានជំពូកទោល
- គន្ថីទី៩: អវសានប្បញ្ញត្តិ និងមានជំពូកទោល

ចំពោះបណ្តឹងទាស់ និងសាលក្រមដែលជាកម្មវត្ថុក្នុងការបណ្តឹងទាស់ មានបញ្ញត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីត្រង់គន្ថីទី២ ជំពូកទី ៥ ផ្នែកទី៥ ដែលមានចាប់ពីមាត្រា ២០០ ដល់ មាត្រា ២១២ នៃក្រមនេះ។ ប៉ុន្តែ

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនេះដដែល បទប្បញ្ញត្តិទាក់ទងនឹងដំណើរការនីតិវិធី ដែលអាចធ្វើឱ្យបណ្តឹងទាស់ប្រព្រឹត្តិទៅបានដោយស្របច្បាប់នោះ នៅមានភាពខ្វះចន្លោះមិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយទៅលើផ្នែកខ្លះដែលពុំអាចធ្វើឱ្យបណ្តឹងទាស់មានដំណើរការទៅបានរលូនទេ ដោយភាពខ្វះចន្លោះក្នុងក្រមនេះ រួមមានដូចជា៖

**ទី១. បទបញ្ញត្តិដែលពុំមានចែងនៅក្នុងក្រម**

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ពុំមានបទបញ្ញត្តិស្តីអំពីការចូលរួមអន្តរាគមន៍ពីតុលាការ ដើម្បីជួយដល់ភាគី ទៅលើការស្រាវជ្រាវស្វែងរកអាសយដ្ឋានរបស់ភាគីម្ខាងទៀត ដោយការចេញលិខិតបទដ្ឋានគតិយុត្តិ ឬលិខិតអនុញ្ញាតណាមួយឱ្យប្រើប្រាស់ក្នុងការស្វែងរកអាសយដ្ឋានោះ ដើម្បីបំពេញបន្ថែមលើមាត្រា៩២ នៃក្រមនេះដដែលនោះទេ។

**ទី២.បទបញ្ញត្តិដែលមានលក្ខណមិនទាន់គ្រប់ជ្រុងជ្រោយ(បទបញ្ញត្តិនៅក្នុងគន្លីទី២)**

- បទបញ្ញត្តិស្តីអំពីការពិនិត្យបណ្តឹង (មាត្រា៧៨ កថាខណ្ឌទី១ វាក្យខណ្ឌទី១) និងបទបញ្ញត្តិដែលស្តីអំពីការពិនិត្យ និងបញ្ជូនពាក្យបណ្តឹងទាស់ (មាត្រា២០៦ កថាខណ្ឌទី១) មានលក្ខណពុំទាន់ច្បាស់លាស់នៅឡើយចំពោះការកំណត់អំឡុងពេលសមរម្យ ដែលបង្គាប់ឱ្យភាគីធ្វើការកែតម្រូវចំណុចខ្វះខាតចំពោះពាក្យបណ្តឹងដោយមិនបានបញ្ជាក់ថាមានរយៈប៉ុន្មានថ្ងៃឱ្យប្រាកដនោះទេ។ ដូច្នេះ ទាមទារឱ្យមាត្រានេះ មានការកំណត់ពេលវេលាឱ្យបានច្បាស់លាស់ ដើម្បីជៀសវាងការកំណត់ពេលវេលាទៅតាមការនឹកឃើញរបស់តុលាការ ដែលមិនបង្កលក្ខណងាយស្រួលដល់ភាគី។

- បទបញ្ញត្តិស្តីអំពីការកំណត់កាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា១១៣) និង ការទាញហេតុផ្ទាល់ដោយផ្ទាល់មាត់ (មាត្រា១១៥) ពុំបានធ្វើការកំណត់កាលបរិច្ឆេទឱ្យបានច្បាស់លាស់ក្នុងអំឡុងពេលប៉ុន្មាននោះទេ។ ហេតុនេះហើយ អាចធ្វើឱ្យការកំណត់ពេលវេលារបស់តុលាការ មានលក្ខណៈមិនច្បាស់លាស់ អាចថាលឿនពេក ឬយូរពេក ដែលធ្វើឱ្យភាគីមិនអាចត្រៀមខ្លួនឱ្យបានទាន់ពេលវេលា ឬធ្វើឱ្យភាគីបាត់បង់នូវជំនឿទុកចិត្តលើតុលាការ រហូតដល់លែងចង់បន្តនីតិវិធី។

- បទបញ្ញត្តិស្តីពីការបញ្ជូន (មាត្រា ២៤៦ ដល់មាត្រា ២៥៧) ពុំបានចែងអំពីការបញ្ជូនពាក្យបណ្តឹង និងដីកាកោះទៅភាគីដែលអាចធ្វើបានតាមរយៈការជូនដំណឹងសមរម្យ (ការកោះហៅតាមទូរស័ព្ទ ផ្ញើតាមតេលេក្រាម ឬប៉ុស្តិ៍ប្រៃសណីយ៍ជាដើម) និងការទទួលស្គាល់នូវការបញ្ជូនដីកាកោះទៅភាគី ត្រូវបានធ្វើឡើងតាមរយៈមេឃុំ ចៅសង្កាត់ នគរបាល កងរាជអាវុធហត្ថ ជាអាទិ៍។

## ៣.១.២.ការយល់ដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋនៅមានកម្រិត

ជាការពិតណាស់ នៅក្នុងវិស័យច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ចំពោះការយល់ដឹងអំពីច្បាប់របស់ប្រជាពលរដ្ឋនៅមានកម្រិតនៅឡើយ។ ជាពិសេស នៅពេលមានវិវាទដែលត្រូវដោះស្រាយតាមប្រព័ន្ធតុលាការ

ភាគីនៃរឿងក្តីនោះ គឺមិនដឹងថាត្រូវសរសេរពាក្យបណ្តឹងដាក់ទៅកាន់តុលាការឱ្យបានត្រឹមត្រូវតាមច្បាប់ដោយរបៀបណា ឬភាគីដែលត្រូវគេប្តឹងនោះ ក៏មិនដឹងថាខ្លួនមានសិទ្ធិឆ្លើយតបទៅនឹងបណ្តឹងនោះតាមវិធីណា ឬនៅពេលចូលរួមនៅក្នុងនីតិវិធីរបស់តុលាការហើយ មិនចេះធ្វើសេចក្តីថ្លែងការណ៍ និងមិនយល់អំពីការកំណត់ចំណុចវិវាទរបស់តុលាការជាដើម។ តួយ៉ាងដូចជា បណ្តឹងទាស់ ក្រោយពីបានទទួលសាលក្រមកំបាំងមុខ ភាគីនោះត្រូវបានច្បាប់បើកសិទ្ធិឱ្យធ្វើបណ្តឹងទាស់បានក្នុងអំឡុងពេល០២ (ពីរ) សប្តាហ៍ ចំពោះសេចក្តីសម្រេចកំបាំងមុខនោះ ប៉ុន្តែ ភាគីដែលមានសិទ្ធិធ្វើបណ្តឹងទាស់ មិនដឹងថាត្រូវសរសេរពាក្យបណ្តឹងទាស់នោះ ក្នុងទម្រង់បែបណាដើម្បីឱ្យបានត្រឹមត្រូវតាមច្បាប់ ដែលអាចឱ្យតុលាការទទួលស្គាល់នោះឡើយ ឬ មិនមានការយល់ដឹងអំពីអំឡុងពេលដែលអាចធ្វើការប្តឹងទាស់ និងដំណើរការនីតិវិធីនៃការជំនុំជម្រះក្តីលើបណ្តឹងទាស់ដែលអាចនាំឱ្យភាគីនោះថ្លោះសិទ្ធិក្នុងការធ្វើប្តឹងទាស់ ឬអវត្តមាននៅក្នុងនីតិវិធីជម្រះក្តីលើបណ្តឹងទាស់ផងដែរ។

ម៉្យាងវិញទៀត នៅពេលដែលប្រជាពលរដ្ឋ ឬ ភាគីនៃរឿងក្តីពុំមានការយល់ដឹងអំពីលំហូរនីតិវិធីទាំងនោះទេ ជាហេតុនាំឱ្យតុលាការពិបាកក្នុងការដឹកនាំនីតិវិធីបានយ៉ាងរលូនណាស់។ ព្រោះកង្វះខាតការយល់ដឹងផ្នែកច្បាប់នេះអាចបង្ករធ្វើឱ្យមានការយឺតយ៉ាវក្នុងការអនុវត្តនីតិវិធីច្បាប់ ហើយភាគីដែលពុំមានការយល់ដឹងអំពីលំហូរនីតិវិធីនោះ ក៏មិនអាចឆ្លើយតបភ្លាមៗចំពោះការអះអាងរបស់ភាគីម្ខាងទៀត ឬ ដាក់ភស្តុតាងដើម្បីបញ្ជាក់ការអះអាងរបស់ខ្លួនបានដែរ។

ករណីនេះ អាចនឹងធ្វើឱ្យពួកគេបាត់បង់នូវសិទ្ធិណាមួយ នៅពេលកំពុងដំណើរការនីតិវិធីនោះ ដូចជាសិទ្ធិទាមទារឱ្យសាកសួរជាដើម ដែលជាសិទ្ធិទាមទារឱ្យមានការធានានូវឱកាសក្នុងការបញ្ចេញមតិយោបល់របស់ខ្លួន ដែលពាក់ព័ន្ធទៅនឹងបញ្ហាដែលត្រូវសម្រេចសេចក្តីដោយតុលាការនៅក្នុងបណ្តឹងរដ្ឋប្បវេណី ឬនិយាយបានយ៉ាងពិតប្រាកដថាបុគ្គលនោះ មិនអាចការពារផលប្រយោជន៍របស់ខ្លួនតាមបណ្តឹងបានឡើយ។ ប្រសិនបើពួកគេបាត់បង់នូវសិទ្ធិទាមទារឱ្យសាកសួរ ប្រាកដណាស់ថាពួកគេអាចប្រឈមនឹងការវិនិច្ឆ័យសម្រេចសេចក្តីកំបាំងមុខ ឬ បាត់បង់នូវផលប្រយោជន៍ណាមួយជាមិនខាន។

### ៣.១.៣.ការកោះហៅមិនស្របច្បាប់

យោងតាមគោលការណ៍ចំពោះមុខ ដែលមានបញ្ញត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ដែលតម្រូវឱ្យមានវត្តមានគូភាគីនៃរឿងក្តីនៅគ្រប់ដំណាក់កាលនៃនីតិវិធីរបស់តុលាការ[៨៥]។ ប៉ុន្តែប្រសិនបើច្បាប់អនុញ្ញាតឱ្យតុលាការអាចកោះហៅភាគីតែម្ខាងមកវិនិច្ឆ័យក្តីនៅក្នុងកាលបរិច្ឆេទ ឬ ទីកន្លែងដែលអវត្តមានភាគីម្ខាងទៀតនោះទំនុកចិត្តលើការវិនិច្ឆ័យក្តីអាចនឹងត្រូវបាត់បង់ ហេតុនេះហើយទើបការវិនិច្ឆ័យចាំបាច់ត្រូវបានធ្វើឡើងដោយ

[៨៥] មាត្រា៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

គោរពតាមគោលការណ៍ចំពោះមុខ ដែលតម្រូវឱ្យមានវត្តមានរបស់គូភាគីនៅក្នុងកាលបរិច្ឆេទនោះ និងចំពោះមុខគ្នា។ ដូច្នេះហើយ តម្រូវឱ្យតុលាការធ្វើការកោះហៅភាគីឱ្យចូលរួមក្នុងគ្រប់ដំណើរការនីតិវិធីរបស់តុលាការ ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែងចំពោះរឿងក្តីមួយចំនួន ភាគីមិនបានចូលរួមបង្ហាញខ្លួនក្នុងនីតិវិធីរបស់តុលាការទេ ពីព្រោះភាគីនោះមិនបានទទួលបានការកោះហៅ ឬបានទទួលដីកាកោះហៅដោយមិនស្របច្បាប់ ហើយត្រូវបានតុលាការសម្រេចសេចក្តីកំបាំងមុខនោះ ជាហេតុនាំឱ្យបណ្តឹងទាស់កើតមានឡើង។ ចំពោះបញ្ហាដែលភាគីពុំបានទទួលបានការកោះហៅ ឬ បានទទួលដីកាកោះហៅដោយមិនស្របច្បាប់នេះ អាចបណ្តាលមកពីតុលាការ ឬ មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន មិនបានអនុវត្តទៅតាមនីតិវិធីច្បាប់ដែលមានជាធរមាន ឬ មានការអនុវត្តផ្ទុយពីអ្វីដែលច្បាប់បានកំណត់។

- **ឧទាហរណ៍**៖ ពាក្យបណ្តឹងទាស់លេខ៨៣ របស់ក្រុមហ៊ុនមេធាវី លីហ្គលសៀល[៥០] ដែលដាក់ទៅកាន់សាលាដំបូងរាជធានីភ្នំពេញ និងបានប្រថាប់ត្រាចូលនៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣ ដែលទាមទារឱ្យលុប ឬ បដិសេធចោលនៅសាលក្រមកំបាំងមុខរបស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានដាក់នៅក្នុងឧបសម្ព័ន្ធនៃអត្ថបទសារណានេះស្រាប។ តាមរយៈពាក្យបណ្តឹងទាស់នេះ ខ្ញុំសុំលើកយកនៅត្រង់តែចំណុចមូលហេតុនៃបណ្តឹងទាស់យកមកបញ្ជាក់តែប៉ុណ្ណោះ ដែលខ្លឹមសារនៃមូលហេតុនៃការប្តឹងទាស់នោះបានលើកឡើងថា៖

តុលាការអនុវត្តផ្ទុយបញ្ញត្តិមាត្រា ២៤៦ (ស្តីពីគោលការណ៍នៃការបញ្ជូន) នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដោយហេតុថា ជាគោលការណ៍ កិច្ចការបញ្ជូនត្រូវតែធ្វើឡើងដោយក្រឡាបញ្ជី និងប្រតិបត្តិដោយបុគ្គលិកប្រៃសណីយ៍ អាជ្ញាសាលា ឬ ក្រឡាបញ្ជី។ ដោយនៅក្នុងពាក្យបណ្តឹងនេះដដែល បានលើកឡើងថា៖ ក្នុងករណីនេះ ខ្ញុំបាទ(មេធាវី) និងកូនក្តីរបស់ខ្ញុំបាទមិនបានទទួលលិខិតអញ្ជើញមេធាវី ឬ ដីកាកោះដើម្បីទាញហេតុផលផ្ទាល់មាត់ពីតុលាការ តាមរយៈការបញ្ជូនតាមបញ្ញត្តិមាត្រា២៤៦ ឡើយ។ ក្នុងករណីនេះតុលាការបានចេញសាលក្រមកំបាំងមុខ ដែលអនុវត្តផ្ទុយពីបញ្ញត្តិមាត្រា២០២ នៃក្រមនីតីវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។ តាមរយៈករណីនេះ សបញ្ជាក់ឱ្យឃើញថាបញ្ហាប្រឈមនៃការអវត្តមានរបស់ភាគីនេះកើតមានឡើងព្រោះពុំបានទទួលបានការកោះហៅ ឬ ទទួលបានដីកាកោះហៅដោយមិនស្របច្បាប់ក៏ពិតមែន។

### ៣.១.៤.អវត្តមានរបស់គូភាគី

ក្រៅពីការអវត្តមានរបស់ភាគីនៅក្នុងដំណើរការនីតិវិធីរបស់តុលារ ដោយមូលហេតុមិនបានទទួលដីកាកោះហៅ ឬ ទទួលបានការកោះហៅដោយមិនស្របច្បាប់ដូចបានលើកបញ្ជាក់ខាងលើ ការមិនព្រមចូលខ្លួនរបស់ភាគីខ្លួនឯងផ្ទាល់ ក៏ជាបញ្ហាប្រឈមមួយ ដែលនឹងត្រូវលើកយកមកពិចារណាផងដែរ។ តាមរយៈការចុះ

[៥០] ឧបសម្ព័ន្ធទី១

ស្រាវជ្រាវឯកសារនៅសាលាដំបូងរាជធានីភ្នំពេញ និងជួបសម្ភាសន៍ផ្ទាល់ជាមួយមន្ត្រីអនុវត្តច្បាប់ដែលបានធ្វើការនៅសាលាដំបូងនោះ គឺលោកស្រី **យី សុខរួច** ជាចៅក្រម និងមន្ត្រីក្រឡាបញ្ជី គឺកញ្ញា **អៀង គឹមណម** ខ្ញុំបានប្រទះជួបនឹងករណីជាក់ស្តែងមួយចំនួនដូចជា៖ នៅពេលដែលតុលាការបានធ្វើការបញ្ជូនដីកាកោះហៅត្រឹមត្រូវតាមច្បាប់កំណត់ហើយ បែរជាភាគីនៃវិវាទនោះមានចេតនាគេចវេះមិនព្រមទទួលដីកាកោះហៅ និងមានករណីមួយចំនួនទៀត ភាគីបានទទួលការកោះហៅដោយស្របច្បាប់ហើយ ប៉ុន្តែភាគីនោះ មិនព្រមចូលបង្ហាញខ្លួនទៅតាមការកោះហៅរបស់តុលាការនោះទេ ដោយមានចេតនាចង់អូសបន្លាយនីតិវិធី ធ្វើព្រងើយកន្តើយ ធ្វើមិនអើពើ មិនខ្វល់ខ្វាយចំពោះការកោះហៅរបស់តុលាការ។ មានរឿងក្តីខ្លះ ក្រោយពីភាគីនោះបានទទួលដីកាកោះហៅរួចហើយ បែរជាព្យាយាមរត់គេចខ្លួនទៅវិញ ដោយករណីនេះភាគច្រើនជារឿងបំណុល។ ចំពោះបញ្ហានេះទៀតសោត យើងសង្កេតឃើញថាកើតមានឡើងជាញឹកញាប់នៅក្នុងដំណើរការនីតិវិធីជម្រះក្តីរបស់តុលាការ **ឧទាហរណ៍៖** សាលក្រមលេខ ១៥៤៤ "វ" របស់សាលាដំបូងរាជធានីភ្នំពេញ[៩១] ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩ ដែលបានជម្រះក្តីលើសំណុំរឿងរដ្ឋប្បវេណីលេខ ១៤១៨ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ ដែលបានលើកឡើងនៅត្រង់ចំណុចការអះអាងរបស់ភាគីសហចុងចម្លើយថា៖ សហចុងចម្លើយឈ្មោះ **ច១** និងឈ្មោះ **ច២** បានទទួលដីកាកោះហៅឱ្យចូលសាលាដំបូងរាជធានីភ្នំពេញ ពីអ្នករត់ដីកាកោះប្រចាំសាលាដំបូងរាជធានីភ្នំពេញគ្រប់នីតិវិធីរួចហើយ ប៉ុន្តែសហចុងចម្លើយមិនចូលរួមតាមកំណត់របស់តុលាការ ដោយគ្មានមូលហេតុ។

ការលើកឡើងដោយសង្ខេបតាមរយៈឧទាហរណ៍ខាងលើ បានបង្ហាញឱ្យឃើញថា ភាគីនោះពិតជាមិនបានចូលបង្ហាញខ្លួននៅក្នុងនីតិវិធីរបស់តុលាការពិតមែន ទោះបីជាខ្លួនទទួលការកោះហៅដោយស្របច្បាប់រួចហើយក៏ដោយ។

### ៣.១.៥.ការយឺតយ៉ាវក្នុងការជម្រះក្តីលើបណ្តឹងទាស់

ការយឺតយ៉ាវក្នុងការជម្រះក្តីលើបណ្តឹងទាស់ អាចបណ្តាលមកពីមូលហេតុមួយចំនួនដូចជា៖

-តុលាការមានសមត្ថកិច្ចលើបណ្តឹងទាស់ មិនបានកំណត់ពេលសមរម្យឱ្យបានច្បាស់លាស់ ក្នុងការបង្គាប់ឱ្យកែតម្រូវនូវចំណុចខ្វះខាតនោះទេ នៅពេលពាក្យបណ្តឹងទាស់មានភាពមិនត្រឹមត្រូវទៅទម្រង់ច្បាប់ដែលបានកំណត់។

-នៅពេលដែលពាក្យបណ្តឹងទាស់ ត្រូវបានទទួលស្គាល់អំពីភាពត្រឹមត្រូវតាមទម្រង់នៃការកំណត់របស់ច្បាប់រួចហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទថ្មីក្នុងការវិនិច្ឆ័យបណ្តឹងទាស់ ត្រូវកំណត់ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្តឹងទាស់ត្រូវបានដាក់ទៅតុលាការ។ ប៉ុន្តែ តុលាការមានការយឺតយ៉ាវ

[៩១] ឧបសម្ព័ន្ធទី៤

ក្នុងការកំណត់ពេលវេលា ឬ មិនបានធ្វើការកំណត់ពេលវេលាឱ្យបានច្បាស់លាស់ក្នុងការវិនិច្ឆ័យបណ្តឹងទាស់ទេ ដោយហេតុថាខ្លួនមានសំណុំរឿងជាច្រើនទៀត ដែលត្រូវធ្វើចំណាត់ការនីតិវិធីបន្តភ្លាមៗ ហើយបានទុករឿងក្តីបណ្តឹងទាស់នេះចោលមួយឡែក ដោយពុំបានធ្វើសកម្មភាពអ្វីសោះឡើយ។

ម៉្យាងវិញទៀត សមត្ថភាពរបស់ចៅក្រមទទួលបន្ទុករឿងក្តី ក៏ជាបញ្ហាចោទមួយផងដែរ ដែលជាទូទៅច្រើនតែកើតមាននូវបញ្ហានេះឡើងចំពោះចៅក្រមដែលទើបតែចេញធ្វើការអនុវត្តផ្ទាល់ ពុំទាន់មានបទពិសោធន៍ច្រើននៅឡើយ ពោលគឺចៅក្រមដែលទើបតែបញ្ចប់កម្មសិក្សា ហើយក្លាយខ្លួនទៅជាចៅក្រមពេញសិទ្ធិ មានន័យថា ការវិនិច្ឆ័យសម្រេចសេចក្តីរបស់ចៅក្រមទាំងនោះ អាចនឹងមិនត្រឹមត្រូវ ឬ អាចនឹងមានការលម្អៀងទៅភាគីណាម្ខាងនៃភាគីវិវាទ ដោយសារតែស្ថានភាពនៃរឿងក្តីនោះ បានបង្ហាញរូបភាពឱ្យចៅក្រមដែលទទួលបន្ទុកយល់ឃើញបែបនោះ ព្រោះចៅក្រមដែលទទួលបន្ទុកមិនទាន់មានសមត្ថភាពគ្រប់គ្រាន់នៅក្នុងការវិនិច្ឆ័យសម្រេចសេចក្តីជាដើម។ ករណីនេះ ប្រសិនបើចៅក្រមទទួលបន្ទុករឿងក្តីបណ្តឹងទាស់ ជាចៅក្រមដែលទើបតែចេញធ្វើការអនុវត្តផ្ទាល់ ដែលពុំទាន់មានបទពិសោធន៍ច្រើននៅឡើយ ពោលគឺចៅក្រមដែលទើបតែបញ្ចប់កម្មសិក្សា ហើយក្លាយខ្លួនទៅជាចៅក្រមពេញសិទ្ធិនោះ ក៏ជាហេតុអាចធ្វើឱ្យការជម្រះក្តីលើបណ្តឹងទាស់មានការយឺតយ៉ាវផងដែរ។

### ៣.១.៦.ការផុតរយៈពេលនៃការដាក់ពាក្យបណ្តឹងទាស់

ជាគោលការណ៍បណ្តឹងទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនសាលក្រមកំបាំងមុខនោះ[៥២]។ មានន័យថា នៅពេលដែលភាគីនោះបានទទួលដំណឹងអំពីសាលក្រមកំបាំងមុខ ឬ បានទទួលការបញ្ជូនសាលក្រមកំបាំងមុខហើយ ភាគីអាចធ្វើបណ្តឹងទាស់ទៅតាមសិទ្ធិ និងកិច្ចនីតិវិធីដែលច្បាប់បានកំណត់។ ផ្ទុយទៅវិញ ប្រសិនបើភាគីព្រងើយកន្តើយ ធ្វើមិនអើពើ មិនខ្វល់ខ្វាយ ឬ មិនបញ្ចេញសកម្មភាពទៅតាមសិទ្ធិដែលខ្លួនមាននោះទេ ភាគីត្រូវទទួលខុសត្រូវដោយខ្លួនឯង ដោយហេតុថាខ្លួនបានលះបង់សិទ្ធិដែលខ្លួនមានតាមផ្លូវច្បាប់។ រីឯតុលាការនឹងបន្តអនុវត្តកិច្ចនីតិវិធីទៅតាមអង្គហេតុដែលមានជាក់ស្តែង និងភស្តុតាងដែលមានពិតនៅក្នុងបណ្តឹងតែប៉ុណ្ណោះ។ ក្នុងករណីនេះដដែល ប្រសិនបើភាគីបានទទួលការបញ្ជូនសាលក្រមកំបាំងមុខរួចហើយ បែរជាធ្វើមិនអើពើ មិនខ្វល់ខ្វាយ ឬ មិនបានធ្វើបណ្តឹងទាស់ក្នុងអំឡុងពេលដែលច្បាប់បានកំណត់ទេ ហើយទុកឱ្យអំឡុងពេលនោះកន្លងផុតទើបខ្លួនធ្វើបណ្តឹងទាស់ នោះមានន័យថា ភាគីនោះបានថ្លោះសិទ្ធិក្នុងការធ្វើបណ្តឹងទាស់ ឬ ផុតរយៈពេលនៃការដាក់ពាក្យបណ្តឹងទាស់ ហើយ

[៥២] មាត្រា២០៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

តុលាការនឹងលើកចោលនូវបណ្តឹងទាស់នោះ ដោយដីកាសម្រេច[៥៣] ដោយមូលហេតុពាក្យបណ្តឹងទាស់នោះ មិនត្រូវត្រឹមតាមច្បាប់។

**ឧទាហរណ៍** ៖ ភាគី A បានទទួលការបញ្ជូនសាលក្រមកំបាំងមុខនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ ហើយអំឡុងពេលដែលអាចធ្វើបណ្តឹងទាស់ គឺគិតចាប់តាំងពីថ្ងៃទទួល រហូតដល់ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ ប៉ុន្តែភាគី A មិនបានអើពើក្នុងការធ្វើបណ្តឹងទាស់ក្នុងអំឡុងពេលដែលកំណត់នោះទេ ប៉ុន្តែបែរជាខ្លួនចាប់ផ្តើមធ្វើនូវបណ្តឹងទាស់ នៅថ្ងៃទី២៩ ខែ មករា ឆ្នាំ២០១៨ នៅពេលដែលផុតអំឡុងពេលដែលច្បាប់កំណត់ទៅវិញ។

ការផុតរយៈពេលនៃការដាក់ពាក្យបណ្តឹងទាស់នេះ ក៏មានករណីខ្លះ អាចបណ្តាលមកពីភាគីនោះមិនស្គាល់ថាអ្វីទៅជាបណ្តឹងទាស់? ហើយចេះតែអូសបន្លាយពេលវេលាពីមួយថ្ងៃទៅមួយថ្ងៃ ពីព្រោះខ្លួនមិនមានការយល់ដឹងអំពីនីតិវិធីនៃការធ្វើបណ្តឹងទាស់ មិនដឹងថាខ្លួនត្រូវឆ្លើយតបទៅនឹងសាលក្រមកំបាំងមុខនោះតាមរយៈបណ្តឹងទាស់នេះតាមវិធីណា ឬ ទម្រាំស្វែងរកនូវមេធាវី ដែលខ្លួនអាចជឿទុកចិត្តបាននោះ អំឡុងពេលនៃការធ្វើបណ្តឹងទាស់អាចនឹងកន្លងផុត ដែលជាហេតុធ្វើឱ្យភាគីនោះថ្លោះសិទ្ធិក្នុងការប្តឹងទាស់ផងដែរ។ ព្រោះអំឡុងពេលដែលបានកំណត់នៅក្នុងមាត្រា២០៤ កថាខណ្ឌទី២ មិនអាចពន្យាបានឡើយ ប៉ុន្តែ ក្នុងករណីភាគីដែលមានសិទ្ធិប្តឹងទាស់ មិនបានធ្វើការប្តឹងទាស់ដោយមូលហេតុមិនជាកំហុសរបស់ខ្លួន តុលាការត្រូវពន្យារពេលនៃការប្តឹងទាស់នោះ ព្រមទាំងកំណត់នូវកាលបរិច្ឆេទថ្មី។

**ឧទាហរណ៍**៖ ចុងចម្លើយ A បានទទួលសាលក្រមកំបាំងមុខនៅថ្ងៃទី ០១ ខែមករា ឆ្នាំ២០២៣ ដោយមានសិទ្ធិប្តឹងទាស់រយៈពេល០២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃទទួលសាលក្រម។ ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៣ ជាថ្ងៃចុងក្រោយនៃសិទ្ធិប្តឹងទាស់ ភាគី A បានដាក់ពាក្យបណ្តឹងទាស់ទៅកាន់តុលាការ ប៉ុន្តែថ្ងៃនោះមានបាតុកម្ម ហើយបិទតុលាការ នាំឱ្យតុលាការមិនអាចទទួលពាក្យបណ្តឹងបាន ក្នុងករណីនេះ អំឡុងពេលនៃការប្តឹងទាស់ត្រូវពន្យារ។

## ៣.២.ដំណោះស្រាយ

ដើម្បីឱ្យការអនុវត្តនីតិវិធីរដ្ឋប្បវេណីមានប្រសិទ្ធភាព និងមានដំណើរការប្រកបដោយតម្លាភាព មានភាពងាយស្រួល ដែលប្រព្រឹត្តិទៅដោយរលូន និងឆាប់រហ័ស ត្រឹមត្រូវតាមគោលការណ៍ច្បាប់ដែលបានកំណត់ គឺត្រូវមាននូវដំណោះស្រាយចំពោះបញ្ហាប្រឈមដែលបានរៀបរាប់ខាងលើនេះ ដូចតទៅ៖

### ៣.២.១.ការបង្កើតលិខិតបទដ្ឋានគតិយុត្តិឱ្យបានច្រើន

ដើម្បីលើកកំពស់ និងពង្រឹងនូវជំនឿទុកចិត្តរបស់ភាគីនៃរឿងក្តី ព្រមទាំងប្រជាពលរដ្ឋចំពោះប្រព័ន្ធច្បាប់

[៥៣] មាត្រា២០៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ស្តីពីការដោះស្រាយបណ្តឹងរដ្ឋប្បវេណី និងដើម្បីធានារក្សាអនាគតិ ការពារសិទ្ធិសេរីភាព និងផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ និងផ្តល់យុត្តិធម៌ជូនប្រជាពលរដ្ឋទូទៅ ដែលបានពឹងពាក់តុលាការក្នុងការដោះស្រាយវិវាទរបស់ខ្លួនបាននោះ ការជំនុំជម្រះក្តីត្រូវប្រតិបត្តិដោយត្រឹមត្រូវតាមច្បាប់។ អាស្រ័យហេតុនេះ ទាមទារឱ្យស្ថាប័នរដ្ឋសភា រាជរដ្ឋាភិបាល និងក្រសួងយុត្តិធម៌ ព្រមទាំងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បង្កើតនូវលិខិតបទដ្ឋានគតិយុត្តិបន្ថែមទៀត ដើម្បីបំពេញបន្ថែមទៅលើភាពខ្វះចន្លោះដូចបានលើកឡើងនៅក្នុងបញ្ហាប្រឈមខាងលើ។ ការបង្កើតនូវលិខិតបទដ្ឋានគតិយុត្តិបន្ថែមទៀតនេះ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តដំណើរការនីតិវិធីជំនុំជម្រះក្តីរបស់តុលាការឱ្យមានភាពត្រឹមត្រូវ និងផ្តល់យុត្តិធម៌ជូនភាគីព្រមទាំងបង្កភាពងាយស្រួលដល់តុលាការ និងភាគីនៃរឿងក្តី ដែលសមស្របនឹងស្ថានភាពសង្គមបច្ចុប្បន្ននេះផងដែរ។

**៣.២.២.ការបង្កើតប្រព័ន្ធផ្សព្វផ្សាយច្បាប់ឱ្យបានទូលំទូលាយ**

ស្ថាប័នតុលាការ ឬ ស្ថាប័នដទៃទៀតដែលពាក់ព័ន្ធ គួរបង្កើតនូវប្រព័ន្ធផ្សព្វផ្សាយច្បាប់ឱ្យបានច្រើន ជាពិសេសច្បាប់ដែលទាក់ទងនឹងនីតិវិធីរបស់តុលាការ ដើម្បីបានជាចំណេះដឹងសម្រាប់ប្រជាពលរដ្ឋទូទៅ តាមរយៈមធ្យោបាយណាមួយដែលសមស្របទៅនឹងសង្គមបច្ចុប្បន្ន ដូចជាការផ្សព្វផ្សាយតាមរយៈទូរទស្សន៍ វិទ្យុ ការសែត ឬទស្សនាវដ្តីជាដើម។ ប្រសិនបើការផ្សព្វផ្សាយអាចប្រព្រឹត្តិធ្វើទៅតាមរយៈទូរទស្សន៍ បានគប្បីមានការផលិតជាវីដេអូអប់រំពន្យល់អំពីដំណើរការនីតិវិធីនៃការជំនុំជម្រះក្តីនៅតុលាការជាសាធារណៈ ដើម្បីឱ្យប្រជាពលរដ្ឋមានការយល់ដឹងបន្ថែមអំពីដំណើរការនីតិវិធីនៃការជំនុំជម្រះក្តីនៅស្ថាប័នតុលាការ ឬ បង្កើតជាវគ្គបណ្តុះបណ្តាលខ្លីៗ ឬ ធ្វើសិក្ខាសាលានៅតាមមូលដ្ឋានឱ្យបានច្រើន ដែលទាក់ទងនឹងការសរសេរពាក្យបណ្តឹង ព្រមទាំងលំហូរនៃនីតិវិធី។ មួយវិញទៀត បើភាគីណាមួយដែលមានវិវាទនៅតុលាការ ហើយខ្វះការយល់ដឹងអំពីច្បាប់ តុលាការគួរតែពន្យល់ណែនាំឱ្យភាគីនោះឱ្យមានការយល់ដឹងខ្លះៗ ស្តីអំពីលំហូរនីតិវិធីរបស់តុលាការ ឬណែនាំឱ្យភាគីនោះ ឱ្យស្វែងរកនូវអ្នកតំណាងដោយអាណត្តិ ពោលគឺមេធាវី ដើម្បីជួយការពារសិទ្ធិ ព្រមទាំងផលប្រយោជន៍របស់ខ្លួន។

**៣.២.៣.ការកោះហៅភាគីឱ្យស្របតាមនីតិវិធីច្បាប់**

ដើម្បីធានានូវសិទ្ធិទាមទារឱ្យសាកសួរ ឱ្យមានប្រសិទ្ធិភាព ការជម្រះក្តីត្រូវតែធ្វើឡើងដោយកោះហៅភាគីទាំងសងខាងឱ្យមកបង្ហាញខ្លួននៅកាលបរិច្ឆេទតែមួយ ហើយត្រូវឱ្យភាគីប្រឈមមុខដាក់គ្នាដោយផ្ទាល់។ ប្រសិនបើច្បាប់អនុញ្ញាតឱ្យតុលាការអាចកោះហៅភាគីតែម្ខាងមកវិនិច្ឆ័យក្តីនៅក្នុងកាលបរិច្ឆេទ ឬ ទីកន្លែងដែលអវត្តមានភាគីម្ខាងទៀត នោះទំនុកចិត្តលើការវិនិច្ឆ័យក្តីអាចនឹងត្រូវបាត់បង់ ហេតុនេះហើយទើបការវិនិច្ឆ័យចាំបាច់ត្រូវបានធ្វើឡើងដោយគោរពតាមគោលការណ៍ចំពោះមុខ ដែលតម្រូវឱ្យមានវត្តមានរបស់គូភាគីនៅក្នុងកាលបរិច្ឆេទនោះនិងចំពោះមុខគ្នា ហើយជជែកតតាំងគ្នាទៅវិញទៅមក។ ហេតុនេះហើយ ទាមទារឱ្យតុលាការ

ត្រូវតែធ្វើការជូនដំណឹងដែលពាក់ព័ន្ធនឹងកោះហៅភាគីជាចំបាច់។ ការកោះហៅភាគី ត្រូវធ្វើតាមរយៈការបញ្ជូន ដែលមានបញ្ញត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ព្រោះការបញ្ជូននេះ គឺជានីតិវិធីដ៏មានសារសំខាន់មួយដល់ដំណើរការក្នុងដោះស្រាយវិវាទរដ្ឋប្បវេណី ដែលអាចឱ្យភាគីទាំងសងខាង បានដឹងអំពីដំណើរការនៃរឿងក្តីនៅតុលាការ និងអាចចូលរួមតាមរយៈការកោះហៅនេះបានផងដែរ។ ដូច្នេះ មន្ត្រីដែលពាក់ព័ន្ធនឹងការបញ្ជូន ត្រូវអនុវត្តនីតិវិធីនៃការបញ្ជូនទៅតាមគោលការណ៍ច្បាប់មានជាធរមាន ព្រមទាំងប្រើប្រាស់វិធីនៃការបញ្ជូនដែលបញ្ញត្តិដោយច្បាប់ឱ្យអស់លទ្ធភាព។

ដើម្បីជៀសវាងការជំនុំជម្រះក្តីដោយមិនមានវត្តមានភាគីណាមួយ ដែលបណ្តាលមកពីការមិនទទួលការកោះហៅ ឬទទួលបានដីកាកោះហៅដោយមិនស្របច្បាប់ នោះមន្ត្រីអ្នកអនុវត្តការបញ្ជូន ត្រូវធ្វើការត្រួតពិនិត្យឯកសារដែលត្រូវបញ្ជូន ( ឈ្មោះរបស់ភាគី និងជនដែលពាក់ព័ន្ធ អាស័យដ្ឋានរបស់ភាគី ព្រមទាំងខ្លឹមសារដែលត្រូវបញ្ជូនជាដើម) ឱ្យបានច្បាស់លាស់មុននឹងធ្វើការបញ្ជូន ដើម្បីជៀសវាងការបញ្ជូន ដែលធ្វើឡើងដោយខុសអាសយដ្ឋាន។ ម៉្យាងទៀត នៅរាល់ឯកសារ ឬ ខ្លឹមសារនៃដីកាកោះហៅត្រូវរៀបចំ និងធ្វើការបញ្ជូនឱ្យសមស្របទៅតាមកាលវេលាដែលកំណត់ដោយច្បាប់ ដោយជៀសវាងការយឺតយ៉ាវដោយប្រការណាមួយ។ ចំពោះការបញ្ជូន មន្ត្រីដែលទទួលបន្ទុកប្រតិបត្តិការបញ្ជូន ត្រូវធានាថាឯកសារដែលត្រូវបញ្ជូននោះ បានប្រគល់ឱ្យជនដែលត្រូវទទួលនោះដោយត្រឹមត្រូវ ឬ ការបញ្ជូនដែលធ្វើឡើងដោយការបញ្ជូនដោយបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោល ត្រូវច្បាស់ថាបានប្រគល់ឯកសារដែលត្រូវបញ្ជូននោះទៅឱ្យអ្នកបម្រើ ឬ អ្នកផ្សេងទៀតដែលធ្វើការនៅទីនោះ ឬ អ្នកនៅជាមួយដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនោះបាន។ មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន ត្រូវជៀសវាងការបញ្ជូនដោយទុកចោលដោយគ្មានអ្នកទទួល ឬ មានអ្នកទទួលដែរ តែជននោះមិនមានការយល់អំពីខ្លឹមសារនៃការបញ្ជូន ឬមានការបដិសេធដោយមានហេតុផលច្បាស់លាស់នោះឡើយ។ ករណីដែលមន្ត្រីទទួលបន្ទុក បានប្រឹងប្រែងធ្វើការបញ្ជូនស្ទើរតែគ្រប់វិធីនៃការបញ្ជូនអស់ហើយ ឬ ប្រើប្រាស់ស្ទើរតែគ្រប់មធ្យោបាយក្នុងការបញ្ជូនប៉ុន្តែពុំទទួលបានផល នោះការបញ្ជូនតាមរយៈការផ្សាយជាសាធារណៈ អាចយកទៅលុបបំបាត់បាតុភូតអសកម្មទាំងនោះ ឱ្យមានភាពត្រឹមកម្រិតទាបបំផុតបាន។

**ឧទាហរណ៍៖** លិខិតជូនដំណឹងស្តីពីការបញ្ជូនតាមការផ្សាយជាសារណៈរបស់សាលាដំបូង ខេត្តបន្ទាយមានជ័យ ទៅចុងចម្លើយក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ០១ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១[៥៤] ឱ្យបានជ្រាបថា៖ សាលាដំបូងខេត្តបន្ទាយមានជ័យ បានសម្រេចធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ ដោយមូលហេតុថាការបញ្ជូនមិនអាចធ្វើបានឡើយ តាមមាត្រា ២៥១ ( ការបញ្ជូននៅកន្លែងជួបប្រទះ) និងមាត្រា ២៥២ (ការបញ្ជូន

[៥៤] ឧបសម្ព័ន្ធទី៣

បង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោល) នៃក្រមនីតិវិធីរដ្ឋប្បវេណី ចាំបាច់ដើម្បីជៀសវាងការយឺតយ៉ាវក្នុងដំណើរការនីតិវិធី តុលាការត្រូវធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ។ល។

ម៉្យាងទៀត ដើម្បីឱ្យការអនុវត្តនីតិវិធីបញ្ជូនទទួលបានប្រសិទ្ធិភាពកាន់តែខ្ពស់ ស្ថាប័នពាក់ព័ន្ធមានដូចជាក្រសួងយុត្តិធម៌ និងឧត្តមក្រុមប្រឹក្សាចៅក្រមជាដើម គួរតែបង្កើតនូវវគ្គបណ្តុះបណ្តាលបន្ថែមលើសមត្ថភាពរបស់មន្ត្រីដែលពាក់ព័ន្ធ ក្នុងករណីដែលៈ មន្ត្រីទទួលកិច្ចការបញ្ជូនខ្វះខាតបទពិសោធ ឬ ទើបតែទទួលបានតួនាទីជាអ្នកប្រតិបត្តិការបញ្ជូនថ្មីៗ ត្រូវតែទទួលការបណ្តុះបណ្តាលបំប៉នសមត្ថភាពបន្ថែម ដើម្បីពង្រឹងសមត្ថភាពក៏ដូចជាធានាដល់ការអនុវត្តនីតិវិធីបញ្ជូនឱ្យមានប្រសិទ្ធិភាព និងមានលក្ខណៈត្រឹមត្រូវតាមច្បាប់ពីសំណាក់មន្ត្រីនោះ។ លើសពីនេះ ក៏គួរតែមានវិធានការរឹតបន្តឹង ដោយដាក់ពិន័យដល់មន្ត្រីដែលពាក់ព័ន្ធនឹងការបញ្ជូនក្នុងករណីដែលមន្ត្រីទាំងនោះមិនគោរពតួនាទីខ្លួន ឬ មិនអនុវត្តទៅតាមគោលការណ៍ច្បាប់ ដើម្បីជៀសវាងភាគីណាមួយមិនបានទទួលការកោះហៅ ឬទទួលបានការកោះហៅដោយមិនស្របច្បាប់កើតមានឡើង។

### ៣.២.៤.ការជម្រុញឱ្យភាគីចូលរួមនីតិវិធីជម្រះក្តីលើបណ្តឹងទាស់

ជាការពិតបណ្តឹងរដ្ឋប្បវេណី ធ្វើឡើងក្នុងគោលបំណងឱ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណី ដោយផ្អែកលើច្បាប់ ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន។ ការធានានូវសិទ្ធិពឹងពាក់តុលាការ ក៏ជាការទាមទារមួយព្រមគ្នានូវនីតិវិធីដោះស្រាយ និងសម្រេចសេចក្តីមួយដែលប្រកបដោយយុត្តិធម៌។ ដូចនេះ នៅក្នុងបណ្តឹងរដ្ឋប្បវេណីភាគីត្រូវបានទទួលស្គាល់នូវសេរីភាពនៃការអនុវត្តនីតិវិធីរដ្ឋប្បវេណី សម្រាប់ផលប្រយោជន៍របស់ខ្លួន ដើម្បីទទួលសាលក្រមឱ្យខ្លួនឈ្នះក្តី។ ប៉ុន្តែ ភាគីមិនត្រូវអនុញ្ញាតឱ្យធ្វើសកម្មភាពដោយទុច្ចរិត និងមិនស្មោះត្រង់ចំពោះភាគីម្ខាងទៀតឡើយ។ ហេតុនេះ នៅពេលដែលតុលាការបានធ្វើការកោះហៅត្រឹមត្រូវតាមច្បាប់ ភាគីនៃរឿងក្តីត្រូវតែចូលបង្ហាញខ្លួននៅនីតិវិធីរបស់តុលាការ ដើម្បីការពារនូវផលប្រយោជន៍របស់ខ្លួន ជៀសវាងមានការខូចខាតផលប្រយោជន៍ដោយប្រការណាមួយ ដែលបណ្តាលមកពីការអវត្តមានរបស់ខ្លួននោះ។

ដើម្បីការកាត់បន្ថយនូវការអវត្តមានរបស់ភាគី ដែលបានទទួលបានការកោះហៅត្រឹមត្រូវតាមច្បាប់ពីតុលាការឱ្យមានកម្រិតទាប និងជម្រុញឱ្យភាគីចូលរួមនីតិវិធីជម្រះក្តីលើបណ្តឹងទាស់ឱ្យគ្រប់ដំណាក់កាលដែលកំណត់ដោយតុលាការនោះ គឺទាមទារឱ្យមានការអនុវត្តដូចខាងក្រោមៈ

ទី១. នៅពេលដែលមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន បានអនុវត្តនូវកិច្ចការបញ្ជូននូវខ្លឹមសារនៃឯកសារតាមផ្លូវបណ្តឹង និងដីកាកោះហៅទៅភាគី និងអ្នកដទៃទៀតដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍ ក្នុងករណីនេះប្រសិនបើការបញ្ជូននោះបានអនុវត្តតាមរយៈការបញ្ជូនដោយប្រគល់ជាដើម ហើយប្រសិនបើអ្នកទទួលការបញ្ជូនមិនចេះអក្សរ មន្ត្រីអនុវត្តកិច្ចការបញ្ជូនគប្បីពន្យល់នូវខ្លឹមសារនៃឯកសារនោះ ដល់អ្នកទទួលការបញ្ជូននៅពេលប្រគល់ឯកសារ។ ដើម្បីជៀសវាងអ្នកទទួលការបញ្ជូនមិនយល់ពីអត្ថន័យនៃឯកសារដែលតុលាការបាន

បញ្ជូន ហើយមិនបានតបត ឬចូលរួមក្នុងនីតិវិធីតុលាការ។ បន្ថែមលើសពីនេះ ទោះបីជាភាគីនោះមានការយល់ដឹងខ្លះៗអំពីបណ្តឹងក្តី ឬមិនមានការយល់ដឹងក្តី មន្ត្រីអនុវត្តកិច្ចការបញ្ជូន ក៏គួរតែពន្យល់បន្ថែមនូវផលប្រយោជន៍នៃបណ្តឹង និងលើកទឹកចិត្ត ព្រមទាំងជម្រុញឱ្យភាគីនោះចូលរួមនីតិវិធីជម្រះក្តីឱ្យបានគ្រប់ដំណាក់កាល ដើម្បីការពារផលប្រយោជន៍ និងភាពស្អាតស្អំរបស់ខ្លួនផងដែរ។

ទី២. តុលាការ ឬស្ថាប័នពាក់ព័ន្ធ គួរតែបង្កើននូវការផ្សព្វផ្សាយច្បាប់ថែមទៀត អំពីការដាក់ទណ្ឌកម្មចំពោះជនទាំងឡាយណាដែលបំពាន ឬ មិនអនុវត្តតាមនីតិវិធីរបស់ច្បាប់ បន្ថែមពីលើការផ្សព្វផ្សាយច្បាប់ដែលទាក់ទងនឹងលំហូរនីតិវិធីរបស់តុលាការនៅចំណុចខាងលើ។ ការបង្កើនការផ្សព្វផ្សាយ អាចធ្វើបានតាមរយៈប្រព័ន្ធបច្ចេកវិទ្យាសម័យទំនើបដែលមាននៅក្នុងពេលបច្ចុប្បន្ននេះ មានដូចជា ៖ វិទ្យុ ទូរទស្សន៍ ហ្វេសប៊ុក តិកតុកជាដើម។ ចំពោះការផ្សព្វផ្សាយនេះ អាចផលិតជាសាច់រឿងអប់រំ និងពន្យល់អំពីវិសាលភាពនៃការអនុវត្តច្បាប់ និងការដាក់ទណ្ឌកម្មចំពោះជនទាំងឡាយណាដែលបំពាន ឬ មិនអនុវត្តតាមនីតិវិធីរបស់ច្បាប់ ជាពិសេសភាគីនៃបណ្តឹង។ តាមរយៈការផ្សព្វផ្សាយនេះផងដែរ ត្រូវមានការលើកទឹកចិត្ត និងជម្រុញឱ្យភាគីនៃរឿងក្តី ត្រូវចូលរួមតាមការកោះហៅរបស់តុលាការឱ្យបានគ្រប់ដំណាក់នៃនីតិវិធី និងស្វែងពីវិសាលភាពនៃការអនុវត្តសេចក្តីសម្រេចរបស់តុលាការផង ទោះបីជាភាគីនោះមិនព្រមចូលខ្លួនតាមការកោះហៅ ឬ រត់គេចក៏ដោយ។

**ឧទាហរណ៍៖** នៅពេលដែលភាគីណាមួយ ទទួលបានការកោះហៅពីតុលាការដោយស្របច្បាប់ហើយ ប៉ុន្តែ ប្រសិនបើភាគីនោះព្រងើយកន្តើយ ធ្វើមិនអើពើ មិនខ្វល់ខ្វាយ ឬមិនបញ្ចេញសកម្មភាពទៅតាមសិទ្ធិដែលខ្លួនមាននោះទេ ភាគីត្រូវទទួលខុសត្រូវដោយខ្លួនឯង ដោយហេតុថាខ្លួនបានលះបង់សិទ្ធិដែលខ្លួនមានតាមផ្លូវច្បាប់។ រីឯតុលាការនឹងបន្តអនុវត្តកិច្ចនីតិវិធីទៅតាមអង្គហេតុជាក់ស្តែង និងភស្តុងតាងដែលមានពិតនៅក្នុងបណ្តឹងតែប៉ុណ្ណោះ។ ហើយការមិនព្រមចូលខ្លួននៅក្នុងនីតិវិធីរបស់តុលាការនេះ មិនមែនជាការរួចពីការទទួលខុសត្រូវនូវកាតព្វកិច្ចណាមួយ ដែលត្រូវបានទាមទារដោយភាគីម្ខាងទៀតនោះឡើយ។ ទោះបីជាភាគីអវត្តមាននោះ ព្យាយាមរត់គេចខ្លួនក៏ដោយ ក៏មិនអាចនឹងគេចវេះពីសំណាញ់ច្បាប់បានដែរ ព្រោះវិសាលភាពនៃច្បាប់ ក៏នៅតែតាមអនុវត្តចំពោះភាគីនោះជានិច្ច សមដូចពាក្យចាស់លោកពោលថា **កុកអាចភ្លេចជង់ តែជង់មិនភ្លេចកុកទេ** ព្រោះនៅថ្ងៃណាមួយភាគីដែលព្យាយាមរត់គេចនោះ គង់តែប្រឈមចំពោះមុខច្បាប់ ដោយការអនុវត្តសាលក្រមជាមិនខាន។

ម្យ៉ាងទៀត ដើម្បីរក្សាកិត្យានុភាពនៃអំណាចរបស់តុលាការ និងដើម្បីបង្ការដល់ជនដទៃ ឬភាគីដទៃទៀតយកគំរូតាម ចំពោះភាគីដែលបានទទួលការកោះហៅត្រឹមត្រូវតាមច្បាប់ហើយ បែរជាមិនបង្ហាញខ្លួន ឬគេចវេះក្នុងការទទួលដីកាកោះ ដោយមានចេតនាទុច្ចរិត តុលាការត្រូវមានចំណាត់ការចំពោះភាគីនោះ ដូចជាការពិន័យជាប្រាក់ជាដើម បន្ថែមពីលើការដាក់ទណ្ឌកម្មដោយសាលក្រមកំបាំងមុខ។

## ៣.២.៥.ការពន្លឿននីតិវិធីជម្រះក្ដីលើបណ្ដឹងចាស់

តុលាការ ក្នុងនាមជាអ្នកដឹកនាំនិងគ្រប់គ្រងដំណើរការនីតិវិធីរដ្ឋប្បវេណី តុលាការត្រូវប្រឹងប្រែងធានាឱ្យបានថារឿងក្ដីរដ្ឋប្បវេណីត្រូវប្រព្រឹត្តិឡើងដោយភាពយុត្តិធម៌ និងឆាប់រហ័ស[៥៥] ។ ពិតមែនតែឯករាជ្យភាពរបស់តុលាការត្រូវបានធានាដោយច្បាប់ ប៉ុន្តែ ពុំមានន័យថាតុលាការអាចយកអំណាចឯករាជ្យនេះ មកប្រើប្រាស់ ជាពិសេស នៅក្នុងការដោះស្រាយបណ្ដឹងរដ្ឋប្បវេណីតាមទំនើងចិត្តរបស់ខ្លួនបាននោះទេ។ ពិតមែនតែតុលាការមានសិទ្ធិសម្រេចសេចក្ដី ប៉ុន្តែមិនមានន័យថា ការសម្រេចសេចក្ដី(ដោះស្រាយបណ្ដឹង) អាចធ្វើបានដោយមិនរវីរវល់ចំពោះពេលវេលានោះឡើយ ដូច្នេះ តុលាការត្រូវគោរពនិងអនុវត្តទៅតាមគោលការណ៍ដែលមានបញ្ញត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ដោយការជម្រះក្ដីត្រូវផ្ដល់យុត្តិធម៌  និងត្រូវធ្វើឡើងក្នុងនាមប្រជារាស្ត្រខ្មែរតាមនីតិវិធីនិងច្បាប់[៥៦] ។

ដើម្បីលើកកំពស់ និងពង្រឹងនូវជំនឿទុកចិត្តរបស់ភាគីនៃរឿងក្ដី ព្រមទាំងពលរដ្ឋចំពោះប្រព័ន្ធច្បាប់ស្ដីពីការដោះស្រាយបណ្ដឹងរដ្ឋប្បវេណី និងដើម្បីធានារក្សាអនាគតិ ការពារសិទ្ធិសេរីភាព និងផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ និងផ្ដល់យុត្តិធម៌ជូនប្រជាពលរដ្ឋទូទៅ ដែលបានពឹងពាក់តុលាការក្នុងការដោះស្រាយវិវាទរបស់ខ្លួនបាននោះ ទាមទារឱ្យស្ថាប័នពាក់ព័ន្ធមានដូចជា ក្រសួងយុត្តិធម៌ និងឧត្តមក្រុមប្រឹក្សាចៅក្រមជាដើម បង្កើតនូវយន្តការតាមដាន និងត្រួតពិនិត្យលើការអនុវត្តច្បាប់របស់ចៅក្រមទទួលបន្ទុក។ ដើម្បីធានាបាននូវការអនុវត្តនីតិវិធីមានភាពត្រឹមត្រូវទៅតាមគោលការណ៍ច្បាប់ ជៀសវាងមានការអនុវត្តផ្ទុយពីនីតិវិធីច្បាប់មានជាធរមានដោយប្រការណាមួយ ដែលបណ្ដាលធ្វើឱ្យមានការយឺតយ៉ាវក្នុងជម្រះក្ដីលើបណ្ដឹងចាស់។ ការបង្កើតយន្តការតាមដាននេះ អាចធ្វើឱ្យដំណើរការនីតិវិធីជម្រះក្ដីប្រព្រឹត្តិទៅដោយភាពឆាប់រហ័ស និងយុត្តិធម៌។

បន្ថែមពីលើនេះ ដើម្បីឱ្យយន្តការនេះទទួលបានប្រសិទ្ធិភាពកាន់តែខ្ពស់  ស្ថាប័នពាក់ព័ន្ធដដែល គួរតែបង្កើតនូវវគ្គបណ្ដុះបណ្ដាលបន្ថែមលើសមត្ថភាពរបស់ចៅក្រមទទួលបន្ទុក ក្នុងករណីដែលចៅក្រមដែលទើបពេញសិទ្ធិថ្មីៗ ដើម្បីឱ្យចៅក្រមទាំងនោះយល់ដឹងកាន់តែច្បាស់អំពីការអនុវត្តជាក់ស្ដែង ឱ្យមានតម្លាភាពទៅនឹងបទបញ្ញត្តិដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។ ម្យ៉ាងទៀត ចៅក្រមទាំងនោះគួរតែត្រូវអនុញ្ញាតឱ្យធ្វើការសាកល្បងវិនិច្ឆ័យសម្រេចសេចក្ដីលើរឿងក្ដីសាមញ្ញធម្មតាៗ ដែលមានលក្ខណៈមិនស្មុគស្មាញឱ្យបានច្រើនល្មមជាមុនសិន ដោយមានការត្រួតពិនិត្យនិងវាយតម្លៃពីក្រុមប្រឹក្សានៃអង្គចៅក្រមទៅតាមលទ្ធផលជាក់ស្ដែង ដែលចៅក្រមនោះបានវិនិច្ឆ័យសម្រេចសេចក្ដី។

ក្នុងករណី ប្រសិនបើយន្តការតាមដាន និងត្រួតពិនិត្យខាងលើ មិនទទួលបានប្រសិទ្ធិក្នុងការអនុវត្តទេ ឬ

[៥៥] មាត្រា៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៥៦] មាត្រា១២៩ កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា

ទទួលបានមិនទាន់គ្រប់គ្រាន់នៅឡើយ ក្រសួងយុត្តិធម៌ គួរតែបង្កើតនូវយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងផ្នែករដ្ឋប្បវេណីបន្ថែមទៀតទៅលើយុទ្ធនាការចាស់ ( យុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងឆ្នាំ ២០២០៖ នយោបាយយុត្តិធម៌ចាស់ ប៉ះកំណែទម្រង់ថ្មី) ដែលត្រូវបានប្រកាសអនុវត្តដោយ **ឯកឧត្តម កើត រិទ្ធ** រដ្ឋមន្ត្រីថ្មីនៃក្រសួងយុត្តិធម៌ នៅខែឧសភា ឆ្នាំ២០២០ កន្លងទៅ ដើម្បីពន្លឿននីតិវិធីជម្រះក្តីរបស់តុលាការលើបណ្តឹងទាស់ឱ្យមានភាពឆាប់រហ័ស និងត្រឹមត្រូវតាមច្បាប់ ព្រមទាំងទទួលបាននូវប្រសិទ្ធិភាពកាន់តែខ្ពស់ និងដើម្បីជៀសវាងការកកស្ទះសំណុំរឿងនៅតុលាការផងដែរ។

### ៣.២.៦. ការពន្លឿននូវការដាក់ពាក្យបណ្តឹងទាស់

ដើម្បីជៀសវាងតុលាការលើកចោលនូវបណ្តឹងទាស់ដោយដីកាសម្រេច ដោយមូលហេតុថា ពាក្យបណ្តឹងទាស់នោះមិនត្រូវត្រឹមតាមច្បាប់ ភាគីនៃបណ្តឹងទាស់ត្រូវដាក់ពាក្យប្តឹងទាស់ នៅក្នុងកាលបរិច្ឆេទដែលកំណត់ដោយច្បាប់។ មានន័យថា ភាគីនៃបណ្តឹងទាស់ ត្រូវគោរពទៅតាមគោលការណ៍ច្បាប់ដែលបានកំណត់ ដោយមិនត្រូវធ្វើការប្តឹងទាស់ ទៅតាមការនឹកឃើញរបស់ខ្លួន ដោយមិនគិតអំពីអំឡុងដែលច្បាប់អនុញ្ញាតនោះទេ។ ប្រសិនបើភាគីនៃបណ្តឹងទាស់ មិនធ្វើការប្តឹងទាស់ ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ទេ ប្រាកដណាស់ថាភាគីនោះនឹងថ្លោះសិទ្ធិក្នុងការប្តឹងទាស់ ដូច្នេះ ទាមទារឱ្យភាគីដែលមានបំណងធ្វើបណ្តឹងទាស់ ត្រូវដាក់ពាក្យប្តឹងទាស់ទៅកាន់តុលាការដែលមានសមត្ថកិច្ចឱ្យបានទាន់ពេលវេលា។

ក៏ប៉ុន្តែ ក្នុងករណីដែលភាគីបោះបង់សិទ្ធិ ឬ ថ្លោះសិទ្ធិក្នុងការធ្វើបណ្តឹងទាស់ ដោយផុតអំឡុងពេលនៃការធ្វើបណ្តឹងទាស់ ក៏មិនមែនមានន័យថាភាគីនោះបាត់បង់នូវសិទ្ធិពឹងពាក់តុលាការក្នុងការស្វែងរកយុត្តិធម៌ឱ្យខ្លួន ចំពោះសេចក្តីសម្រេចកំបាំងមុខនោះដែរ។ មានន័យថា ទោះបីជាភាគីបានបោះបង់សិទ្ធិក្នុងបណ្តឹងទាស់ ឬ ថ្លោះសិទ្ធិក្នុងការធ្វើបណ្តឹងទាស់ ដោយផុតអំឡុងនៃការធ្វើប្តឹងទាស់ ឬ ករណីដែលបណ្តឹងទាស់មិនត្រូវបានទទួលស្គាល់ក៏ដោយ ក៏ច្បាប់អនុញ្ញាតឱ្យប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះសាលក្រមកំបាំងមុខដែរ។ ក្នុងករណីនេះ ភាគីនោះអាចធ្វើបណ្តឹងឧទ្ធរណ៍បានក្នុងអំឡុងពេល១ (មួយ) ខែ ដោយគិតចាប់តាំងពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រម ឬ ថ្ងៃដែលបានជូនដំណឹងអំពីដីកាសម្រេចច្រានចោល ឬ លើកចោលនូវបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ។ ប៉ុន្តែ ករណីនេះ ក៏មិនបានរារាំងភាគី ក្នុងការប្តឹងឧទ្ធរណ៍នៅមុនថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រម ឬ ថ្ងៃដែលបានជូនដំណឹងអំពីការសម្រេចច្រានចោល ឬលើកចោលនូវបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខដែរ។ ម៉្យាងទៀត ភាគីដែលមានសិទ្ធិប្តឹងទាស់ តែបានបោះបង់សិទ្ធិនេះ ក៏អាចធ្វើបណ្តឹងឧទ្ធរណ៍នៅមុនអំឡុងពេលនៃការប្តឹងឧទ្ធរណ៍បានផងដែរ[៥៧]។

---

[៥៧] មាត្រា២៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

លទ្ធផលដែលទទួលបានមកពីកិច្ចការស្រាវជ្រាវលើប្រធានបទ **បណ្តឹងទាស់នៅក្នុងរឿងរដ្ឋប្បវេណី** បានបង្ហាញឱ្យឃើញថា ចំណាត់ការក្នុងរឿងក្តីរដ្ឋប្បវេណីនីមួយៗ ពិតជាមានភាពស្មុគស្មាញណាស់ ដែលទាមទារឱ្យមានការសិក្សាស្រាវជ្រាវត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន និងហ្មត់ចត់បំផុត ដើម្បីធានាបាននូវភាពយុត្តិធម៌ជូនដល់គូភាគីនៃរឿងក្តី និងសង្គមជាតិទាំងមូល។

ករណីដែលតុលាការបានសម្រេចសេចក្តីចេញសាលក្រមកំបាំងមុខ ដោយមិនបានធ្វើការសាកសួរភាគី វាជាហេតុដែលធ្វើឱ្យប៉ះពាល់ ឬ ខូចប្រយោជន៍របស់ភាគី។ ម៉្យាងទៀត ប្រសិនបើការសម្រេចនោះទៀតសោត ដោយពុំបានពិនិត្យឱ្យបានល្អិតល្អន់ទៅលើមូលហេតុ ដែលបណ្តាលធ្វើឱ្យភាគីមិនបង្ហាញខ្លួនតាមកាលបរិច្ឆេទនោះឱ្យបានច្បាស់លាស់ជាមុននោះទេ ការសម្រេចសេចក្តីកំបាំងមុខ ដោយពុំមានវត្តមានរបស់ភាគីម្ខាងទៀតនោះនឹងអាចប៉ះពាល់ដល់ទំនុកចិត្តរបស់ភាគីទៅលើយុត្តិធម៌នៃការវិនិច្ឆ័យ និង សិទ្ធិទាមទារឱ្យសាកសួររបស់ភាគីជាមិនខាន។ ដោយមូលហេតុ នៃការវិនិច្ឆ័យដោយមិនបានធ្វើការសាកសួរ ឬ ផ្តល់ឱកាសឱ្យភាគីនោះក្នុងការបញ្ចេញមតិយោបល់របស់ខ្លួន ដែលពាក់ព័ន្ធទៅនឹងបញ្ហាដែលត្រូវសម្រេចសេចក្តីដោយតុលាការនៅក្នុងបណ្តឹងរដ្ឋប្បវេណី និងក្នុងការឆ្លើយតបទៅនឹងមតិយោបល់របស់ភាគីម្ខាងទៀតទេ វាជាហេតុដែលធ្វើឱ្យប៉ះពាល់ ឬ ខូចប្រយោជន៍របស់ភាគីនោះ ទើបក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ បានទុកសិទ្ធិឱ្យភាគី ដែលតុលាការបានចេញនូវសាលក្រមកំបាំងមុខ មានសិទ្ធិក្នុងការធ្វើបណ្តឹងទាស់ ដើម្បីទាមទារឱ្យតុលាការ ឬចៅក្រមដែលបានចេញសាលក្រមកំបាំងមុខធ្វើការសម្រេចសេចក្តីម្តងទៀត។

សរុបមក ការសិក្សាអំពីបណ្តឹងទាស់ក្នុងរឿងរដ្ឋប្បវេណី គឺពិតជាមានគុណតម្លៃដ៏វិសេសវិសាល ក្នុងការបង្កើនចំណេះដឹងពាក់ព័ន្ធនឹងបណ្តឹងទាស់ ក៏ដូចជាស្វែងយល់ពីបញ្ហាដែលកំពុងកើតឡើងនៅក្នុងការអនុវត្តដំណើរការនីតិវិធីជាក់ស្តែងរបស់តុលាការ។ ទន្ទឹមនឹងនេះ ប្រសិនបើយើងពិនិត្យឱ្យបានស៊ីជម្រៅទៅលើបញ្ញត្តិនៃបណ្តឹងទាស់ដែលបានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ឃើញថាបណ្តឹងទាស់ គឺជាផ្នែកមួយដ៏សំខាន់ក្នុងបណ្តឹងរដ្ឋប្បវេណី ដែលអាចទាមទារឱ្យតុលាការធ្វើការផ្លាស់ប្តូរ ឬលុបចោលនូវសេចក្តីសម្រេចដើម។ ម៉្យាងទៀត ក៏ជាបណ្តឹងមួយដ៏មានសារៈសំខាន់ចំពោះភាគី ដែលត្រូវបានតុលាការចេញនូវសាលក្រមកំបាំងមុខ អាចមានលទ្ធភាពក្នុងការប្រើប្រាស់សិទ្ធិរបស់គាត់ម្តងទៀត នៅក្នុងនីតិវិធីបណ្តឹងទាស់ និងផ្តល់ឱកាសដល់តុលាការក្នុងការស្វែងរកការពិតជូនភាគី ដែលបង្ករឱ្យមានភាពងាយស្រួលដល់គូវិវាទក្នុងការទទួលបាននូវភាពស្មើគ្នាចំពោះមុខច្បាប់ ដែលអាចឱ្យភាគីបង្ហាញនូវសិទ្ធិ និង ដាក់មធ្យោបាយក្នុងការតទល់ឱ្យអស់ពីលទ្ធភាព ទោះបីជាលទ្ធផលនោះទទួលបានមកចាញ់ ឬឈ្នះក៏ដោយ ក៏ភាគីនោះបានជជែកតតាំងគ្នាទៅវិញទៅមកដែរ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវ និងស្វែងយល់ជុំវិញប្រធានបទស្តីពី **បណ្តឹងទាស់នៅក្នុងរឿងរដ្ឋប្បវេណី** រួចមក ជារួមឃើញថាបណ្តឹងទាស់ដែលបានកំណត់ដោយក្រមនីតិវិធីរដ្ឋប្បវេណី ពិតជាមានសារៈសំខាន់ណាស់ ដែលជាបណ្តឹងមួយធ្វើឡើងប្រឆាំងនឹងសាលក្រមកំបាំងមុខ ទាមទារឱ្យមានការលុបចោល ឬ ផ្លាស់ប្តូរសាលក្រមកំបាំងមុខនោះ។ តាមរយៈបណ្តឹងនេះ ក៏ជាការទាមទារឱ្យតុលាការគោរពនូវគោលការណ៍សិទ្ធិទាមទារឱ្យសាកសួរ គោលការណ៍ចំពោះមុខ គោលការណ៍នៃការទទួលខុសរបស់តុលាការ និងគោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់ ព្រមទាំងធ្វើការគោរពនូវផលប្រយោជន៍របស់ភាគី និងអ្នកដែលពាក់ព័ន្ធ។ ដោយហេតុថាបណ្តឹងទាស់កើតមានឡើងពាក់ព័ន្ធវត្តមានរបស់ភាគី ដែលពុំបានចូលរួមបង្ហាញខ្លួននៅកិច្ចនីតិវិធីណាមួយដែលតុលាការបានកំណត់។ បញ្ហានេះកើតមាន អាចព្រោះតែតុលាការមិនបានជូនដំណឹងអំពីព័ត៌មានពាក់ព័ន្ធឱ្យបានគ្រប់គ្រាន់ ឬមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនមិនបានអនុវត្តច្បាប់ឱ្យបានគ្រប់ជ្រុងជ្រោយ។

ដើម្បីបន្ថយករណីកើតមានបណ្តឹងទាស់នេះឱ្យមានកម្រិតទាប និងជម្រុញឱ្យមានការចូលរួមបង្ហាញខ្លួនរបស់ភាគី ឱ្យបានគ្រប់ដំណាក់កាលនីតិវិធីរបស់តុលាការ ខ្ញុំបាទសូមចូលរួមមតិយោបល់ដូចខាងក្រោម៖

១. ដោយឆ្លងតាមការសិក្សាស្រាវជ្រាវរួចមក ការអវត្តមានរបស់ភាគី ដោយមានករណីមួយចំនួន គឺមិនបានទទួលដីកាកោះហៅ ឬ ទទួលបានការកោះហៅដោយមិនស្របច្បាប់ តាមរយៈបញ្ហានេះសបញ្ជាក់ថា មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនមិនបានអនុវត្តច្បាប់ ឬ អនុវត្តមិនត្រឹមត្រូវតាមគោលការណ៍ច្បាប់នោះទេ ដូច្នេះ ដើម្បីឱ្យមន្ត្រីទទួលបន្ទុកកិច្ចបញ្ជូន អនុវត្តនូវកិច្ចការបញ្ជូនបានត្រឹមត្រូវតាមការកំណត់របស់ច្បាប់ ក្រសួងយុត្តិធម៌គប្បីបើវគ្គបណ្តុះបណ្តាលអំពីតួនាទី ភារកិច្ច និងវិធីបញ្ជូនដល់មន្ត្រីទទួលកិច្ចការបញ្ជូន ព្រោះថាមិនទាន់ឃើញមានបើកវគ្គនេះទេ។

២. ដោយផ្អែកលើស្ថានភាពភូមិសាស្ត្រ ស្ថានភាពបុគ្គលដែលត្រូវអនុវត្តកិច្ចការបញ្ជូនបច្ចុប្បន្ន យើងឃើញថា ទោះបីជាច្បាប់កំណត់ឱ្យមន្ត្រីប្រៃសណីយ៍ អាជ្ញាសាលា ក្រឡាបញ្ជី ជាអ្នកអនុវត្តក៏ដោយ ក៏គួរតែធ្វើការទទួលស្គាល់នូវការអនុវត្តតាមរយៈមេឃុំ ចៅសង្កាត់ នគរបាល កងរាជអាវុធហត្ថ ជាអាទិ៍ផងដែរ ព្រោះជាភាពងាយស្រួលដើម្បីកាត់បន្ថយកិច្ចការរបស់មន្ត្រីបច្ចេកទេស ក៏ដូចងាយស្រួលដល់ភាគី ក្នុងការទទួលបាននូវដីកាកោះហៅពីតុលាការ។ មានន័យថា មេឃុំ ចៅសង្កាត់ នគរបាល កងរាជអាវុធហត្ថ ជាអាទិ៍ អាចដឹងច្បាស់អំពីភូមិសាស្ត្រជាងមន្ត្រីប្រៃសណីយ៍ អាជ្ញាសាលា ក្រឡាបញ្ជី ទៅលើស្ថានភាពរបស់បុគ្គលដែលត្រូវទទួលការបញ្ជូននោះ ថាមានទីលំនៅ នៅទីណា ពេលណានៅផ្ទះ ឬមិននៅផ្ទះ ឬអាចដឹងថាជននោះមានការផ្លាស់ប្តូរអាសយដ្ឋានថ្មី ឬ មិនការផ្លាស់ប្តូរអាសដ្ឋានជាដើម។

៣.ក្រសួងយុត្តិធម៌ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គប្បីចាត់វិធានការឱ្យបានតឹងរឹងបំផុតចំពោះ

ចៅក្រមទទួលបន្ទុករឿងក្ដី និងមន្ត្រីដែលពាក់ព័ន្ធក្នុងវិស័យតុលាការ ទៅលើការអនុវត្តច្បាប់។ ដើម្បីជៀសវាងនូវការជម្រះក្ដីដែលមិនផ្ដល់យុត្តិធម៌ជូនគូភាគីនៃរឿងក្ដី និងដើម្បីរក្សានូវកិត្យានុភាពនៃអំណាចតុលាការ និងធានាបាននូវសេចក្ដីទុកចិត្តពីសំណាក់ប្រជាពលរដ្ឋ ទៅលើប្រព័ន្ធតុលាការ ករណីដែលចៅក្រមទទួលបន្ទុក និងមន្ត្រីដែលពាក់ព័ន្ធណាមួយ មិនអនុវត្ត ឬមិនគោរពតាមគោលការណ៍ច្បាប់ទេ ត្រូវតែដាក់ទណ្ឌកម្មទៅតាមកំហុសជាក់ស្ដែង ដែលចៅក្រម ឬ មន្ត្រីពាក់ព័ន្ធនោះបានប្រព្រឹត្តិផ្ទុយពីច្បាប់។

ម៉្យាងទៀត ក្រសួងយុត្តិធម៌ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គប្បីបង្កើតប្រព័ន្ធផ្សព្វផ្សាយច្បាប់ឱ្យបានទូលំទូលាយ ស្ដីអំពីនីតិវិធីអនុវត្តនៅតុលាការ។ ព្រមទាំងបង្កើតវគ្គបណ្ដុះបណ្ដាលច្បាប់ ដល់ប្រជាពលរដ្ឋទូទៅ ឬ ធ្វើជាសិក្ខាសាលាពន្យល់អំពីនីតិវិធីនៃការធ្វើបណ្ដឹងទៅកាន់តុលាការឱ្យបានច្រើន។ បន្ថែមលើសពីនេះទៅទៀត ករណីដែលភាគីណាមួយនៃរឿងក្ដី ដែលបានទទួលការកោះហៅដោយស្របច្បាប់ហើយ ប៉ុន្តែមិនព្រមចូលខ្លួនតាមការកោះហៅរបស់តុលាការទេ តុលាការត្រូវចាត់វិធានការឱ្យបានម៉ឺងមាត់ចំពោះភាគីនោះ។ ដោយត្រូវដាក់ទណ្ឌកម្មណាមួយ ឱ្យសមស្របតាមកំហុសជាក់ស្ដែង បន្ថែមលើទណ្ឌកម្មដោយសាលក្រមកំបាំងមុខ។

# ឯកសារយោង

# ឯកសារយោង

❖ **លិខិតបទដ្ឋានគតិយុត្តិជាតិ**

១- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

២- ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦

៣- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ លេខ នស/រកម/១២០៧/០៣០ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧

❖ **ឯកសារផ្សេងៗ**

៤- សេចក្តីពន្យល់នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ភាគ១ ស្តីពីនីតិវិធីបណ្តឹងឆ្នាំ ២០០៨

៥- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី របស់ក្រសួងយុត្តិធម៌ ឆ្នាំ២០០៧

៦- មេរៀនស្តីពី ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ ឆ្នាំ២០១៥ និងភាគ២ ឆ្នាំ២០១៦

៧- មេរៀន នីតិវិធីរដ្ឋប្បវេណី របស់លោកសាស្ត្រាចារ្យ ហ៊ី សោភា(ថតចម្លងដោយ ជ័យ វាសនា ឆ្នាំ២០១៣)

៨- មេរៀន នីតិវិធីរដ្ឋប្បវេណី របស់លោកសាស្ត្រាចារ្យ ហេង ប៉ូវ៉ា ឆ្នាំសិក្សា២០២១-២០២២

៩- មេរៀន នីតិវិធីរដ្ឋប្បវេណី របស់លោកមេធាវី អ៊ីវ ប៉ូលី ឆ្នាំ២០១០

១០- កំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ឆ្នាំ២០១៦ នៃវិទ្យាស្ថានសភាកម្ពុជា

១១- គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពនៃក្រុមចៅក្រម ដែលអនុម័តដោយអង្គការសហប្រជាជាតិ

១២- វចនានុក្រមនៃសម្តេចសង្ឃរាជ ជួន ណាត ព.ស ២៥១១ គ.ស ១៩៦៧

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

| | |
|---|---|
| **ឧបសម្ព័ន្ធទី១** | ១.ពាក្យបណ្ដឹងទាស់<br>២.សេចក្ដីចម្លងបណ្ដឹងទាស់ |
| **ឧបសម្ព័ន្ធទី២** | ១.ដីកាសម្រេចបង្គាប់ឱ្យកែតម្រូវពាក្យបណ្ដឹងទាស់<br>២.ដីកាសម្រេចលើកចោលពាក្យបណ្ដឹងទាស់<br>៣.ដីកាសម្រេចច្រានចោលពាក្យបណ្ដឹងទាស់ |
| **ឧបសម្ព័ន្ធទី៣** | ១.ដីកាកោះ<br>២.លិខិតជូនដំណឹង អំពីការបញ្ជូនដីកាកោះតាមការផ្សាយជាសាធារណៈ<br>៣.របាយការណ៍អំពីការបញ្ជូន |
| **ឧបសម្ព័ន្ធទី៤** | ១.សាលក្រមកំបាំងមុខ<br>២.សាលក្រមដែលបានប្រកាសកំបាំងមុខភាគី |
| **ឧបសម្ព័ន្ធទី៥** | សាលក្រមកំបាំងមុខលើកទី២ |

# ឧបសម្ព័ន្ធទី១

## ពាក្យបណ្ដឹងទាស់ និង

## សេចក្ដីចម្លងបណ្ដឹងទាស់

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ៥៣/២៣

សាលាដំបូងរាជធានីភ្នំពេញ
ចូល លេខ ០៧ ថ្ងៃទី ១២ ខែ ០៤ ឆ្នាំ ២០២៣ ម៉ោង ១០ ង ៣៥

# ពាក្យបណ្តឹងទាស់

ខ្ញុំបាទមេធាវី អត្តលេខ សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីតំណាងដោយអាណត្តិទាយកឈ្មោះ ជាដើមចោទ ។

ស្នាក់ការការិយាល័យមេធាវី ផ្ទះលេខ សេអី ផ្លូវ សង្កាត់បឹងកេងកង ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។ទូរស័ព្ទលេខ ០១២ ។

**សូមគោរពជូន**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ** ប្តឹងទាស់នឹងសាលក្រមរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់សេចក្តីសំរេចទាំងមូលនៃសាលក្រម។

**យោង** -មាត្រា២៤៦ និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-សាលក្រមរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

-សំណុំរឿងរដ្ឋប្បវេណីលេខ១៩៤៧ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។

-លិខិតប្រគល់សិទ្ធិមេធាវីតំណាងដោយអាណត្តិចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣ របស់ឈ្មោះ ។

**សាលក្រមដែលទាមទារដោយដើមបណ្តឹងទាស់**

១-លុបឬបដិសេធចោល សាលក្រមរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

២-មោឃភាពវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ និងលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីរាជធានីភ្នំពេញ មានទីតាំងស្ថិតនៅក្នុងបុរីសែនមនោរម្យ ភូមិកន្ទោកជើង សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ ដែលមានឈ្មោះ និងឈ្មោះ ។

ជាម្ចាស់កម្មសិទ្ធិផ្ទះល្វែងលេខ [illegible] ទទឹងប្រវែង ៤,៥០ម៉ បណ្តោយប្រវែង១៦ម៉និងលេខ B6(13)លើដីនេះ ចោលទាំងស្រុង ។

៣-បង្គាប់ឲ្យមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីរាជធានីភ្នំពេញ លុបឈ្មោះ [illegible] និងឈ្មោះ [illegible] ចេញពីវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ [illegible] និងលេខ [illegible] ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ ដោយរក្សាទុកស្ថានភាព ដើមវិញដដែល។

៤-បង្គាប់ឲ្យសហចុងចម្លើយ ឈ្មោះ[illegible] និងឈ្មោះ [illegible] ប្រគល់ដី-ផ្ទះល្វែងលេខB6 (12) និងលេខ B6 (13) ដូចចំណុច១ ខាងលើ ឲ្យឈ្មោះ[illegible] គ្រប់គ្រងជាកម្មសិទ្ធិវិញ ដោយគ្មានលក្ខណ្ឌ។

៥-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

**<u>មូលហេតុនៃការប្តឹងទាស់</u>**

តុលាការអនុវត្តផ្ទុយបញ្ញត្តិមាត្រា២៤៦ (គោលការណ៍នៃការបញ្ជូន)នៃក្រមនីតិវិធីនៃព្រះរាជាណាចក្រកម្ពុជា ដោយហេតុថា ជាគោលការណ៍ កិច្ចការបញ្ជូនត្រូវតែធ្វើឡើងដោយក្រឡាបញ្ជី និងប្រតិបត្តិដោយបុគ្គលិកប្រៃសណីយ៍,អាជ្ញាសាលា ឬក្រឡាបញ្ជី។ ក្នុងករណីនេះខ្ញុំបាទ និងកូនក្តីរបស់ខ្ញុំបាទមិនបានទទួល លិខិតអញ្ជើញមេធាវី ឬដីកាកោះដើម្បីទាញហេតុផលផ្ទាល់មាត់ ពីតុលាការ តាមរយៈការបញ្ជូន តាមបញ្ញត្តិ មាត្រា ២៤៦ឡើយ។ក្នុងករណីនេះតុលាការ បានចេញសាលក្រមរដ្ឋប្បវេណីកំបាំងមុខលេខ[illegible] ចុះថ្ងៃទី [illegible] ខែ[illegible] ឆ្នាំ [illegible] អនុវត្តផ្ទុយពីបញ្ញត្តិមាត្រា ២០២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

អាស្រ័យហេតុនេះ សូម**ឯកឧត្តមប្រធាន** មេត្តាចាត់ការតាមនីតិវិធី ។

ថ្ងៃអង្គារ ៦រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣

**ហត្ថលេខា និងត្រា**

មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

**<u>ជូនភ្ជាប់ជាមួយ</u>**

១-លិខិតប្រគល់សិទ្ធិមេធាវី តំណាងដោយអាណត្តិរបស់ ឈ្មោះ[illegible] ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ ២០២៣ = ០១សន្លឹក។

២-សាលក្រមរដ្ឋប្បវេណីលេខ[illegible] ចុះថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ[illegible]របស់សាលាដំបូងរាជធានីភ្នំពេញ=០១ច្បាប់ថតចម្លង។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

# សេចក្តីចម្លងបណ្តឹងដាស់

លេខ ថ្ងៃទី
ខែ ឆ្នាំ
សំណុំរឿង រដ្ឋប្បវេណី
លេខ ចុះថ្ងៃទី
ខែ ឆ្នាំ

ឆ្នាំពីរពាន់ម្ភៃបី ខែមេសា ថ្ងៃទីដប់ពីរ វេលាម៉ោងដប់និងសាមសិបប្រាំនាទី។
យើង ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ។
បានឃើញពាក្យបណ្តឹង ទាស់ ចុះថ្ងៃទី ១១.០៤.២០២៣ របស់ឈ្មោះ
មេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ ។
ចូលមកចំពោះមុខយើងនៅការិយាល័យក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ។
ហើយសុំប្តឹង ទាស់ នឹងសាលក្រមរដ្ឋប្បវេណីកំបាំងមុខលេខ ចុះថ្ងៃទី
ខែ ឆ្នាំ ត្រង់ សេចក្តីសម្រេចទាំងមូលនៃសាលក្រម។

អ្នកប្តឹង
ហត្ថលេខា ឬ ផ្តិតមេដៃ

ក្រឡាបញ្ជី
ហត្ថលេខា

---

បានឃើញ
ថ្ងៃពុធ ៧រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ភ្នំពេញ ថ្ងៃទី ១២ ខែមេសា ឆ្នាំ២០២៣
ជ. ប្រធានសាលាដំបូង
អនុប្រធាន

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ៧រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ភ្នំពេញ ថ្ងៃទី ១២ ខែមេសា ឆ្នាំ២០២៣
ក្រឡាបញ្ជី

បានទទួល
19-04-2023 10:50

# ឧបសម្ព័ន្ធទី២

## ដីកាសម្រេចបង្គាប់ឱ្យកែតម្រូវ

## លើកចោល,ច្រានចោល

## ពាក្យបណ្តឹងទាស់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ:........................

## ដីកាសម្រេចបង្គាប់ឱ្យកែតម្រូវពាក្យបណ្ដឹងទាស់

យើង...........................ចៅក្រម, ប្រធានក្រុមប្រឹក្សាជំនុំជម្រះ នៃសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញមាត្រា២០៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ.......................ចុះថ្ងៃទី..............ខែ...........ឆ្នាំ............ របស់សាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញសាលក្រមកំបាំងមុខលេខ........................... ចុះថ្ងៃទី....... ខែ.........ឆ្នាំ..............

បានឃើញពាក្យបណ្ដឹងទាស់ ចុះថ្ងៃទី.......ខែ.........ឆ្នាំ..........របស់ឈ្មោះ..........................

### សំអាងហេតុ

-.............................................................................................................................

-.............................................................................................................................

-.............................................................................................................................

### ហេតុដូច្នេះសម្រេច

បង្គាប់ឱ្យឈ្មោះ.......................កែតម្រូវពាក្យបណ្ដឹងទាស់ ចុះថ្ងៃទី.........ខែ..........ឆ្នាំ........... ត្រង់ចំណុច...........................................ក្នុងរយៈពេល...................................................

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី........ខែ........ឆ្នាំ...............

**ចៅក្រម, ក្រុមប្រឹក្សាជំនុំជម្រះ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រៃវែង
លេខ...103/2016...........

# ដីកាសម្រេចលើកចោលពាក្យបណ្ដឹងទាស់

យើង **សុខ កល្យាណ** ចៅក្រមសាលាដំបូងខេត្ត ព្រៃវែង

បានឃើញ មាត្រា ២០៧ កថាខ័ណ្ឌ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ ២០០៦។

បានឃើញ សំណុំរឿងអនុវត្តលេខ ០៧ ចុះថ្ងៃទី០១ខែ មីនា ឆ្នាំ២០១៣ របស់សាលាដំបូងខេត្ត ព្រៃវែង។

បានឃើញ លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ។

បានឃើញ លិខិតតំណាងដោយអាណត្តិ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ។

បានឃើញ ពាក្យបណ្ដឹងទាស់និងការអនុវត្ត ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៥ របស់ឈ្មោះ ពុធ ផាត ។

## សំអាងហេតុ

យល់ឃើញថា: ពាក្យបណ្ដឹងទាស់ និងការអនុវត្តចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០១៥ របស់ឈ្មោះពុធ ផាត ដែលបានប្ដឹងទាស់និងការអនុវត្តលក់ឡាយឡុង និងសុំចូលជាតតិយជនក្នុងសំណុំរឿងអនុវត្តលេខ ០៧ ចុះថ្ងៃទី០១ ខែ មីនា ឆ្នាំ២០១៣ ឃើញថា ម្ចាស់បណ្ដឹងទាស់បានទិញដី និងផ្ទះមួយកន្លែងពីឈ្មោះ ជី ហៀន ( ត្រូវជាម្ដាយក្ូនបំណុលនៃការអនុវត្តឈ្មោះ ជី ភឿន ប្រពន្ធឈ្មោះ ថន គុលា) ដីលំនៅឋានមានទំហំ ៨០៥ ម² និងផ្ទះមួយខ្នងសង់អំពីថ្មឥដ្ឋ ដំបូលប្រក់សង្កសី មានទំហំ ១៧២,៨៤ ម² មានទីតាំងស្ថិតនៅភូមិស្ពរដាច ឃុំ តាកោ ស្រុក ពោធិ៍រៀង ខេត្តព្រៃវែង ក្នុងតម្លៃ$១.២០០០(មួយម៉ឺនពីរពាន់)ដុល្លារអាមេរិក ដោយមានលិខិតផ្ទេរកម្មសិទ្ធិ ចុះថ្ងៃទី១១ខែវិច្ឆិកា ឆ្នាំ២០១៥ និងកិច្ចសន្យាលក់ផ្ដាច់ ចុះថ្ងៃទី១១ខែវិច្ឆិកា ឆ្នាំ២០១៥ ។

យល់ឃើញថា: ម្ចាស់បណ្ដឹងទាស់និងការអនុវត្តឈ្មោះ ពុធ ផាត បានបញ្ជាក់នៅក្នុងពាក្យបណ្ដឹងទាស់ថា: រូបគាត់ពិតជាពុំបានដឹងអំពីទ្រព្យសម្បត្តិរបស់កូនបំណុលដែលបានលក់ឡាយឡុងរបស់តុលាការតាមរយៈការបិទផ្សព្វផ្សាយជាសាធារណៈ នៅក្នុងសំណុំរឿងអនុវត្តខាងលើនេះទេ ។ ក្រោយពីរូបគាត់បានទិញដី និងផ្ទះពីឈ្មោះជី ហៀន (ត្រូវជាម្ដាយកូនបំណុលនៃការអនុវត្ត) នៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៥ រួចមក ក៏មានលិខិតផ្សាយជាសាធារណៈ អំពីការលក់ឡាយឡុងដោយស្រោមសំបុត្រ ចុះថ្ងៃទី០៨ខែធ្នូ ឆ្នាំ២០១៥ លើដី និងផ្ទះរបស់គាត់ ដែលបានទិញរួចហើយ ។

យល់ឃើញថា: លិខិតផ្ទេរកម្មសិទ្ធិ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៥ និងកិច្ចសន្យាលក់ផ្ដាច់ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៥ រវាងឈ្មោះជី ហៀន និងឈ្មោះពុធ ផាត គឺបានធ្វើឡើង

ក្រោយតុលាការអនុវត្ត ដោយតុលាការអនុវត្តបានចាប់ផ្ដើមចេញ ដីកាបង្គាប់ឲ្យអនុវត្តការលក់ ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា និងការផ្សាយជាសាធារណៈអំពីការលក់ឡាយឡុង ដោយស្រោមសំបុត្រ ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៣ ។ ដូចនេះ ការផ្ទេរកម្មសិទ្ធិ និងការទិញលក់ខាងលើពុំត្រឹមត្រូវឡើយ ។

យល់ឃើញថា: ពាក្យបណ្ដឹងទាស់និងការអនុវត្តរបស់ឈ្មោះ ពុធ ផាត ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៥ គប្បីលើកពាក្យបណ្ដឹងចោល។

## ហេតុដូច្នេះសម្រេច

-លើកចោលពាក្យបណ្ដឹងទាស់ ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០១៥ របស់ឈ្មោះ ពុធ ផាត នៅក្នុងសំណុំរឿងអនុវត្តលេខ ០៧ ចុះថ្ងៃទី០១ខែ មីនា ឆ្នាំ២០១៣ ។

ព្រៃវែង ថ្ងៃទី២៨ ខែ មិថុនា ឆ្នាំ២០១៦

ចៅក្រម

សុខ_គល្យាណ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

លេខៈ..........................

## ដីកាសម្រេចច្រានចោលពាក្យបណ្ដឹងទាស់

យើង..............................ចៅក្រម, ប្រធានក្រុមប្រឹក្សាជំនុំជម្រះ នៃសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញមាត្រា២០៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ.........................ចុះថ្ងៃទី..............ខែ............ឆ្នាំ............ របស់សាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញសាលក្រមកំបាំងមុខលេខ............................ ចុះថ្ងៃទី....... ខែ.........ឆ្នាំ..............

បានឃើញពាក្យបណ្ដឹងទាស់ ចុះថ្ងៃទី.......ខែ..........ឆ្នាំ..........របស់ឈ្មោះ..........................

## សំអាងហេតុ

-.............................................................................................................................

-.............................................................................................................................

-.............................................................................................................................

## ហេតុដូច្នេះសម្រេច

ច្រានចោលបណ្ដឹងទាស់ ចុះថ្ងៃទី..........ខែ.........ឆ្នាំ...........របស់ឈ្មោះ........................................

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី........ខែ........ឆ្នាំ...............

**ចៅក្រម, ក្រុមប្រឹក្សាជំនុំជម្រះ**

# ឧបសម្ព័ន្ធទី៣

## ដីកាកោះ, លិខិតជូនដំណឹង និង

## របាយការណ៍អំពីការបញ្ជូន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*******

ស៊ូ លក្ខិណា

សាលាដំបូងរាជធានីភ្នំពេញ

# ដីកាកោះ

សំណុំរឿងរដ្ឋប្បវេណី

បង្គាប់មកឈ្មោះ ជា កែវកល្យាណ ភេទស្រី និងប្តីឈ្មោះ គឹម វុទ្ធី ភេទប្រុស អាសយដ្ឋាននៅផ្ទះលេខ១១៧ ផ្លូវលេខ១៨ ភូមិប្រការ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ។

| | |
|---|---|
| សញ្ញាណ នៃរឿងក្តី (លេខនិងភាគី)<br>-ប្តឹងសុំទាមទារប្រាក់ | **សំណុំរឿងរដ្ឋប្បវេណីលេខ១០៨៨ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២**<br>-ដើមចោទឈ្មោះ **សេង ណារី**<br>-សហចុងចម្លើយឈ្មោះ **ជា កែវកល្យាណ** និងឈ្មោះ **គឹម វុទ្ធី** |
| កាលបរិច្ឆេទ និង ទីកន្លែងដែលត្រូវបង្ហាញខ្លួន | **ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២** វេលាម៉ោង៩និង៣០នាទី ☑ព្រឹក ☐រសៀល<br>សាលាដំបូងរាជធានីភ្នំពេញ ជាន់ទី៣ បន្ទប់ "ឋ" |
| ប្រភេទដំណាក់កាលនៃនីតិវិធី<br>(សូមគូស☐ លើលេខនៃនីតិវិធីដែលចាំបាច់) | ១.ការទាញហេតុផលដោយផ្ទាល់មាត់ ☐ ២.ការប្រកាសសាលក្រម ☐<br>៣.ការផ្សះផ្សា ☐ ៤.នីតិវិធីត្រៀម ☑ ៥.សេចក្តីបញ្ជាក់ដំបូង ☐ |
| ប្រភេទនៃឯកសារដែលភ្ជាប់ជាមួយ<br>(សូមសរសេរបញ្ជាក់ឈ្មោះឯកសារបើចាំបាច់អោយកាន់មក) | |
| ទណ្ឌកម្ម ជាអាទិ៍ក្នុងករណីដែលមិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ | **១.ចំពោះសាម៉ីភាគី:** បើពុំចូលខ្លួននោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន ។<br>**តាមមាត្រា១៤០ កថាខ័ណ្ឌទី២. ២៧៣ ក្រមនីតិវិធីរដ្ឋប្បវេណី ។**<br>**២.ចំពោះសាក្សី:**បើមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ<br>**តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០រៀល ( មួយលានរៀល ) ។**<br>តាមមាត្រា១៣២ កថាខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ |

សូមបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដូចដែលបានកំណត់ខាងលើ ។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២

**ចៅក្រម**

ម៉ឹម ច័ន្ទវណ្ណៈ

<u>បញ្ជាក់:</u> ក្នុងករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចបង្ហាញខ្លួនបាន សូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុនោះ ជូនតុលាការ ។ ពេលបង្ហាញខ្លួនសូមយកដីកាកោះនេះជូនក្រឡាបញ្ជីទទួលបន្ទុក។ ទម្រង់នេះប្រើសម្រាប់ ភាគី សាក្សី អ្នកចូលរួមអន្តរាគមន៍ក្នុងបណ្តឹង។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តបន្ទាយមានជ័យ

សំណុំរឿងរដ្ឋប្បវេណីលេខ ០១
ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១

# ***លិខិតជូនដំណឹង***
## ***ស្តីពីការបញ្ជូនតាមការផ្សាយជាសាធារណៈ***

*យើង **សំ វាសនា** ក្រឡាបញ្ជី សាលាដំបូងខេត្តបន្ទាយមានជ័យ ។*

<u>សូមជូនដំណឹងមក:</u> ឈ្មោះ ជីម វាសនា អាសយដ្ឋានផ្ទះលេខ១៨៥ ភូមិសន្សំកុសល២ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ជាចុងចម្លើយក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ០១ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១ *ឲ្យបានជ្រាបថា :* សាលាដំបូងខេត្ត បន្ទាយមានជ័យ បានសម្រេចធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ ដោយហេតុថាការបញ្ជូនមិនអាចធ្វើបានឡើយ តាមមាត្រា ២៥១ "ការបញ្ជូននៅកន្លែងជួបប្រទះ" និងមាត្រា ២៥២ "ការបញ្ជូនបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោល" នៃក្រមនីតិវិធីរដ្ឋប្បវេណី ចាំបាច់ដើម្បីជៀសវាងការយឺតយ៉ាវ ក្នុងដំណើរការនីតិវិធីក្នុងការបញ្ជូនតាមការផ្សាយជាសាធារណៈនេះ តុលាការៈ

-បានកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលត្រូវធ្វើនៅថ្ងៃទី..២៧.. ខែ..មីនា.... ឆ្នាំ២០២២ វេលាម៉ោង..៩:៣០..នាទី ព្រឹក/~~រសៀល~~ ដោយដីកាកោះ និងឯកសារមួយចំនួនដែលត្រូវបញ្ជូនទៅចុងចម្លើយបានរក្សាទុកនៅនឹងក្រឡាបញ្ជី ដែលសាមីខ្លួនអាចមកទទួលនៅការិយាល័យក្រឡាបញ្ជីនៅរាល់ម៉ោងធ្វើការ ។

-បានបិទផ្សាយដីកាកោះ និងលិខិតជូនដំណឹងស្តីពីការបញ្ជូនតាមការផ្សាយជាសាធារណៈ នៅកន្លែងសម្រាប់បិទផ្សាយជាសាធារណៈ នៅសាលាដំបូងខេត្តបន្ទាយមានជ័យ និងនៅសាលាសង្កាត់បឹងទំពុន ដែលជាលំនៅដ្ឋានចុងក្រោយរបស់សហចុងចម្លើយស្ថិតនៅភូមិសន្សំកុសល២ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

*សេចក្តីនេះសូម ឈ្មោះ ជីម វាសនា ជ្រាបជាដំណឹង ។*

*ថ្ងៃ..សុក្រ ៩ រោច..ខែ..មាឃ..ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥*

*បន្ទាយមានជ័យ,ថ្ងៃទី..២៥..ខែ..កុម្ភៈ..ឆ្នាំ២០២២*

**ក្រឡាបញ្ជី**

**សំ វាសនា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

## របាយការណ៍អំពីការបញ្ជូន

ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី

| |
|---|
| កាលបរិច្ឆេទផ្ញើចេញ: ថ្ងៃទី 10 ខែ 11 ឆ្នាំ២០១6 |
| លេខសំណុំរឿង: 722 ចុះថ្ងៃទី 16 ខែ 03 ឆ្នាំ២០១6 |
| ឈ្មោះឯកសារដែលត្រូវបានបញ្ជូន: [illegible] 1558 [illegible] 06.09.16 |
| ឈ្មោះអ្នកទទួលបន្ទុកកិច្ចការបញ្ជូន: លោក [illegible] |
| អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន: សាលាដំបូងរាជធានីភ្នំពេញ |
| ឈ្មោះជនដែលត្រូវទទួលការបញ្ជូន: [illegible] |

ហត្ថលេខា ឬស្នាមម្រាមដៃអ្នកទទួលឯកសារជាក់ស្តែង: ..........

ប្រអប់ខាងក្រោមត្រូវបំពេញដោយអ្នកប្រតិបត្តិការបញ្ជូន (កត្តាប្រៃសណីយ៍ អាជ្ញាសាលា ឬក្រឡាបញ្ជី)

| | |
|---|---|
| ទីកន្លែងដែលធ្វើការបញ្ជូន: [illegible] 122AE [illegible] 51 [illegible] | |
| កាលបរិច្ឆេទនៃការបញ្ជូន: ថ្ងៃទី 17 ខែ 11 ឆ្នាំ២០១6 ម៉ោង 3:30 ព្រឹក/រសៀល | |
| **វិធីជាក់ស្តែងក្នុងការបញ្ជូន** | |
| ☐១ | បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ |
| | ☐ ខ្ញុំបានពន្យល់ជូនជនដែលត្រូវទទួលការបញ្ជូន នូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូន ពីព្រោះជននោះមិនចេះអក្សរ |
| ☑២ | បានប្រគល់ឯកសារទៅឱ្យអ្នកដែលមានការយល់ដឹងសមរម្យចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់នៅទីកន្លែងដែលត្រូវបញ្ជូននោះទេ |
| | ☐ អ្នកបម្រើ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ ☐ អ្នកនៅជាមួយ |
| | ឈ្មោះ [illegible] |
| ☐៣ | ឯកសារត្រូវបានទុកនៅឯទីកន្លែងដែលត្រូវធ្វើការបញ្ជូន ដោយហេតុថា បុគ្គលខាងក្រោមនេះមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល |
| | ☐ ជនដែលត្រូវទទួលការបញ្ជូន ☐ អ្នកបម្រើ |
| | ☐ អ្នកនៅជាមួយ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ |
| | ឈ្មោះ .......... |
| ☑ | ខ្ញុំបានបញ្ជូនឯកសារតាមនីតិវិធីខាងលើ |
| ☐ | ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូន ខ្ញុំមិនបានជួបជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារ |
| កាលបរិច្ឆេទធ្វើរបាយការណ៍: ថ្ងៃទី 17 ខែ 11 ឆ្នាំ២០១6 | |
| ឈ្មោះ និងហត្ថលេខាអ្នកធ្វើរបាយការណ៍: [signature] | |

កំណត់សម្គាល់សម្រាប់អ្នកប្រតិបត្តិការបញ្ជូន:

១-ប្រសិនបើជនដែលទទួលឯកសារជាក់ស្តែង (ជនដែលត្រូវទទួលការបញ្ជូន ឬ បុគ្គលផ្សេង) មិនចេះសរសេរ ឬចុះហត្ថលេខា ឬមិនអាចផ្តិតម្រាមដៃបានទេ អ្នកប្រតិបត្តិការបញ្ជូនត្រូវចុះនិទ្ទេសពីការណ៍នោះនៅកន្លែង "ហត្ថលេខា ឬ ស្នាមម្រាមដៃអ្នកទទួលឯកសារជាក់ស្តែង"។

២-"ទីកន្លែងដែលបានធ្វើការបញ្ជូន" ត្រូវតែសរសេរឲ្យបានច្បាស់ៗ និងត្រឹមត្រូវ។

៣-ប្រសិនបើការបញ្ជូនបានធ្វើឡើងតាមចំណុចលេខ ១ អ្នកបញ្ជូនត្រូវគូស ☑ ហើយប្រសិនបើបានពន្យល់ជូនពីខ្លឹមសារសង្ខេបត្រូវគូស ☑ នៅក្នុងប្រអប់ដែរ។ ប្រសិនបើការបញ្ជូនបានធ្វើឡើងតាមចំណុចលេខ ២ ត្រូវគូស ☑ នៅក្នុងប្រអប់មុខលេខ២ ហើយត្រូវបញ្ជាក់ពីបុគ្គលទទួលដោយគូស ☑ នៅក្នុងប្រអប់កំណត់បុគ្គលទទួល និងសរសេរឈ្មោះបុគ្គលដែលបានទទួលនោះផង។ ប្រសិនបើការបញ្ជូនបានធ្វើឡើងតាមចំណុចលេខ ៣ អ្នកបញ្ជូនត្រូវគូស ☑ នៅក្នុងប្រអប់មុខលេខ៣ ហើយត្រូវបញ្ជាក់ពីបុគ្គលដែលមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផលនេះ ដោយការគូស ☑ នៅក្នុងប្រអប់កំណត់បុគ្គលដែលមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផលនោះ ដោយការគូស ☑ នៅក្នុងប្រអប់កំណត់បុគ្គលដែលមិនព្រមទទួលការបញ្ជូន ហើយត្រូវសរសេរឈ្មោះបុគ្គលដែលមិនព្រមទទួលការបញ្ជូននោះចូលផង។

៤-ក្នុងករណីដែលអ្នកធ្វើរបាយការណ៍មិនអាចធ្វើការបញ្ជូនឯកសារបានសម្រេច អ្នកធ្វើរបាយការណ៍នោះត្រូវគូស ☑ នៅក្នុងប្រអប់នៅពីមុខឃ្លាដែលសរសេរថា *"ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូន ខ្ញុំមិនបានជួបជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនេះ"*។

[illegible]

[illegible] 122 AE [illegible] 57 [illegible]

[illegible] 1558 [illegible] 06/09/2016

[illegible]

[illegible]

[illegible]

[illegible]

17/11/2016

# ឧបសម្ព័ន្ធទី៤

## សាលក្រមកំបាំងមុខ និង

## សាលក្រមដែលបានប្រកាស

## កំបាំងមុខភាគី

0120

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

**តុលាការរដ្ឋប្បវេណី**

សំណុំរឿងរដ្ឋប្បវេណីលេខ: ១៤១៨

ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩

**សាលក្រមលេខ: ១៥៤៤ "រ"**

**ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩**

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩

**ចៅក្រមជំនុំជម្រះ**

លោក **លិ សុខា** ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

លោក **តិច ប៉ូ** ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

**ដើមចោទ ៖** ធនាគារ ជ សាខា អាសយដ្ឋានផ្ទះលេខ រាជធានីភ្នំពេញ ។

**អ្នកតំណាងដោយអាណត្តិ ៖** លោក **ជួន ឧស្សាហ៍ អត្តលេខ:** ៦២១ មានការិយាល័យមេធាវី **ឧស្សាហ៍ និងសហភាតា** (OSAR LAW OFFICE & ASSOCIATE)_អាសយដ្ឋានផ្ទះលេខ ២៣៧ ផ្លូវលេខ ៤៤P ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

**សហចុងចម្លើយ ៖**

-ឈ្មោះ ច១ ភេទប្រុស កើតនៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៨២ សញ្ជាតិខ្មែរ មានអាសយដ្ឋាន រាជធានីភ្នំពេញ ។

-ឈ្មោះ ច២ ភេទប្រុស កើតនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៨២ សញ្ជាតិខ្មែរ មានអាសយដ្ឋាន រាជធានីភ្នំពេញ ។

## អង្គហេតុ និងចំណុចវិវាទ

### ក.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

**ក-១.**សុំបញ្ចប់ការអនុវត្តកិច្ចសន្យា ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ ។

**ក-២.**បង្គាប់ឱ្យសហចុងចម្លើយរួមគ្នាសងប្រាក់ដើមចំនួន USD **១៤៩,៤៤៦.៥០** (មួយរយសែសិបប្រាំបួនពាន់ បួនរយសែសិបប្រាំមួយ និងហាសិបសេនដុល្លារអាមេរិក) និងប្រាក់រៀលចំនួន **១៩៦.៣៨៣.២៥៧** (មួយរយកៅសិបប្រាំមួយលាន បីរយប៉ែតសិបបីពាន់ ពីររយហាសិបប្រាំពីរ)រៀល ។

**ក-៣.**បង្គាប់ឱ្យសហចុងចម្លើយរួមគ្នាសងការប្រាក់ក្នុងអត្រាការប្រាក់ចំនួន២៤% ក្នុងមួយឆ្នាំ គិតចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ សម្រាប់ឥណទានមានកាលកំណត់ទី១ (FL១) និងគិតចាប់ពីថ្ងៃ០៨ ខែឧសភា ឆ្នាំ២០១៩ សម្រាប់ឥណទានមានកាលកំណត់ទី២ (FL២) រហូតដល់ថ្ងៃសងគ្រប់ចំនួន ។

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

**ក-៤.**បង្គាប់ឱ្យសហចុងចម្លើយរួមគ្នាបង់ការប្រាក់យឺតយ៉ាវចំនួន ២៤% ក្នុងមួយឆ្នាំ សម្រាប់ឥណទានមានកាលកំណត់ទី១ (FL១) សម្រាប់ឥណទានមានកាលកំណត់ទី២ (FL២) គិតចាប់ពីថ្ងៃ១២ ខែសីហា ឆ្នាំ២០១៩ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

**ក-៥.**បង្គាប់ឱ្យសហចុងចម្លើយរួមគ្នាសងថ្លៃសេវាមេធាវី សោហ៊ុយធ្វើដំណើរ និងចំណាយផ្សេងៗជាប្រាក់ចំនួន **១៥,០០០** (ដប់ប្រាំពាន់ដុល្លារអាមេរិក) ។

**ក-៦.**ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។

**ក-៧.**សុំអនុវត្តបណ្តោះអាសន្ន ។

## ខ.ដំណើររឿងក្តី និងចំណុចវិវាទ៖

### ខ-១.ការសង្ខេបអំពីរឿងក្តី៖

ដើមចោទបានប្តឹងទាមទារឱ្យសហចុងចម្លើយសងប្រាក់ដើមដែលជាប្រាក់កម្ចីចំនួន USD ១៤៩,៤៤៦.៥០ (មួយរយសែសិបប្រាំបួនពាន់ បួនរយសែសិបប្រាំមួយ និងហាសិបសេនដុល្លារអាមេរិក) សម្រាប់ឥណទានមានកាលកំណត់ទី១ (FL១)ដែលមានទឹកប្រាក់ចំនួន USD **១៥០,០០០** (មួយរយហាសិបពាន់ដុល្លារអាមេរិក) ត្រូវសងតាមឥណប្រតិទានរយៈពេល១៥ឆ្នាំ និងបង់ប្រាក់ដើមដែលជាប្រាក់កម្ចីចំនួន **១៩៦.៣៨៣.២៥៧** (មួយរយកៅសិបប្រាំមួយលាន បីរយប៉ែតសិបបីពាន់ ពីររយហាសិបប្រាំពីរ)រៀល សម្រាប់ឥណទានមានកាលកំណត់ទី២ (FL២) ដែលមានទឹកប្រាក់ចំនួន **២០០.០០០.០០០** (ពីររយលាន)រៀល ត្រូវសងតាមឥណប្រតិទានរយៈពេល១០ឆ្នាំ ក្នុងអត្រាការប្រាក់៩%ក្នុងមួយឆ្នាំ ដោយផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ រវាងដើមចោទនិងសហចុងចម្លើយ។ លើសពីនេះ ដោយហេតុថាសហចុងចម្លើយពុំបានអនុវត្តកាតព្វកិច្ចក្នុងការបង់ប្រាក់ទៅឱ្យដើមចោទស្របតាមកិច្ចសន្យាដើមចោទបានទាមទារការប្រាក់ក្នុងអត្រា២៤% ក្នុងមួយឆ្នាំលើបំណុលសរុបចំពោះឥណទានមានកាលកំណត់ទាំងពីរខាងលើ ដោយគិតចាប់ពីថ្ងៃទី០៨ ខែមេសាឆ្នាំ២០១៩ សម្រាប់ឥណទានមានកាលកំណត់ទី១ (FL១) និងគិតចាប់ពីថ្ងៃ០៨ ខែឧសភា ឆ្នាំ២០១៩ សម្រាប់ឥណទានមានកាលកំណត់ទី២ (FL២) រហូតដល់ថ្ងៃសងគ្រប់ចំនួន ។

### ខ-២.អង្គហេតុដែលគ្មានវិវាទ

**ខ.២.១.**ការបង្កើតកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ ដែលដើមចោទបានផ្តល់ឥណទានមានកាលកំណត់ដល់សហចុងចម្លើយចំនួន២ប្រភេទ ដោយឥណទានមានកាលកំណត់ទី១ (FL១) ដែលមានទឹកប្រាក់ចំនួន USD **១៥០,០០០** (មួយរយហាសិបពាន់ដុល្លារអាមេរិក) ត្រូវសងតាមឥណប្រតិទានរយៈពេល១៥ឆ្នាំ និងឥណទានមានកាលកំណត់ទី២ (FL២) ដែលមានទឹកប្រាក់ចំនួន **២០០.០០០.០០០ (ពីររយលាន) រៀល** ត្រូវសងតាមឥណប្រតិទានរយៈពេល១០ឆ្នាំ ក្នុងអត្រាការប្រាក់ ៩% ក្នុងមួយឆ្នាំ ។

**ខ.២.២.**ការបង្កើតកិច្ចសន្យាហ៊ីប៉ូតែក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ ដែលមានទ្រព្យហ៊ីប៉ូតែកជាផ្ទះ៣ជាន់ ១ល្វែង មានទីតាំងស្ថិតនៅក្បាលដីលេខ ១០២០ ភូមិត្រពាំងគល់ សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ និងមានប័ណ្ណកម្មសិទ្ធិលេខ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧ ដើម្បីជាការធានាទូវការខ្ចីប្រាក់ខាងលើ ។

**ខ.២.៣.**សហចុងចម្លើយបានទទួលប្រាក់ចំនួន USD ១៥០,០០០(មួយហាសិបពាន់ដុល្លារអាមេរិក) និងចំនួន

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

២០០.០០០.០០០ (ពីររយលាន) រៀលពីដើមចោទ ។

**ខ.២.៤.** ប្រាក់ដើមដែលនៅជំពាក់មានចំនួន USD ១៤៩,៤៤៦.៥០(មួយរយសែសិបប្រាំបួនពាន់ បួនរយសែសិបប្រាំមួយ និងហាសិបសេន)ដុល្លារអាមេរិកនិងប្រាក់រៀលចំនួន១៩៦.៣៨៣.២៥៧ (មួយរយកៅសិបប្រាំមួយលាន បីរយប៉ែតសិបបីពាន់ ពីររយហាសិបប្រាំពីរ)រៀល ។

**ខ.៣ ចំណុចវិវាទ៖** គ្មាន

**ខ.៤ ការអះអាងរបស់ភាគី៖**

***ក-ការអះអាងរបស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ៖***

-កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ សហចុងចម្លើយបានព្រមព្រៀងធ្វើកិច្ចសន្យាខ្ចីបរិភោគជាមួយដើមចោទជាធនាគារធនាគារ ង សាខា ដែលជាកូនក្តីខ្លួន ដោយទទួលបាននូវឥណទានចំនួន២គឺ៖ ឥណទានទី១(FL១) ចំនួន USD ១៥០,០០០ (មួយរយហាសិបដុល្លារអាមេរិក)មានអត្រាការប្រាក់៩%ក្នុងមួយឆ្នាំ ដោយសហចុងចម្លើយធ្វើការបង់រំលោះទាំងប្រាក់ដើម និងការប្រាក់ចំនួន ១៨០ លើក ក្នុង១លើកៗ (១ខែម្តង) ស្មើនឹងទឹកប្រាក់ចំនួន USD ១,៥៣៣ (មួយពាន់ប្រាំរយសាមសិបបីដុល្លារអាមេរិក) និងឥណទានទី២ (FL២) ចំនួន ២០០,០០០,០០០ (ពីររយលាន)រៀល មានអត្រាការប្រាក់៩% ក្នុងមួយឆ្នាំ ដោយសហចុងចម្លើយធ្វើការបង់រំលោះទាំងប្រាក់ដើម និងការប្រាក់ចំនួន១២០លើក ក្នុង១លើកៗ (១ខែម្តង) ស្មើនឹងចំនួន ២.៥៤៧.១០០ (ពីរលាន ប្រាំរយសែសិបប្រាំពីរពាន់មួយរយ)រៀល និងបានយល់ព្រមឱ្យធនាគាររបស់កូនក្តីខ្លួនពិន័យការយឺតយ៉ាវចំនួន១% បន្ថែមលើអត្រាការប្រាក់ធម្មតា ដោយឡែកករណីមានការទូទាត់សងហួសពេលកំណត់បំពានល័ក្ខខ័ណ្ឌនៃការសង នឹងត្រូវអនុវត្តតាមអត្រាការប្រាក់ចំនួន២៤% លើបំណុលទាំងអស់ ។ សហចុងចម្លើយបានដាក់ទ្រព្យហ៊ីប៉ូតែក ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ដើម្បីធានាបំណុល ។ តាំងពីចុះកិច្ចសន្យាខ្ចីបរិភោគរហូតមកដល់បច្ចុប្បន្ន ចំពោះឥណទានទី១(FL១) ចំនួន USD ១៥០,០០០ (មួយរយហាសិបពាន់ដុល្លារអាមេរិក) សហចុងចម្លើយបានបង់ប្រាក់មកឱ្យកូនក្តីខ្លួនបានមួយចំនួនក៏អាក់ខានបង់ប្រាក់មកឱ្យកូនក្តីខ្លួនចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩រហូតដល់សព្វថ្ងៃនេះ ដោយនៅជំពាក់ដើមចំនួន USD ១៤៩,៤៤៦.៥០(មួយរយសែសិបប្រាំបួនពាន់ បួនរយសែសិបប្រាំមួយ និងហាសិបសេនដុល្លារអាមេរិក)។ នៅពេលកូនបំណុលអាកខានបង់ប្រាក់នោះកូនក្តីខ្លួនបានធ្វើលិខិតរំលឹកអំពីបំណុលដែលហួសកាលកំណត់ទៅកូនបំណុល*(លិខិតចុះថ្ងៃទី២៤ខែធ្នូ ឆ្នាំ២០១៨)*។ ចំពោះឥណទានទី២(FL២)ចំនួន ២០០.០០០.០០០ (ពីររយលាន)រៀល សហចុងចម្លើយបានបង់ប្រាក់មកឱ្យកូនក្តីខ្លួនបានមួយចំនួនក៏អាក់ខានបង់ប្រាក់មកឱ្យកូនក្តីខ្លួនចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩រហូតដល់សព្វថ្ងៃនេះ ដោយនៅជំពាក់ដើមចំនួន ១៩៦.៣៨៣.២៥៧ (មួយកៅសិបប្រាំមួយលាន បីរយប៉ែតសិបបីពាន់ ពីររយហាសិបប្រាំពីរ)រៀល។ លុះដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ខ្លួនបានធ្វើលិខិតជូនដំណឹងទៅកូនបំណុលឈ្មោះ ច១ **និងឈ្មោះ** ច២ ឱ្យអញ្ជើញទៅបំពេញកាតព្វកិច្ចជូនធនាគារ ង *(លិខិតជូនដំណឹងចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩)* ទោះបីកូនក្តីខ្លួន និងខ្លួនធ្វើជូនដំណឹងឱ្យកូនបំណុលមក អនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនជាមួយធនាគាររួចហើយ តែកូនបំណុលមិនបានមកអនុវត្តកាតព្វកិច្ចរបស់ខ្លួនដដែល។ ក្រោយមកកូនក្តីខ្លួនបានធ្វើលិខិតទារប្រាក់កម្ចីទាំងស្រុងមកឱ្យខ្លួនចេញលិខិតទាមទារបំណុលទាំងអស់ជួសមុខឱ្យធនាគារពីអ្នកសុំខ្ចី *(លិខិតទារប្រាក់កម្ចីទាំងស្រុង)* ។ នៅពេលខ្លួនជូនដំណឹងរួចខ្លួនក៏បានចេញលិខិតជូនដំណឹងទៅកូនបំណុលឱ្យទៅបំពេញកាតព្វកិច្ច ង

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

កុំបីខាន*(លិខិតជូនដំណឹង ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩)* ទោះបីកូនក្តីខ្លួនក៏ដូចជារូបខ្លួនផ្ទាល់ខិតខំព្យាយាមធ្វើលិខិតជូនដំណឹងទៅកូនបំណុលយ៉ាងណាក៏ដោយ នៅតែកូនបំណុលពុំមកអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ដដែល។ ផ្អែកតាមការព្រមព្រៀងក្នុងកិច្ចសន្យាកាលណាសហចុងចម្លើយមិនអនុវត្តការបង់រំលោះរយៈពេល ៣ ខែជាប់ៗគ្នានោះអត្រាការប្រាក់ ៩% ក្នុងមួយឆ្នាំ នឹងត្រូវកើនទៅ ២៤% ក្នុងមួយឆ្នាំ ទើបខ្លួនប្តឹងសុំឱ្យតុលាការចេញសាលក្រមតាមការទាមទារដែលមាននៅក្នុងចំណុច(ក)ខាងលើ។

***ខ-ការដោះសារបស់ភាគីសហចុងចម្លើយ៖***

-សហចុងចម្លើយឈ្មោះ ច១ និងឈ្មោះ ច២ បានទទួលដីកាកោះហៅឱ្យចូលសាលាដំបូងរាជធានីភ្នំពេញពីអ្នករត់ដីកាកោះប្រចាំសាលាដំបូងរាជធានីភ្នំពេញគ្រប់នីតិវិធីរួចហើយ ប៉ុន្តែសហចុងចម្លើយមិនចូលរួមតាមកំណត់របស់តុលាការ ដោយគ្មានមូលហេតុឡើយ ។

## គ.ការពិនិត្យភស្តុតាង

***គ-១.ភស្តុតាងដែលដើមចោទដាក់ជូនតុលាការពិនិត្យ៖***

-កិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ ។

-លិខិតរំលឹកអំពីបំណុលដែលហួសការកំណត់ ចុះថ្ងៃ២៤ ខែធ្នូ ឆ្នាំ២០១៨។

-លិខិតទារប្រាក់កម្ចីទាំងស្រុង ។

-លិខិតបំពេញកាតព្វកិច្ចជូនធនាគារ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩។

-លិខិតជូនដំណឹង ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩ ។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ។

-តារាងសង្ខេបបំណុលចុងក្រោយ (ថតចម្លងចំនួន ០២ច្បាប់) ។

## សំអាងហេតុ

***ក.ស្តីពីការបញ្ចប់ការអនុវត្តកិច្ចសន្យាខ្ចីបរិភោគ***

-ផ្អែកតាមភស្តុតាងជាលិខិតទារប្រាក់កម្ចីទាំងស្រុង ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ បានបង្ហាញឱ្យតុលាការឃើញថា ដើមចោទពិតជាបានធ្វើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរទៅដល់សហចុងចម្លើយ ដើម្បីដាស់តឿនឱ្យសហចុងចម្លើយអនុវត្តកាតព្វកិច្ចស្របតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ ថែមទាំងបានបង្ហាញឆន្ទៈថាប្រសិនជាសហចុងចម្លើយមិនបានធ្វើតាមការដាស់តឿនទេ ដើមចោទនឹងសុំបញ្ចប់ការអនុវត្តកិច្ចសន្យាខ្ចីបរិភោគ ដូច្នេះគប្បីតុលាការយកការទាមទាររបស់ដើមចោទមកធ្វើការពិចារណាសម្រេច ។

***ខ.ស្តីពីប្រាក់ដើមចំនួន USD ១៤៩,៤៤៦.៥០ (មួយរយសែសិបប្រាំបួនពាន់ បួនរយសែសិបប្រាំមួយ និងហាសិបសេនដុល្លារអាមេរិក និងប្រាក់រៀលចំនួន១៩៦.៣៨៣.២៥៧(មួយរយកៅសិបប្រាំមួយលាន បីរយប៉ែតសិបបីពាន់ ពីររយហាសិបប្រាំពីរ) រៀល។***

-ផ្អែកតាមភស្តុតាងកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ ,លិខិតជូនដំណឹង ,លិខិតទារប្រាក់កម្ចីទាំងស្រុង និងតារាងសង្ខេបបំណុលចុងក្រោយដែលដើមចោទបានដាក់ជូនតុលាការពិនិត្យ និង

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្ដីជាក់ស្ដែង ហើយមិនមែនជាសាលក្រមគំរូទេ

ការអះអាងរបស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ ដែលមានលក្ខណៈស៊ីសង្វាក់គ្នា នាំឱ្យតុលាការទទួលស្គាល់ថា ៖

**ខ-១.**ដើមចោទជាធនាគារកម្ពុជាសាធារណៈ ភីអិលស៊ីសាខាតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ពិតជាបានបង្កើតនូវកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ ជាមួយនឹងសហចុងចម្លើយ ដោយផ្ដល់ឱ្យសហចុងចម្លើយនូវឥណទានចំនួន២គឺ៖ ឥណទានមានកាលកំណត់ទី១ (FL១) មានទឹកប្រាក់ចំនួន ១ USD ៥០,០០០ (មួយរយហាសិបដុល្លារអាមេរិក មានអត្រាការប្រាក់ ៩% ក្នុងមួយឆ្នាំ ដោយសហចុងចម្លើយធ្វើការបង់រំលោះទាំងប្រាក់ដើម និងការប្រាក់ចំនួន ១៨០លើក ក្នុង១លើក១ (១ខែម្ដង) ស្មើនឹងចំនួន USD ១,៥៣៣ (មួយពាន់ ប្រាំរយសាមសិបបីដុល្លារអាមេរិក) និងឥណទានទី២ (FL២) មានទឹកប្រាក់ចំនួន ២០០.០០០.០០០ (ពីររយលាន) រៀល មានអត្រាការប្រាក់ ៩% ក្នុងមួយឆ្នាំ ដោយសហចុងចម្លើយធ្វើការបង់រំលោះទាំងប្រាក់ដើម និងការប្រាក់ចំនួន១២០លើក ក្នុង១លើក១(១ខែម្ដង)ស្មើនឹងចំនួន ២.៥៤៧.១០០ (ពីរលាន ប្រាំរយសែសិបប្រាំពីរពាន់ មួយរយ) រៀល ពិតប្រាកដមែន ។

**ខ-២.**ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ អ្នកតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្ដីថ្លែងការណ៍ និងធ្វើសេចក្ដីសន្និដ្ឋានថា រវាងកូនក្ដីរបស់ខ្លួន និងសហចុងចម្លើយពិតជាបានធ្វើកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ ដោយឥណទានទី១ (FL១) មានទឹកប្រាក់ចំនួន USD ១៥០,០០០ (មួយរយហាសិបដុល្លារអាមេរិក) សហចុងចម្លើយបានបង់ឱ្យកូនក្ដីខ្លួនបានមួយចំនួនរួចហើយដោយនៅជំពាក់ប្រាក់ដើមចំនួន ១៤៩,៤៤៦.៥០ (មួយរយសែសិបប្រាំបួនពាន់ បួនរយសែសិបប្រាំមួយ និងហាសិបសេនដុល្លារអាមេរិក) និងឥណទានទី២ (FL២) មានទឹកប្រាក់ចំនួន ២០០.០០០.០០០(ពីររយលាន)រៀលសហចុងចម្លើយបង់បានមួយចំនួនក៏អាក់ខានបង់ ដោយនៅជំពាក់ចំនួន១៩៦.៣៨៣.២៥៧ (មួយរយកៅសិបប្រាំមួយលាន បីរយប៉ែតសិបបីពាន់ ពីររយហាសិបប្រាំពីរ) រៀល ។

**ខ-៣.**ភាគីសហចុងចម្លើយបានទទួលដីកាកោះហៅឱ្យចូលរួមគ្រប់នីតិវិធីរបស់តុលាការរួច ប៉ុន្តែភាគីសហចុងចម្លើយមិនបានចូលរួមក្នុងនីតិវិធីតាមការកំណត់របស់តុលាការឡើយ ថែមទាំងមិនបានជូនដំណឹងអំពីការអាក់ខានមិនបានចូលរួម ឬ ជូនដំណឹងអំពីការពន្យារពេលចូលរួមនីតិវិធីណាមួយនោះទេ តាមបញ្ញត្តិមាត្រា២០១នៃក្រមនីតិវិធីរដ្ឋប្បវេណី ក្នុងករណីចុងចម្លើយអវត្តមាននៅដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។ បើភាគីចុងចម្លើយមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់តុលាការត្រូវចាត់ទុកថា ភាគីចុងចម្លើយបានសារភាពតាមសេចក្ដីថ្លែងការណ៍របស់ភាគីដើមចោទដែលទាក់ទងទៅនឹងអង្គហេតុ ដែលសហចុងចម្លើយពិតជាបានខ្ចី និងទទួលបានឥណទានចំនួន ២ ពីដើមចោទ គឺឥណទានមានកាលកំណត់ទី១(FL១) ចំនួន USD ១៥០.០០០ (មួយរយហាសិបដុល្លារអាមេរិក) មានអត្រាការប្រាក់ ៩% ក្នុងមួយឆ្នាំ ដោយសហចុងចម្លើយបានបង់សងបានមួយចំនួនហើយនៅជំពាក់ចំនួន **USD ១៤៩,៤៤៦.៥០**(មួយរយសែសិបប្រាំបួនពាន់ បួនរយសែសិបប្រាំមួយ និងហាសិបសេន) ដុល្លារអាមេរិក និងឥណទានមានកាលកំណត់ទី២(FL២) ចំនួន ២០០.០០០.០០០ (ពីររយលាន) រៀល មានអត្រាការប្រាក់ ៩% ក្នុងមួយឆ្នាំ ដោយសហចុងចម្លើយបានបង់សងបានមួយចំនួន ហើយនៅជំពាក់ចំនួន **១៩៦.៣៨៣.២៥៧** (មួយរយកៅសិបប្រាំមួយលាន បីរយប៉ែតសិបបីពាន់ ពីររយហាសិបប្រាំពីរ) រៀល ដូចមានក្នុងកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ ពិតប្រាកដមែន ដូច្នេះគប្បីឱ្យតុលាការពិចារណាសម្រេចចេញសាលក្រមកំបាំងមុខតាមមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**ខ-៤.**ផ្អែកលើសេចក្ដីថ្លែងការណ៍និងភស្តុតាងនានាឃើញថាប្រាក់ដើមដែលសហចុងចម្លើយនៅជំពាក់មានចំនួន USD ១៤៩,៤៤៦.៥០ (មួយរយសែសិបប្រាំបួនពាន់ បួនរយសែសិបប្រាំមួយ និងហាសិបសេនដុល្លារអាមេរិក) និងប្រាក់

រៀលចំនួន១៩៦.៣៨៣.២៥៧ (មួយរយកៅសិបប្រាំមួយលាន បីរយប៉ែតសិបបីពាន់ ពីររយហាសិបប្រាំពីរ)រៀល ប្រាកដមែន ដែលបង្ហាញថាដើមចោទពិតជាមានអត្ថិភាពនៃសិទ្ធិទាមទារតាមផ្លូវច្បាប់ ដូច្នេះគប្បីតុលាការបង្គាប់ឱ្យសហចុងចម្លើយរួមគ្នាសងប្រាក់ដើមទៅដើមចោទតាមការទាមទារខាងលើ ។

***គ.ចំណុចស្តីពីការប្រាក់ក្នុងអត្រាចំនួន២៤%ក្នុងមួយឆ្នាំគិតចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ សម្រាប់ឥណទាន មានកាលកំណត់ទី១ (FL១) និងគិតចាប់ពីថ្ងៃ០៨ ខែឧសភា ឆ្នាំ២០១៩ សម្រាប់ឥណទានមានកាលកំណត់ទី២(FL ២) រហូតដល់ថ្ងៃសងគ្រប់ចំនួន***

**គ-១.**ផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ បង្ហាញថា ការប្រាក់ចំពោះឥណទានមានកាលកំណត់ទាំង ២ (FL១ និង FL២) ដែលបានកំណត់ក្នុងកិច្ចសន្យានេះមានចំនួន៩%ក្នុងមួយឆ្នាំ។ ទន្ទឹមនឹងនេះដែរភាគីដើមចោទនិងភាគីសហចុងចម្លើយបានព្រមព្រៀងគ្នាក្នុងកិច្ចសន្យាថាកាលណាសហចុងចម្លើយមិនអនុវត្តការបង់រំលោះរយៈពេល ៣ ខែ ជាប់ៗគ្នានោះអត្រាការប្រាក់ ៩% ក្នុងមួយឆ្នាំ នឹងត្រូវកើនទៅ ២៤% ក្នុងមួយឆ្នាំ ។

**គ-២.**យោងតាមមាត្រា៥៨៥ នៃក្រមរដ្ឋប្បវេណី ភាគីនៃកិច្ចសន្យាខ្ចីបរិភោគអាចព្រមព្រៀងគ្នាកំណត់ពីអត្រាការប្រាក់បាន ប៉ុន្តែអត្រាការប្រាក់នោះមិនត្រូវលើសពីអត្រាការប្រាក់ដែលច្បាប់បានកំណត់ឡើយ ។ បើពិនិត្យក្នុងប្រការ១ នៃប្រកាសលេខ ១២៨ កយ.ប្រក/១១ របស់ក្រសួងយុត្តិធម៌ ក៏បានកំណត់ថាអត្រាការប្រាក់នេះត្រូវកំណត់មិនឱ្យលើសពី ១៨%ក្នុងមួយឆ្នាំ។ ករណីនេះ តុលាការយល់ឃើញថា គូភាគីបានព្រមព្រៀងចំពោះអត្រាការប្រាក់រហូតដល់ ២៤% ក្នុងមួយឆ្នាំដែលជាអត្រាការប្រាក់មានលក្ខណៈលើសពីការកំណត់របស់ច្បាប់អំពីអត្រាការប្រាក់ នាំឱ្យការកំណត់អត្រាការប្រាក់របស់គូភាគីខាងលើជាការកំណត់ដែលមានលក្ខណៈមិនត្រឹមត្រូវតាមកំណត់ច្បាប់ គប្បីតុលាការបន្ថយនូវអត្រាការប្រាក់នោះមកត្រឹម ១៨% ក្នុងមួយឆ្នាំ ស្របតាមបញ្ញត្តិនៃច្បាប់ ។

**គ-៣.**ផ្អែកតាមសេចក្តីថ្លែងការណ៍របស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ បង្ហាញឱ្យឃើញថា ប្រាក់ដើមដែលសហចុងម្លើយបានជំពាក់ដើមចោទរួមមាន ៖

-ឥណទានមានកាលកំណត់ទី១(FL១)៖ សហចុងចម្លើយនៅជំពាក់ប្រាក់ដើមចំនួនUSD១៤៩,៤៤៦.៥០ (មួយរយសែសិបប្រាំបួនពាន់ បួនរយសែសិបប្រាំមួយ និងហាសិបសេនដុល្លារអាមេរិក) រីឯការខកខានបង់ប្រាក់តាំងពីថ្ងៃ០៨ ខែមេសា ឆ្នាំ២០១៩ ។

-ឥណទានមានកាលកំណត់ទី២(FL២)៖សហចុងចម្លើយនៅជំពាក់ប្រាក់ដើមជាប្រាក់រៀលចំនួន១៩៦.៣៨៣.២៥៧ (មួយរយកៅសិបប្រាំមួយលាន បីរយប៉ែតសិបបីពាន់ ពីររយហាសិបប្រាំពីរ) រៀល រីឯការខកខានបង់ប្រាក់តាំងពីថ្ងៃ០៨ ខែឧសភា ឆ្នាំ២០១៩ ។

ដូចនេះដើមចោទមានអត្ថិភាពក្នុងការទាមទារឱ្យសហចុងចម្លើយបង់ការប្រាក់ ក្នុងអត្រាការប្រាក់ចំនួន ១៨% ក្នុងមួយឆ្នាំ លើបំណុលទាំងអស់***គិតចាប់ពីថ្ងៃ០៨ ខែឧសភា ឆ្នាំ២០១៩ ដល់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩*** ។

***ឃ.ចំណុចស្តីពីអត្រាការប្រាក់យឺតយ៉ាវចំនួន២៤%ក្នុងមួយឆ្នាំគិតចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ រហូតដល់សងប្រាក់គ្រប់ចំនួន សម្រាប់ឥណទានមានកាលកំណត់ទី១ (FL១) និងសម្រាប់ឥណទានមានកាលកំណត់ទី២(FL២) ។***

-ផ្អែកតាមការអះអាងរបស់ភាគីដើមចោទបានបញ្ជាក់ថា គូភាគីបានព្រមព្រៀងគ្នាអំពីប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវនៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានអត្រាស្មើនឹង២៤% (ម្ភៃបួនភាគរយ) ដែល

អត្រាការប្រាក់យឺតយ៉ាវនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់កំណត់ ។ ដូច្នេះគប្បីឱ្យតុលាការពិចារណាសម្រេចតាមការទាមទាររបស់ភាគីដើមចោទ យោងតាមមាត្រា ៤០៣ នៃក្រមរដ្ឋប្បវេណី និងមាត្រា ១៧ កថាខណ្ឌទី ៦ នៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី។

***ង.ចំណុចស្ដីពីការទាមទារថ្លៃសេវាមេធាវីសោហ៊ុយធ្វើដំណើរ និងចំណាយផ្សេងៗជាប្រាក់ចំនួន ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក***

-តាមការអះអាងរបស់ភាគីដើមចោទបានប្ដឹងទាមទារថ្លៃសេវាមេធាវី សោហ៊ុយធ្វើដំណើរ និងចំណាយផ្សេងៗជាទឹកប្រាក់ចំនួន USD ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក នោះមានលក្ខណៈត្រឹមត្រូវ ដោយសារភាគីសហចុងចម្លើយមិនបានអនុវត្តតាមកិច្ចសន្យាខ្ចីបរិភោគ ដែលជាហេតុធ្វើឱ្យភាគីដើមចោទដាក់ពាក្យបណ្ដឹងទាមទារប្រាក់តាមប្រព័ន្ធតុលាការនោះ ពិតជាធ្វើឱ្យភាគីដើមចោទបានចំណាយសោហ៊ុយសេវាផ្លូវច្បាប់សោហ៊ុយធ្វើដំណើរប្រាកដមែន ប៉ុន្តែការប្ដឹងទាមទាររបស់ភាគីដើមចោទមានលក្ខណៈច្រើនពេក ដូច្នេះគប្បីតុលាការចេញសាលក្រមសម្រេចឱ្យភាគីសហចុងចម្លើយសងថ្លៃសេវាមេធាវី សោហ៊ុយធ្វើដំណើរនិងចំណាយផ្សេងៗទៅឱ្យភាគីដើមចោទនូវចំនួនទឹកប្រាក់សមរម្យស្របនឹងការចំណាយរបស់ភាគីដើមចោទ ។

***ច.ចំណុចស្ដីពីបន្ទុកលើប្រាក់ប្រដាប់ក្ដី៖***

-ប្រាក់ប្រដាប់ក្ដីត្រូវអនុវត្តទៅតាមកថាខណ្ឌទី១ មាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដូច្នេះគប្បីតុលាការសម្រេចឱ្យសហចុងចម្លើយជាអ្នកទទួលបន្ទុកលើប្រាក់ប្រដាប់ក្ដី ។

***ឆ.ចំណុចស្ដីពីការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន៖***

-ដើមចោទបានប្ដឹងសុំឱ្យតុលាការសម្រេចប្រកាសអនុវត្តជាបណ្ដោះអាសន្ន តុលាការយល់ឃើញថា ការទាមទាររបស់ដើមចោទនោះ មិនមានភាពចាំបាច់ដែលធ្វើឱ្យតុលាការធ្វើការប្រកាសអនុវត្តជាបណ្ដោះអាសន្ននោះឡើយ ដូច្នេះគប្បីតុលាការធ្វើការច្រានចោលការទាមទារនូវចំណុចនេះប្ដឹងសុំទាមទារឱ្យប្រកាសអនុវត្តជាបណ្ដោះអាសន្ន ។

## <u>សេចក្ដីសម្រេចបញ្ចប់</u>

**១.**បញ្ចប់ការអនុវត្តកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ រវាងដើមចោទ ជ

និងសហចុងចម្លើយឈ្មោះ ច១ និងឈ្មោះ ច២ ។

**២.**បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ ច១ និងឈ្មោះ ច២ បង់ប្រាក់ចំនួន USD **១៤៩,៤៤៦.៥០** (មួយរយសែសិបប្រាំបួនពាន់ បួនរយសែសិបប្រាំមួយនិងហាសិបសេនដុល្លារអាមេរិក)និងប្រាក់រៀលចំនួន **១៩៦.៣៨៣.២៥៧ (មួយរយកៅសិបប្រាំមួយលាន បីរយប៉ែតសិបបីពាន់ ពីររយហាសិបប្រាំពីរ)** រៀល និងប្រាក់ក្នុងអត្រា **១៨%** ក្នុង០១ឆ្នាំ នៃប្រាក់នេះគិតចាប់ពីថ្ងៃ០៨ ខែឧសភា ឆ្នាំ២០១៩ ដល់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ទៅឱ្យដើមចោទ ជ

។

**៣.**បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ ច១ និងឈ្មោះ ច២ បង់ការប្រាក់យឺតយ៉ាវ២៤% ក្នុង០១ឆ្នាំ លើប្រាក់ USD **១៤៩,៤៤៦.៥០**(មួយរយសែសិបប្រាំបួនពាន់ បួនរយសែសិបប្រាំមួយ និងហាសិបសេនដុល្លារអាមេរិក) និងប្រាក់រៀលចំនួន**១៩៦.៣៨៣.២៥៧(មួយរយកៅសិបប្រាំមួយលាន បីរយប៉ែតសិបបីពាន់ ពីររយហាសិបប្រាំពីរ)**រៀល គិតចាប់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ រហូតដល់សងប្រាក់គ្រប់ចំនួន។

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

៤.បង្គាប់ឱ្យសហចុងចម្លើយរួមគ្នាសងថ្លៃសេវាមេធាវី សោហ៊ុយធ្វើដំណើរ និងចំណាយផ្សេងៗជាទឹកប្រាក់ចំនួន ៦,០០០,០០០ (ប្រាំមួយលាន)រៀល ។ ការទាមទារលើសពីនេះបដិសេធចោល។

៥. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។

៦. ច្រានចោលនូវការទាមទារប្រកាសជាបណ្តោះអាសន្នរបស់ដើមចោទ។

សាលក្រមនេះត្រូវបានប្រកាសនៅសវនាការជាសាធារណៈ នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩។ ក្នុងករណីដែលប្តឹងទាស់ ត្រូវធ្វើឡើងក្នុងរយៈពេល២សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រមនេះ ។

**ចៅក្រម**

ហត្ថលេខា និងត្រា : **លិ សុខា**

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ ព្រហស្បតិ៍ ៩ កើត ខែ មិគសិរ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

តិច-ប៊ុ

**បានឃើញ**

**ចៅក្រម**

លិ_សុខា

0156

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមរដ្ឋប្បវេណី**

-លេខ ១១៧ "ឥ"

ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០

-សំណុំរឿងរដ្ឋប្បវេណីលេខ ១៥៣១

ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង ០៩ និង០០នាទីព្រឹក និងប្រកាសសាលក្រមនៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០ លើសំណុំរឿងរដ្ឋប្បវេណីលេខ ១៥៣១ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

-លោក **សំ ម៉ុនពៅ** ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

-លោក **សន គីមសាន** ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

-ដើមចោទ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** **ក** ដែលមានអាសយដ្ឋានការិយាល័យកណ្តាលអាគារលេខ រាជធានីភ្នំពេញ ដែលតំណាងដោយលោកមេធាវី **ស៊ីវ ភ័ក្ត្រា** អត្តលេខ ១៧៩៣T ជាមេធាវីនៅក្រុមមេធាវី ផាន់ ពៅស៊ាង មានការិយាល័យនៅអាគារលេខ៥១៥ ជាន់ទី៧ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ។

-សហចុងចម្លើយឈ្មោះ **ច១** ភេទស្រី អាយុ២៣ឆ្នាំ ជនជាតិខ្មែរ និងប្តីឈ្មោះ **ច២** អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិ រាជធានីភ្នំពេញ រួមទាំងម្តាយឈ្មោះ **ច៣** ភេទស្រី អាយុ៥៥ឆ្នាំ ជនជាតិខ្មែរ និងឪពុកឈ្មោះ **ច៤** អាយុ៥៨ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិ រាជធានីភ្នំពេញ។

## I. អង្គហេតុ និងចំណុចវិវាទ

**១.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ៖**

-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ **ច១** ភេទស្រី អាយុ២៣ឆ្នាំ ជនជាតិខ្មែរ និងប្តីឈ្មោះ **ច២** អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ រួមទាំងម្តាយឈ្មោះ **ច៣** ភេទស្រី អាយុ៥៥ឆ្នាំ ជនជាតិខ្មែរ និងឪពុកឈ្មោះ **ច៤** អាយុ៥៨ឆ្នាំ ត្រូវជាអ្នកខ្ចី រួមគ្នាសងប្រាក់ដើមដែលនៅជំពាក់ដូចខាងក្រោម៖

**កម្ចីទី០១**

-ប្រាក់ដើមចំនួន USD ១៩,៥១៦.៦៦ (ដប់ប្រាំបួនពាន់ប្រាំរយដប់ប្រាំមួយដុល្លារអាមេរិកគត់ និងហុកសិបប្រាំមួយសេនគត់) និងអត្រាការប្រាក់ ១.១៥% (មួយក្បៀសដប់ប្រាំភាគរយ) ក្នុងមួយខែ លើប្រាក់ដើមចំនួន USD ១៩,៥១៦.៦៦ ដោយគិតចាប់ពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន ព្រមទាំងប្រាក់ពិន័យ ២% (ពីរភាគរយ) ក្នុងមួយខែ លើប្រាក់ដើមចំនួន USD ១៩,៥១៦.៦៦ គិតចាប់ពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤ (ករណីហួសកាលកំណត់សងចុងក្រោយនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤) រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន។

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

-ទាមទារសេវាទូទាត់ឥណទានមុនរយៈពេលប្រើប្រាស់អប្បរមាចំនួន USD ៥៨៥.៤៩ (ប្រាំរយប៉ែតសិបប្រាំដុល្លារអាមេរិក និងសែសិបប្រាំបួនសេនគត់)។

-ទាមទារការប្រាក់ដែលសងយឺតយ៉ាវចំនួន USD ១,៩៨៧.៥៩ (មួយពាន់ប្រាំបួនរយប៉ែតសិបប្រាំពីរដុល្លារអាមេរិក និងហាសិបប្រាំបួនសេនគត់) ជាទឹកប្រាក់គិតពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩។

**កម្ចីទី០២៖**

-ប្រាក់ដើមចំនួន USD ១,៦២៥.១៥ (មួយពាន់ប្រាំមួយរយម្ភៃប្រាំដុល្លារអាមេរិក និងដប់ប្រាំសេនគត់) និងអត្រាការប្រាក់ចំនួន ១.៤% (មួយក្បៀសបួនភាគរយ) ក្នុងមួយខែ លើប្រាក់ដើមចំនួន USD ១,៦២៥.១៥ ដោយគិតចាប់ពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន ព្រមទាំងប្រាក់ពិន័យ ២% (ពីរភាគរយ) ក្នុងមួយខែ លើប្រាក់ដើមចំនួន USD ១,៦៤៣.៦៩ គិតចាប់ពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១ (ករណីហួសកាលកំណត់សងចុងក្រោយនៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១) រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន។

-ទាមទារសេវាទូទាត់ឥណទានមុនរយៈពេលប្រើប្រាស់អប្បរមាចំនួន USD ៤៨.៧៥ (សែសិបប្រាំបីដុល្លារអាមេរិក និងចិតសិបប្រាំសេនគត់)។

-ទាមទារការប្រាក់ដែលសងយឺតយ៉ាវចំនួន USD ៧.៥៥ (ប្រាំពីរដុល្លារអាមេរិក និងហាសិបប្រាំសេនគត់) ជាទឹកប្រាក់គិតពីថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩។

២-ទាមទារថ្លៃខាតបង់ពេលវេលាចំនួន USD ៦,០០០ (ប្រាំមួយពាន់ដុល្លារអាមេរិកគត់)។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

៤-សុំអនុវត្តជាបណ្តោះអាសន្ន ត្រង់ចំណុចទី១ លើប្រាក់ដើមសរុបទាំង០២កម្ចី ចំនួន USD 21,141.81 (ម្ភៃមួយពាន់មួយរយសែសិបមួយដុល្លារអាមេរិក និងប៉ែតសិបមួយសេនគត់)។

**២.ការពន្យល់ត្រួសៗអំពីរឿងក្តី៖**

កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ សហចុងចម្លើយ បានចុះកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ ជាមួយនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទៅលើប្រាក់កម្ចីចំនួន ២០,០០០$ (ពីរម៉ឺន)ដុល្លារអាមេរិក ក្នុងអត្រាការប្រាក់ ១.១៥% ក្នុងមួយខែ ហើយក្រោយមកសហចុងចម្លើយបានខ្ចីប្រាក់បន្ថែមចំនួន ២,០០០$ (ពីរពាន់)ដុល្លារអាមេរិក ក្នុងអត្រាការប្រាក់ ១.៤% ក្នុងមួយខែ ក្រោយពេលចុះកិច្ចសន្យារួចមកសហចុងចម្លើយ មិនបានគោរពតាមកិច្ចសន្យាទេ ដោយមានការយឺតយ៉ាវក្នុងការបង់ប្រាក់ជាច្រើនលើក និងបានឈប់ទូទាត់ប្រាក់រហូតដល់បច្ចុប្បន្ន។

**៣.អង្គហេតុដែលអះអាងដោយដើមចោទ៖**

-មេធាវី **ស៊ុំ ភ័ក្ត្រា** តំណាងដោយអាណត្តិឱ្យដើមចោទបានថ្លែងការណ៍ថា៖ ក្នុងនាមខ្ញុំបាទជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ សុំរក្សានូវខ្លឹមសារនៃពាក្យបណ្តឹងចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ និងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ ទុកជាបានការទាំងស្រុង។ កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ សហចុងចម្លើយបានខ្ចីប្រាក់ពី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ចំនួន ២០,០០០$ (ពីរ

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

ម៉ឺន)ដុល្លារអាមេរិក ដោយព្រមទទួលបង់ការប្រាក់ចំនួន ១.១៥% ក្នុងមួយខែ និងព្រមបង់ប្រាក់ពិន័យ ២% ក្នុងមួយខែលើប្រាក់ដើម គិតចាប់ពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ (ក្នុងករណីហួសកាលកំណត់សងចុងក្រោយថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤) ដោយមានកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ ក្រោយមកសហចុងចម្លើយបានសងប្រាក់ដើមចំនួន ៤៨៣.៣៤$ នៅសល់ ១៩,៥១៦.៦៦$ (មួយម៉ឺនប្រាំបួនពាន់ ប្រាំរយដប់ប្រាំមួយ និងហុកសិបប្រាំមួយសេន)ដុល្លារអាមេរិក។ ហើយក្រោយមកសហចុងចម្លើយបានខ្ចីប្រាក់បន្ថែមចំនួន ២,០០០ (ពីរពាន់)ដុល្លារអាមេរិក ដោយព្រមទទួលបង់ការប្រាក់ចំនួន ១.៤% ក្នុងមួយខែលើប្រាក់ដើម និងព្រមបង់ប្រាក់ពិន័យ ២% ក្នុងមួយខែលើប្រាក់ដើម គិតចាប់ពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១ (ក្នុងករណីហួសកាលកំណត់សងចុងក្រោយថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១) ក្រោយមកសហចុងចម្លើយបានសងប្រាក់ដើមចំនួន ៣៧៤.៨៥$ នៅសល់ ១,៦២៥.១៥ (មួយពាន់ប្រាំមួយរយម្ភៃប្រាំ និងដប់ប្រាំសេន)ដុល្លារអាមេរិក។ ក្រោយពេលចុះកិច្ចសន្យារួចមកសហចុងចម្លើយ មិនបានគោរពតាមកិច្ចសន្យាទេ ដោយមានការយឺតយ៉ាវក្នុងការបង់ប្រាក់ជាច្រើនលើក និងបានឈប់ទូទាត់ប្រាក់រហូតដល់បច្ចុប្បន្ន។ ចំពោះការទាមទារសេវាទូទាត់ឥណទានមុនរយៈពេលប្រើប្រាស់អប្បរមាចំនួន ៥៨៥.៤៩$ (ប្រាំរយប៉ែតសិបប្រាំ និងសែសិបប្រាំបួនសេន)ដុល្លារអាមេរិក ដោយយោងតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ និងចំពោះការទាមទារសេវាទូទាត់ឥណទានមុនរយៈពេលប្រើប្រាស់អប្បរមាចំនួន ៤៨.៧៥$ (សែសិប្រាំបី និងចិតសិបប្រាំសេន)ដុល្លារអាមេរិក ដោយយោងតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨។ ការដែលសហចុងចម្លើយមិនបានបង់សងប្រាក់មកឱ្យកូនក្តីខ្ញុំបាទ ធ្វើឱ្យកូនក្តីខ្ញុំបាទខូចផលប្រយោជន៍យ៉ាងធ្ងន់ធ្ងរ ដូច្នេះសុំឱ្យតុលាការសម្រេចតាមការទាមទារដូចមានក្នុងកម្មវត្ថុខាងលើ។

**៤.អង្គហេតុដែលអះអាងដោយចុងចម្លើយ៖**

សហចុងចម្លើយឈ្មោះ ច១ ភេទស្រី អាយុ២៣ឆ្នាំ និងប្តីឈ្មោះ ច២ អាយុ៣៤ឆ្នាំ រួមទាំងម្តាយឈ្មោះ ច៣ អាយុ៥៥ឆ្នាំ និងឪពុកឈ្មោះ ច៤ អាយុ៥៨ឆ្នាំ (អវត្តមាន) តុលាការបានធ្វើការបញ្ជូនដីកាកោះឱ្យចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ត្រឹមត្រូវតាមច្បាប់ហើយ តែភាគីសហចុងចម្លើយនៅតែអវត្តមានដោយគ្មានមូលហេតុ។

**៥.ចំណុចមានវិវាទ៖** គ្មាន។

**៦.ចំណុចគ្មានវិវាទ៖** មាន។

## II.ការពិនិត្យភស្តុតាង

**១.ភស្តុតាងជាឯកសារ៖**

១.១.កិច្ចសន្យាខ្ចីបរិភោគ គណនីកម្ចីលេខ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨។

១.២.កិច្ចសន្យាខ្ចីបរិភោគ គណនីកម្ចីលេខ ។

១.៣.កិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨។

១.៤.កិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨។

១.៥.កាលវិភាគសងប្រាក់ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨។

១.៦.កាលវិភាគសងប្រាក់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៨។

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

# សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា៖

១-តាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ រវាងដើមចោទ និងសហចុងចម្លើយ ឃើញថា សហចុងចម្លើយឈ្មោះ ច១ ឈ្មោះ ច៤ ឈ្មោះ ច៣ ពិតជាបានចុះកិច្ចសន្យាខ្ចីបរិភោគ ដែលមានប្រាក់ដើមជំពាក់សរុបចំនួន ២០,០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ពីដើមចោទ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** តំណាងដោយលោក ក៨ ប្រាកដមែន។ និងតាមកិច្ចសន្យាខ្ចីបរិភោគ គណនីកម្ចីលេខ

រវាងដើមចោទ និងសហចុងចម្លើយ ឃើញថាសហចុងចម្លើយឈ្មោះ ច១ ឈ្មោះ ច២ និងឈ្មោះ ច៤ ពិតជាបានចុះកិច្ចសន្យាខ្ចីបរិភោគ ដែលមានប្រាក់ដើមជំពាក់សរុបចំនួន ២,០០០ (ពីរពាន់) ដុល្លារអាមេរិក ពីដើមចោទ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** តំណាងដោយលោក ក៨ ប្រាកដមែន។

២-ចំពោះការទាមទាររបស់ដើមចោទ សុំឱ្យសហចុងចម្លើយសងប្រាក់ដើម ក្នុងកម្ចីទី១ ចំនួន **១៩,៥១៦.៦៦** (ដប់ប្រាំបួនពាន់ប្រាំរយដប់ប្រាំមួយដុល្លារអាមេរិកគត់ និងហុកសិបប្រាំមួយសេនគត់) ដោយសំអាងលើកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ និងប្រាក់ដើមក្នុងកម្ចីទី២ ចំនួន **១,៦២៥.១៥** (មួយពាន់ប្រាំមួយរយម្ភៃប្រាំដុល្លារអាមេរិក និងដប់ប្រាំសេនគត់) ដោយសំអាងលើកិច្ចសន្យាខ្ចីបរិភោគ គណនីកម្ចីលេខ

មានលក្ខណៈត្រឹមត្រូវតាមភស្តុតាងជាក់ស្តែងដែលបានដាក់មកឱ្យតុលាការពិនិត្យ។ ដូចនេះគប្បីតុលាការសម្រេចតាមការទាមទាររបស់ដើមចោទ។

៣-ចំពោះការទាមទាររបស់ដើមចោទ ឱ្យសហចុងចម្លើយបង់ការប្រាក់ចំនួន **១.១៥%** ក្នុងមួយខែ លើប្រាក់ដើមចំនួន **១៩,៥១៦.៦៦** (មួយម៉ឺនប្រាំបួនពាន់ ប្រាំរយដប់ប្រាំមួយ និងហុកសិបប្រាំមួយ) ដុល្លារអាមេរិក និងបង់ការប្រាក់ចំនួន **១.៤%** ក្នុងមួយខែ លើប្រាក់ដើមចំនួន **១,៦២៥.១៥$** (មួយពាន់ ប្រាំមួយរយម្ភៃប្រាំ និងដប់ប្រាំសេន)ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន។ តុលាការយល់ឃើញថាមិនសមហេតុសមផលទេ ដែលគប្បីតុលាការពិចារណាគិតចាប់ពីថ្ងៃដែលខកខានមិនបានបង់ការប្រាក់ រហូតដល់ថ្ងៃដាក់ពាក្យបណ្តឹង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ ហើយកំណត់យកអត្រាការប្រាក់តាមការព្រមព្រៀងរបស់ភាគី។

៤-ចំពោះការទាមទាររបស់ដើមចោទ ឱ្យសហចុងចម្លើយបង់ប្រាក់ពិន័យ ចំនួន ២% (ពីរភាគរយ) ក្នុងមួយខែ លើប្រាក់ដើម ចំនួន ១៩,៥១៦.៦៦$ គិតចាប់ពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ (ករណីហួសកាលកំណត់សងចុងក្រោយនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤) រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន និងប្រាក់ពិន័យ ២% (ពីរភាគរយ) ក្នុងមួយខែ លើប្រាក់ដើមចំនួន ១,៦៤៣.៦៩$ គិតចាប់ពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១ (ករណីហួសកាលកំណត់សងចុងក្រោយនៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១) រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន។ ឃើញថាការទាមទារមានលក្ខណៈស្មុគស្មាញមិនច្បាស់លាស់ដែលអាចធ្វើឱ្យប៉ះពាល់ផលប្រយោជន៍សហចុងចម្លើយធ្ងន់ធ្ងរ។ ដូចនេះមិនគប្បីតុលាការយកមកពិចារណាទេ។

៥-ចំពោះការទាមទារការប្រាក់ដែលសងយឺតយ៉ាវ ក្នុងកម្ចីទី១ ចំនួន ១,៩៨៧.៥៩$ ជាទឹកប្រាក់គិតពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩ និងទាមទារការប្រាក់ដែលសងយឺតយ៉ាវ ក្នុងកម្ចីទី២ ចំនួន ៧.៥៥ គិតចាប់ពីថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩។ មានលក្ខណៈ

ត្រឹមត្រូវតាមភស្តុតាងជាក់ស្តែងដែលបានដាក់មកឱ្យតុលាការពិនិត្យ ដូចនេះគប្បីតុលាការសម្រេចតាមការទាមទាររបស់ដើមចោទ។

៦-ចំពោះការទាមទារសេវាទូទាត់ឥណទានមុនរយៈពេលប្រើប្រាស់អប្បបរមា ចំនួន ៥៨៥.៤៩$ (ប្រាំរយប៉ែតសិបប្រាំ និងសែសិបប្រាំបួនសេន)ដុល្លារអាមេរិក ដោយយោងតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ និងចំពោះការទាមទារសេវាទូទាត់ឥណទានមុនរយៈពេលប្រើប្រាស់អប្បបរមាចំនួន ៤៨.៧៥$ (សែសិបប្រាំបី និងចិតសិបប្រាំសេន)ដុល្លារអាមេរិក ដោយយោងតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ តុលាការឃើញថា តាមប្រការ ២.២ នៃកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ បានបញ្ជាក់ថា លុះត្រាតែមានការសងប្រាក់មុនកាលកំណត់ទើបមានការយល់ព្រមបង់កម្រៃសេវាអោយអ្នកខ្ចី ស្មើនឹង ៣% នៃប្រាក់ដើម តែសហចុងចម្លើយមិនទាន់មានការស្នើសុំបង់សងប្រាក់មុនកាលកំណត់ទេ ដូច្នេះមិនគប្បីតុលាការយកមកពិចារណាទេ។

៧-ចំពោះការទាមទាររបស់ដើមចោទ បានទាមទារឱ្យសហចុងចម្លើយសងការខាតបង់ពេលវេលា ចំនួន ៦,០០០ (ប្រាំមួយពាន់)ដុល្លារអាមេរិក តុលាការយល់ឃើញថា មានលក្ខណៈមិនសមហេតុផលនោះទេ ព្រោះដើមចោទបានទទួលផលចំណេញពីសហចុងចម្លើយតាមរយៈការប្រាក់ប្រចាំខែ និងប្រាក់ពិន័យលើការយឺតយ៉ាវរួចហើយ។ ដូចនេះគប្បីតុលាការច្រានចោលការទាមទារនេះ។

៨-ចំពោះការទាមទាររបស់ដើមចោទ បានទាមទារសុំសាលក្រមប្រកាសអនុវត្តជាបណ្តោះអាសន្ន ទៅលើចំណុចទី១ លើប្រាក់ដើមសរុបទាំង០២កម្ចី ចំនួន ២១,១៤១.៨១ (ពីរម៉ឺនមួយពាន់ មួយរយសែសិបមួយ និងប៉ែតសិបមួយសេន)ដុល្លារអាមេរិក មានលក្ខណៈសមស្របតាមភស្តុតាង គឺកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ និងកិច្ចសន្យាខ្ចីបរិភោគ គណនីកម្ចីលេខ ដែលជាប្រាក់ដើមជាក់លាក់។ ដូច្នេះគប្បីតុលាការសម្រេចឱ្យអនុវត្តជាបណ្តោះអាសន្ន យោងតាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៩-សហចុងចម្លើយឈ្មោះ ច១ ភេទស្រី អាយុ២៣ឆ្នាំ ជនជាតិខ្មែរ និងប្តីឈ្មោះ ច២ អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ រួមទាំងម្តាយឈ្មោះ ច៣ ភេទស្រី អាយុ៥៥ឆ្នាំ ជនជាតិខ្មែរ និងឪពុកឈ្មោះ ច៤ អាយុ៥៨ឆ្នាំ តុលាការបានធ្វើការបញ្ជូនដីកាកោះឱ្យចូលរួមនីតិវិធីគ្រប់ដំណាក់កាល តែសហចុងចម្លើយនៅតែអវត្តមានដោយគ្មានមូលហេតុ ដូចនេះចាត់ទុកថាសហចុងចម្លើយទទួលស្គាល់សេចក្តីថ្លែងការណ៍ទាមទាររបស់ដើមចោទ យោងតាមមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

១០-ប្រាក់ប្រាប់ក្តីគប្បីសម្រេចតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ ច១ ភេទស្រី អាយុ២៣ឆ្នាំ ជនជាតិខ្មែរ និងប្តីឈ្មោះ ច២ អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ រួមទាំងម្តាយឈ្មោះ ច៣ ភេទស្រី អាយុ៥៥ឆ្នាំ ជនជាតិខ្មែរ និងឪពុកឈ្មោះ ច៤ អាយុ៥៨ឆ្នាំ ត្រូវជាអ្នកខ្ចី រួមគ្នាសងនូវ៖

ក.ប្រាក់ដើមទាំង០២កម្ចី សរុបចំនួន ២១,១៤១.៨១$ (ពីរម៉ឺនមួយពាន់ មួយរយសែសិបមួយ និងប៉ែតសិបមួយសេន)ដុល្លារអាមេរិក។

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

ខ.ការប្រាក់ចំនួន ១.១៥% ក្នុងមួយខែ លើប្រាក់ដើមចំនួន ១៩,៥១៦.៦៦ $ (មួយម៉ឺនប្រាំបួនពាន់ ប្រាំរយដប់ប្រាំមួយ និងហុកសិបប្រាំមួយ) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ រហូតដល់ថ្ងៃដាក់ពាក្យបណ្តឹង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ និងការប្រាក់ចំនួន ១.៤% ក្នុងមួយខែ លើប្រាក់ដើមចំនួន ១,៦២៥.១៥$ (មួយពាន់ ប្រាំមួយរយម្ភៃប្រាំ និងដប់ប្រាំសេន)ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ រហូតដល់ថ្ងៃដាក់ពាក្យបណ្តឹង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩។

គ.ការប្រាក់ដែលសងយឺតយ៉ាវចំនួន ១,៩៨៧.៥៩$ (មួយពាន់ប្រាំបួនរយប៉ែតសិបប្រាំពីរដុល្លារអាមេរិក និងហាសិបប្រាំបួនសេនគត់) ជាទឹកប្រាក់គិតពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩ និងការប្រាក់ដែលសងយឺតយ៉ាវចំនួន ៧.៥៥$ (ប្រាំពីរដុល្លារអាមេរិក និងហាសិបប្រាំសេនគត់) ជាទឹកប្រាក់គិតពីថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩។

ទៅអោយដើមចោទ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលមានអាសយដ្ឋានការិយាល័យកណ្តាលអាគារលេខ រាជធានីភ្នំពេញ ដែលតំណាងដោយលោកមេធាវី ស៊ីវ ភ័ត្រា។

២-ច្រានចោលការទាមទារការខូចខាតពេលវេលា។

៣-ច្រានចោលការទាមទារសេវាទូទាត់ឥណទានមុនរយៈពេលប្រើប្រាស់អប្បរមាចំនួន ៥៨៥.៤៩$ (ប្រាំរយប៉ែតសិបប្រាំដុល្លារអាមេរិក និងសែសិបប្រាំបួនសេនគត់) និងការទាមទារសេវាទូទាត់ឥណទានមុនរយៈពេលប្រើប្រាស់អប្បរមាចំនួន ៤៨.៧៥$ (សែសិបប្រាំបី ដុល្លារអាមេរិក និងចិតសិបប្រាំសេនគត់)។

៤-ច្រានចោលការទាមទារប្រាក់ពិន័យ ២% (ពីរភាគរយ) ក្នុងមួយខែ លើប្រាក់ដើមចំនួន ១៩,៥១៦.៦៦$ គិតចាប់ពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤ (ករណីហួសកាលកំណត់សងចុងក្រោយនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤) រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន និងការទាមទារប្រាក់ពិន័យ ២% (ពីរភាគរយ) ក្នុងមួយខែ លើប្រាក់ដើមចំនួន ១,៦៤៣.៦៩$ គិតចាប់ពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១ (ករណីហួសកាលកំណត់សងចុងក្រោយនៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១) រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន។

៥-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

៦-សាលក្រមនេះប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្នត្រង់ចំណុចទី១.ក នៃសេចក្តីសម្រេចខាងលើ។

សាលក្រមនេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩ ចំពោះមុខតំណាងដោយអាណត្តិដើមចោទ កំបាំងមុខសហចុងចម្លើយ និងប្រកាសជាសាធារណៈនៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០។ ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រម**

ហត្ថលេខា និងត្រា **សំ ម៉ុនពៅ**

---

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃព្រហស្បតិ៍ ៦កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០

**បានឃើញ**

**ចៅក្រម**

**ក្រឡាបញ្ជី**

*កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

**តុលាការរដ្ឋប្បវេណី**

-សាលក្រមរដ្ឋប្បវេណី

លេខ ៨២២ "ជ១"

ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩

-សំណុំរឿងរដ្ឋប្បវេណីលេខ ៣៥០៨

ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅ

ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩

**ចៅក្រមជំនុំជម្រះ**

លោក **ភី ម៉ានេវ៉ា** អនុប្រធាននៃសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

លោកស្រី **ស៊ឹម សុផល្លា** ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ

**<u>ដើមចោទ៖</u>**

**-គ្រឹះស្ថាន** ដ តំណាងដោយលោក តដ ជាប្រធាននាយកប្រតិបត្តិ មានការិយាល័យនៅផ្ទះលេខ

រាជធានីភ្នំពេញ។

ដោយមានលោក **ជា ណារ៉ា**, លោក **ជុំ ម៉ូលីការ** និងកញ្ញា **អ៊ុយ ច័ន្ទធារី** ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ។

**<u>សហចុងចម្លើយ៖</u>**

-ឈ្មោះ ច១ ភេទប្រុស កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ

-ឈ្មោះ ច២ ភេទស្រី កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ

សហចុងចម្លើយមានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ

រាជធានីភ្នំពេញ ។

## <u>អង្គហេតុ និង ចំណុចវិវាទ</u>

**ក.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ ៖**

១-ទាមទារឱ្យសហចុងចម្លើយសងប្រាក់ដើមចំនួន ១៤៩,៥៥៣.៩៧$ (ដប់បួនម៉ឺនប្រាំបួនពាន់ប្រាំរយហាសិបបី ក្បៀសកៅសិបប្រាំពីរ) ដុល្លារអាមេរិក ឱ្យទៅគ្រឹះស្ថាន ដ ដែលតំណាងដោយលោក តដ ។

២-ទាមទារឱ្យសហចុងចម្លើយសងការប្រាក់ចំនួន ១៦% (ដប់ប្រាំមួយភាគរយ) ក្នុងមួយឆ្នាំ និងសងប្រាក់ពិន័យ ឬ ការប្រាក់យឺតយ៉ាវ ២៤% (ម្ភៃបួនភាគរយ) ក្នុងមួយឆ្នាំ គិត ចាប់ពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ ២០១៧ រហូតដល់សងគ្រប់ចំនួន ។

៣-ទាមទារឱ្យចុងចម្លើយបង់សោហ៊ុយសេវាមេធាវី ចំនួន ៨,៥០០$ (ប្រាំបីពាន់ប្រាំរយ) ដុល្លារអាមេរិក និងសោហ៊ុយខូចខាតផលប្រយោជន៍ចំនួន ៥,០០០,០០០៛ (ប្រាំលានរៀល) ។

៤-សុំអនុវត្តជាបណ្តោះអាសន្នលើប្រាក់ដើមចំនួន ១៤៩,៥៥៣.៩៧$ (ដប់បួនម៉ឺនប្រាំបួនពាន់ប្រាំរយហាសិបបីក្បៀសកៅសិបប្រាំពីរ) ដុល្លារអាមេរិក។

៥-បង្គាប់ឱ្យចុងចម្លើយទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី ។

## ខ. ការសង្ខេបអំពីរឿងក្តី ៖

សហចុងចម្លើយបានទំនាក់ទំនងជាមួយតំណាង ដ ដើម្បីស្នើសុំខ្ចីចងការប្រាក់ពីគ្រឹះស្ថាន ដ ។ រួចបង្កើតកិច្ចសន្យានូវខ្ចីប្រាក់ចុះ**ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧** មានចំនួនទឹកប្រាក់ ១៥០,០០០$ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក មានរយៈពេលកំណត់ ១២០ខែ មានអត្រាការប្រាក់ចំនួន ១៦% ក្នុងមួយឆ្នាំ មានប្រាក់ពិន័យ ឬការប្រាក់យឺតយ៉ាវចំនួន ២៤% ក្នុង១ឆ្នាំ ។ ភាគីទាំងពីរក៏បានធ្វើកិច្ចសន្យាបង្កើតហ៊ីប៉ូតែកចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ ដែលភាគីសហចុងចម្លើយ បានព្រមព្រៀងដាក់បញ្ចាំទ្រព្យសម្បត្តិ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលវត្ថុលេខ ៖

ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៦ ដែលចេញដោយប្រធានមន្ទីររៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដី ។ តាមកាលវិភាគបង់ប្រាក់ភាគីសហចុងចម្លើយបានខកខានបង់ប្រាក់ដល់ដើមបណ្តឹង ព្រមទាំងប្រាក់ពិន័យយឺតយ៉ាវផងដែរ ។ ចំពោះចំនួនប្រាក់ដើមដែលភាគីសហចុងចម្លើយនៅជំពាក់ដើមបណ្តឹងគឺនៅសល់ ១៤៩,៥៥៣.៩៧$ (ដប់បួនម៉ឺនប្រាំបួនពាន់ប្រាំរយហាសិបបី ក្បៀសកៅសិបប្រាំពីរ) ដុល្លារអាមេរិក រហូតដល់បច្ចុប្បន្នសហចុមចម្លើយមិនបានបង់ប្រាក់ទាំងដើម ក៏ដូចជាការប្រាក់នោះទេ ហេតុនេះទើបដើមចោទប្តឹងនឹងស្នើសុំតុលាការសម្រេចដូចមានក្នុងពាក្យបណ្តឹង ។

## គ. អង្គហេតុដែលអះអាងដោយដើមចោទ ៖

លោក **ជា ណារ៉ា** ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទលោក តដ ជាប្រធាននាយកប្រតិបត្តិ នៃ**គ្រឹះស្ថាន** ដ បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្លួនសូមរក្សាខ្លឹមសារដូចក្នុងពាក្យបណ្តឹងចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ ទុកនៅដដែល និងសុំឱ្យសហចុងចម្លើយសងនូវ៖

១.សងប្រាក់ដើមចំនួន ១៤៩,៥៥៣.៩៧$ (ដប់បួនម៉ឺនប្រាំបួនពាន់ប្រាំរយហាសិបបី និងកៅសិបប្រាំពីរ) ដុល្លារអាមេរិក មកឱ្យ**គ្រឹះស្ថាន** ដ ដែលតំណាងដោយលោក តដ ។

២.សងការប្រាក់ចំនួន ១៦% (ដប់ប្រាំមួយភាគរយ) ក្នុងមួយឆ្នាំ និងសងប្រាក់ពិន័យ ឬ ការប្រាក់យឺតយ៉ាវ ២៤% (ម្ភៃបួនភាគរយ) ក្នុងមួយឆ្នាំ គិត ចាប់ពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧ រហូតដល់សងគ្រប់ចំនួន ។

៣.បង់សោហ៊ុយមេធាវី ចំនួន ៨,៥០០$ (ប្រាំបីពាន់ប្រាំរយ) ដុល្លារអាមេរិក និងសោហ៊ុយខូចខាតផលប្រយោជន៍ចំនួន ៥,០០០,០០០ ៛ (ប្រាំលានរៀល) ។

*កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ*

៤.សុំអនុវត្តជាបណ្តោះអាសន្នលើប្រាក់ដើមចំនួន ១៤៩,៥៥៣.៩៧$ (ដប់បួនម៉ឺនប្រាំបួនពាន់ប្រាំរយហាសិបបី និងកៅសិបប្រាំពីរ)ដុល្លារអាមេរិក ។

៥.បង្គាប់ឱ្យសហចុងចម្លើយទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី ។

### ឃ. អង្គហេតុដែលអះអាងដោយចុងចម្លើយ ៖

អវត្តមានដោយគ្មានមូលហេតុ ។

## ការពិនិត្យភស្តុតាង

ភស្តុតាងជាឯកសាររបស់ដើមចោទ ៖

- កិច្ចសន្យាខ្ចីប្រាក់ រវាងភាគីខ្ចីប្រាក់ឈ្មោះ លី ច១ ងឈ្មោះ ឌ ច២ ងភាគីឱ្យខ្ចីប្រាក់ គ្រឹះស្ថានមីប៍ ដ ះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ ។
- កិច្ចសន្យាបង្កើតហ៊ុប៉ូតេក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ ។
- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ៤ ៈថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៦ ដែលចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី។
- កាលវិភាគបង់ប្រាក់ ។

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា ៖

១-សហចុងចម្លើយមិនបានចូលបង្ហាញខ្លួននៅគ្រប់នីតិវិធីរបស់តុលាការ ទោះជាតុលាការបានព្យាយាមធ្វើការកោះហៅ និងបញ្ជូនដីកាកោះទៅឱ្យភាគីសហចុងចម្លើយត្រឹមត្រូវ តាមនីតិវិធីច្បាប់ដោយបានបញ្ជូនដល់ទីកន្លែងស្នាក់នៅរបស់សហចុងចម្លើយក៏ដោយហើយតុលាការក៏បានព្យាយាមធ្វើការផ្សព្វផ្សាយជាសាធារណៈអំពីការកោះហៅមកចូលរួមគ្រប់នីតិវិធីតុលាការ តែជាលទ្ធផលគឺចុងចម្លើយមិនបានមកបង្ហាញខ្លួននោះទេ ដូច្នេះតុលាការអាចធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់ដោយអវត្តមានសហចុងចម្លើយ ស្របតាមមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២-តាមមាត្រា៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា តុលាការត្រូវប្រឹងប្រែងដើម្បីរ៉ាប់រង បណ្តឹងរដ្ឋប្បវេណី ឱ្យប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌ និងឆាប់រហ័ស ឯភាគីត្រូវអនុវត្តបណ្តឹងរដ្ឋប្បវេណីដោយសុចរិតនិងស្មោះត្រង់ ។

៣-តាមកិច្ចសន្យាខ្ចីប្រាក់ រវាងភាគីខ្ចីប្រាក់ឈ្មោះ លី ច១ ឈ្មោះ ឌ ច២ ងភាគីឱ្យខ្ចីប្រាក់ **គ្រឹះស្ថានមីប៍** ដ ះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ អាចបញ្ជាក់បានថា ភាគីសហចុងចម្លើយឈ្មោះ លី ច១ និងឈ្មោះ ឌ ច២ ពិតជាបានខ្ចីប្រាក់ពីដើមចោទដែលជា **គ្រឹះស្ថានមី** ដ សបតាមការអះអាងរបស់មេធាវីតំណាងដោយអាណត្តិអោយដើមចោទ ពិតប្រាកដមែន។

-ភាគីដើមចោទ និងភាគីសហចុងចម្លើយបានបង្កើតកិច្ចសន្យាខ្ចីប្រាក់ ខាងលើដោយមានការព្រមព្រៀងគ្នា ក្នុងលក្ខខណ្ឌមួយចំនួនដូចដែលមានចែងនៅក្នុងកិច្ចសន្យាខ្ចីប្រាក់ដូច្នេះ ភាគីនៃកិច្ចសន្យាត្រូវតែអនុវត្តកាតព្វកិច្ចរបស់ខ្លួនឱ្យស្របតាមការព្រមព្រៀងគ្នានៃកិច្ចសន្យានោះ ។ ប៉ុន្តែ ភាគីសហចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនត្រឹមត្រូវនោះទេដោយខកខានមិនបានបង់ប្រាក់តាមការព្រមព្រៀងដូចមានចែងក្នុងកិច្ចសន្យាខ្ចីបរិភោគនោះទេ ។

៤-តាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិអោយដើមចោទ និងពាក្យបណ្តឹងចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ មានភាពស៊ីចង្វាក់គ្នាស្របទៅនឹងឯកសារភស្តុតាងផ្សេងៗដែលដើមចោទបានដាក់ជូនតុលាការ អាចបញ្ជាក់យ៉ាងច្បាស់ថាភាគីដើមចោទ និងសហចុងចម្លើយ ពិតជាបានបង្កើតកិច្ចសន្យាខ្ចីប្រាក់ គូភាគីបានប្រគល់ទទួលប្រាក់កម្ចីរួចរាល់ តែបន្ទាប់ពីបានប្រាក់ហើយភាគីសហចុងចម្លើយបានខកខានក្នុងការបង់ប្រាក់មកឱ្យធនាគារ ហេតុនេះ ភាគីសហចុងចម្លើយបានបំពានកិច្ចសន្យានេះយ៉ាងធ្ងន់ធ្ងរដោយមិនបានបន្តបង់ប្រាក់រំលោះទៅឲ្យដើមចោទតាមការព្រមព្រៀងដូចមានចែងក្នុងកិច្ចសន្យានោះទេ ។

៥-ដើមចោទបានទាមទារឲ្យតុលាការសម្រេចចេញសាលក្រម ដូចខាងក្រោម ៖

៥.១-សងប្រាក់ដើមដែលនៅសល់ ១៤៩,៥៥៣.៥៧$ (ដប់បួនម៉ឺនប្រាំបួនពាន់ប្រាំរយហាសិបបី ក្បៀសកៅសិបប្រាំពីរ) ដុល្លារអាមេរិក និងការប្រាក់ចំនួន ១៦% (ដប់ប្រាំមួយភាគរយ) ក្នុងមួយឆ្នាំ ព្រមទាំងសងប្រាក់ពិន័យ ឬការប្រាក់យឺតយ៉ាវ ២៤% (ម្ភៃបួនភាគរយ) ក្នុងមួយឆ្នាំ គិត ចាប់ពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧ រហូតសងគ្រប់ ។

-ការទាមទារក្នុងចំណុច ៥.១ ខាងលើ ឃើញថាមានភស្តុតាងបញ្ជាក់ច្បាស់លាស់ ដោយសហភាគីចុងចម្លើយមិនបានបំពេញកាតព្វកិច្ចក្នុងការសងប្រាក់ដើម. និងការប្រាក់ ដូចមានចែងក្នុងប្រការ១ ចំណុច១.៣ និងប្រការ២ចំណុច២.១ នៃកិច្ចសន្យាខ្ចីប្រាក់នោះទេ ដូច្នេះគប្បីតុលាការពិនិត្យ និងសម្រេចតាមការទាមទាររបស់ដើមចោទ ។

៥.២-បង់សោហ៊ុយមេធាវី ចំនួន ៨,៥០០$ (ប្រាំបីពាន់ប្រាំរយ) ដុល្លារអាមេរិក និងសោហ៊ុយខូចខាតផលប្រយោជន៍ចំនួន ៥,០០០,០០០ ៛ (ប្រាំលានរៀល) ។

-ការទាមទារនេះពុំមានភស្តុតាងបញ្ជាក់អំពីទំហំនៃការខូចខាតច្បាស់លាស់ដូចការទាមទារនោះទេ ហេតុនេះតុលាការគប្បីពិចារណា ទៅតាមភាពជាក់ស្តែងដែលសមរម្យ ។

៥.៣-សុំអនុវត្តជាបណ្តោះអាសន្នលើប្រាក់ដើមចំនួន ១៤៩,៥៥៣.៩៧$ (ដប់បួនម៉ឺនប្រាំបួនពាន់ប្រាំរយហាសិបបី និងកៅសិបប្រាំពីរ) ដុល្លារអាមេរិក ។

-ចំពោះអង្គហេតុនៃការប្តឹងទាមទារក្នុងរឿងនេះ គឺជាការទាមទារសិទ្ធិលើបំណុល លើប្រាក់ដើមដែលនៅសល់ចំនួន១៤៩,៥៥៣.៩៧$ (ដប់បួនម៉ឺនប្រាំបួនពាន់ប្រាំរយហាសិបបី ក្បៀសកៅសិបប្រាំពីរ) ដុល្លារអាមេរិក ហើយតុលាការយល់ឃើញថាមានភាពចាំបាច់ ដូច្នេះប្រកាសថាអាចអនុវត្តបណ្តោះអាសន្នបានត្រង់ចំណុចទាមទារប្រាក់ដើម ។

៦-ប្រាក់ប្រដាប់ក្តីត្រូវបានអនុវត្តតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## <u>សេចក្តីសម្រេចបញ្ចប់</u>

១.បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ ប១ និងឈ្មោះ ប២ សងប្រាក់ឲ្យទៅដើមចោទ **គ្រឹះស្ថាន** ដ នូវ៖

១.១-ប្រាក់ដើមចំនួន ១៤៩,៥៥៣.៩៧$ (ដប់បួនម៉ឺនប្រាំបួនពាន់ប្រាំរយហាសិបបី ក្បៀសកៅសិបប្រាំពីរ)ដុល្លារអាមេរិក ។

១.២-ការប្រាក់ចំនួន ១៦% (ដប់ប្រាំមួយភាគរយ) ក្នុងមួយឆ្នាំ និងប្រាក់ពិន័យការប្រាក់យឺតយ៉ាវ ២៤% (ម្ភៃបួនភាគរយ)ក្នុងមួយឆ្នាំ គិតចាប់ពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧ រហូតដល់សងគ្រប់ចំនួន ។

១.៣-បង់សោហ៊ុយខូចខាតផលប្រយោជន៍ចំនួន ៤,០០០,០០០(បួនលាន)រៀល ។

*កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ*

២.សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបាន ចំពោះចំណុច ១.១ នៃសេចក្តីសម្រេចនេះ ។

៣.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។

សាលក្រមនេះប្រកាសជាសារធារណៈ នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ។ ក្នុងករណីដែលមានប្តឹងទាស់ ឬប្តឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងក្នុងរយៈពេលដែលច្បាប់កំណត់ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រមនេះ ៕

**ចៅក្រម**

ហត្ថលេខា និងត្រា **គី ម៉ានេវ៉ា**

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃសុក្រ ០៩កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័កព.ស២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

ស៊ឹម សុជវិរ្ណា

**បានឃើញ**

**ចៅក្រម**

គី ម៉ានេវ៉ា

0135

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តប៉ៃលិន

-សាលក្រមរដ្ឋប្បវេណីលេខ ៤០ "ខ"

ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តប៉ៃលិន

បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩ នាវេលាម៉ោងដប់បួន និងសូន្យនាទី រសៀល និងបានប្រកាសសាលក្រម នាថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង ប្រាំបី និងសូន្យនាទី ព្រឹក ដែលមានសមាសភាពដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

លោក លី ម៉េង ជាចៅក្រមសាលាដំបូងខេត្តប៉ៃលិន

**ក្រឡាបញ្ជីសវនាការ**

កញ្ញា ទឹម ស្រីសួន ជាក្រឡាបញ្ជីសាលាដំបូងខេត្តប៉ៃលិន

សញ្ញាណនៃរឿងក្តីលេខ ៤១ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ រវាង៖

**គូភាគី៖**

-ដើមចោទឈ្មោះ ជ អាសយដ្ឋាននៅអាគារលេខ

រាជធានីភ្នំពេញ តំណាងដោយលោក តជ ។

មេធាវីតំណាងដោយអាណត្តិ លោកមេធាវី ហួត សុវណ្ណ អត្តលេខ ១៣៨៣ អាសយដ្ឋានអគារលេខ ៣១៥ វិថី ព្រះអង្គឌួង កែងនឹងមហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

-សហចុងចម្លើយឈ្មោះ ច១ ភេទប្រុស កើតឆ្នាំ ១៩៦០ ជាតិខ្មែរ និងប្រពន្ធឈ្មោះ ច២ កើតឆ្នាំ១៩៥៦ មានទីលំនៅបច្ចុប្បន្ននៅភូមិ

ខេត្តប៉ៃលិន។

## អង្គហេតុនិងចំណុចវិវាទ៖

**១/ការទាមទាររបស់ដើមចោទ ៖**

ដើមចោទទាមទារសុំអោយតុលាការចេញសាលក្រម ដែលមានខ្លឹមសារដូចខាងក្រោម៖

ក.បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ ច១ និងឈ្មោះ ច២ រួមគ្នាសងប្រាក់មកដើមចោទមានប្រាក់ដើមចំនួន ៥១.៦០០ (ហាសិបមួយពាន់ប្រាំមួយរយ)ដុល្លាអាមេរិក។

ខ. បង្គាប់ឲ្យសហចុងចម្លើយសងការប្រាក់គិតចាប់ពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ក្នុងអត្រាការប្រាក់ ១៥,៦០ (ដប់ប្រាំក្បៀសហុកសិប) ភាគរយ ក្នុងមួយឆ្នាំ លើប្រាក់

ដើមចំនួន ៥១.៦០០ ដុល្លាអាមេរិក តាមកិច្ចសន្យាខ្ចីបរិភោគលេខ៖ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ ២០១៨ ។

គ. បង្គាប់ឲ្យសហចុងចម្លើយសងការប្រាក់ពិន័យគិតចាប់ពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទូទាត់ចប់ ក្នុងអត្រាស្មើនឹង ២ (ពីរ) ដងនៃអត្រាការប្រាក់ដូចមានចែងក្នុងឧបសម្ព័ន្ធ កិច្ចសន្យាខ្ចីបរិភោគលេខ៖ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ ។

ឃ. ថ្លៃសេវាកម្មច្បាប់ការខាតបង់ពេលវេលា និងសំណងជម្ងឺចិត្ត ចំនួន ៥.០០០ (ប្រាំពាន់) ដុល្លាអាមេរិក។

ង.ប្រាក់ប្រដាប់ក្តី និងការចំណាយលើនីតិវិធីតុលាការជាបន្ទុករបស់សហចុងចម្លើយ។

ច. សាលក្រមនេះ អាចអនុវត្តជាបណ្តោះអាសន្នមានគ្រង់ចំនុច (១, ២, ៣) ក្នុងចំណុចទាមទារខាងលើ។

<u>២-ការពន្យល់ត្រួសៗអំពីរឿងក្តី៖</u>

កាលពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ សហចុងចម្លើយឈ្មោះ ច១ និងឈ្មោះ ច២ បានចុះកិច្ចសន្យាខ្ចីបរិភោគពីធនាគារ ដ (សាខាប៉ៃលិន) ដែលមានទឹកប្រាក់សរុបចំនួន ៥១.៦០០ (ហាសិបមួយពាន់ប្រាំមួយរយ) ដុល្លាអាមេរិក តាមអត្រាការប្រាក់ ១៥, ៦០ ភាគរយ ក្នុងមួយឆ្នាំ រយៈពេលខ្ចីប្រាក់ ៦០ ខែ ដោយធ្វើការបង់សងរំលស់ការប្រាក់រៀងរាល់ខែ និងសងប្រាក់ដើមរៀងរាល់ ១២ ខែម្តង ចំនួន ៨០០០ (ប្រាំបីពាន់)ដុល្លាអាមេរិក ចាប់ពីថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ ។ របៀបនៃការសងប្រាក់ត្រូវអនុវត្តតាមតារាងកាលវិភាគសងប្រាក់របស់ធនាគារ ដោយការសងត្រូវកាត់យកដោយស្វ័យប្រវត្តិពីគណនីរបស់សហចុងចម្លើយ ដូចក្នុងប្រការ ៦ នៃឧបសម្ព័ន្ធកិច្ចសន្យាខ្ចីបរិភោគលេខ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ ។

ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន សហចុងចម្លើយមិនបានគោរពតាមកាតព្វកិច្ចនៃការបង់ប្រាក់តាមកិច្ចសន្យាឡើយ ដោយបានខកខានបង់ការប្រាក់ និងប្រាក់ដើមមកធនាគារអស់ជាច្រើនខែមកហើយ។

<u>៣. ការអះអាងរបស់គូភាគី៖</u>

**ដើមចោទ ធនាគារ ដ ដោយមានមេធាវី ហួត សុវណ្ណ ជាអ្នកតំណាងដោយអាណត្តិ** បានថ្លែងការណ៍ថា៖ ខ្លួនជាអ្នកតំណាងដោយអាណត្តិអោយធនាគារ ដ ។ ខ្លួន សូមរក្សាការទាមទារក្នុងពាក្យបណ្តឹងលេខ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ ដដែល។ មូលហេតុដែលខ្ញុំបាទទាមទារ ដោយសារខាងចុងចម្លើយបានខកខាតក្នុងបំពេញកាតព្វកិច្ចបង់ប្រាក់មកធនាគារជាច្រើនខែមកហើយ ម្យ៉ាងទៀត ខាងធនាគារក៏បានធ្វើការដាស់តឿនជាច្រើនលើកច្រើនសារផងដែរ ក៏ប៉ុន្តែចុងចម្លើយនៅតែមិនព្រមបង់ប្រាក់មកអោយធនាគារ ហេតុនេះ ទើបភាគីធនាគារ បានដាក់ពាក្យបណ្តឹងទៅលើសហចុងចម្លើយទាំងពីរ ។

ភស្តុតាងបញ្ជាក់ការទាមទារមាន:

-តារាងសង្ខេបបំណុលចុងក្រោយ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ។

-តារាងរំលស់ប្រាក់ដើម និងការប្រាក់ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ។

-កិច្ចសន្យាចង់ការប្រាក់ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៧ ។

-កិច្ចសន្យាខ្ចីបរិភោគលេខ                    ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ ។

-កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ ។

សហចុងចម្លើយឈ្មោះ ច១ និងឈ្មោះ ច២ បានធ្វើសេចក្ដីថ្លែងការណ៍ថា៖ ខ្លួនទាំងពីរទទួល ស្គាល់ទាំងស្រុងការអះអាងរបស់ដើមចោទ ។ នៅពេលនេះ ខ្លួនស្នើសុំអោយដើមចោទ ធ្វើការគណនាទានឡើងវិញ ទាំងប្រាក់ដើម និងការប្រាក់ ដែលនៅសល់ អោយខ្លួនម្តងទៀត ដើម្បីអោយខ្ញុំ បានងាយស្រួលក្នុងបង់ប្រាក់បន្តទៀត។

៤-ចំណុចវិវាទ៖ សហចុងចម្លើយពុំមានលទ្ធភាពសងប្រាក់ដូចការទាមទារ។

៥-ចំណុចគ្មានវិវាទ៖ សហចុងចម្លើយទទួលស្គាល់នូវការអះអាងរបស់ដើមចោទទាំងស្រុង។

## <u>សំអាងហេតុ</u>

តាមលទ្ធផលនៃការសាកសួរសោមីភាគី និងពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុហេតុផលដោយផ្ទាល់ មាត់ ឃើញថា៖

១. ពាក្យបណ្តឹងចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨ របស់ដើមចោទ ដ ដោយ មានលោកមេធាវី ហួត សុវណ្ណ ជាអ្នកតំណាងដោយអាណត្តិ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ស្រប តាមមាត្រា ៧៥នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២. ផ្អែកតាមសេចក្ដីថ្លែងការណ៍របស់ដើមចោទ ដ ដោយមានមេធាវី ហួត សុវណ្ណ ជាអ្នកតំណាងដោយអាណត្តិ និងសហចុងចម្លើយ កិច្ចសន្យាខ្ចីបរិភោគលេខ ចុះថ្ងៃ ទី២៨ ខែមីនា ឆ្នាំ២០១៨, កិច្ចសន្យាចង់ការប្រាក់ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៧ និងកិច្ចសន្យា បង្កើតសិទ្ធិលើការបញ្ចាំ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ បញ្ជាក់ថា ពិតជាមានអត្ថិភាពនៃសិទ្ធិលើបំណុល របស់ដើមចោទធនាគារ ដ ទៅលើសហចុងចម្លើយឈ្មោះ ច១ និងឈ្មោះ ច២ ហើយសហចុងចម្លើយក៏បានទទួលស្គាល់ទាំងស្រុងនៃការអះអាងរបស់ដើមចោទ ប្រាកដមែន។ ហេតុនេះ គប្បីតុលាការទទួលស្គាល់ការទាមទាររបស់ដើមចោទ និងសម្រេចតាមការទាមទារ។

៣. សហចុងចម្លើយឈ្មោះ ច១ និងឈ្មោះ ច២ នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់ បានដឹងដំណឹង ក៏ប៉ុន្តែអវត្តមាន ដោយគ្មានមូលហេតុ។ គប្បីតុលាការសន្មតថា ភាគីនេះ បានទទួលស្គាល់ នូវអត្ថិភាពនៃអង្គហេតុនេះហើយ តុលាការនឹងសម្រេចដោយកំបាំងមុខ យោងតាមបញ្ញត្តិមាត្រា ៩៥, មាត្រា ៩៦ និងមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ចំពោះ ថ្លៃសេវាកម្មច្បាប់ ការខាតបង់ពេលវេលា និងសំណងជំងឺចិត្ត ដែលដើមចោទចោទបានទាមទារចំនួន ៥០០០ (ប្រាំពាន់) ដុល្លាអាមេរិក គប្បី តុលាការនឹងពិចារណា។

៤.តាមប្រការ ៧-៤ នៃកិច្ចសន្យាខ្ចីបរិភោគលេខ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ គូភាគីបានព្រមព្រៀងគ្នាថា ផុតរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីផ្ទេរចូលបំណុលហួសកាលកំណត់ តាមចំនុច ៧-១ ឬ ៧-៣ បើនៅតែមិនទាន់សងបំណុលទាំងនោះទេ ភាគី ក សុខចិត្តអោយភាគី ខ ចាត់ ចែងលក់ដូច ឬគ្រប់គ្រងចលនវត្ថុ ឬអចលនវត្ថុដែលដាក់បញ្ចាំ ដើម្បីកាត់យក ទាំងប្រាក់ដើម ទាំងការប្រាក់ និងប្រាក់ពិន័យ ដោយមិនចាំបាច់បែបបទអ្វីទៀតឡើយ ។ ក្នុងករណីកាត់សងហើយ នៅតែមានសល់ប្រាក់

ភាគី ខ ត្រូវប្រគល់អោយ ភាគី ក វិញ។ ប៉ុន្តែ បើសិនជាមិនទាន់គ្រប់ភាគី ក ត្រូវមានកាតព្វកិច្ចសងបន្ថែមអោយទាល់តែគ្រប់។ គប្បីតុលាការពិនិត្យ និងពិចារណា។

៥. ការប្តឹងសុំអោយតុលាការសម្រេចអនុវត្តសាលក្រមជាបណ្តោះអាសន្ន គ្រង់ចំណុចទី១ ទី២ និងទី៣ របស់ដើមចោទ គឺមានលក្ខណៈសមស្របតាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៦. ចំពោះប្រាក់ប្រដាប់ក្តី ត្រូវអនុវត្តត្រូវអនុវត្តតាមបញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចចុងក្រោយ

១. បង្គាប់អោយសហចុងចម្លើយឈ្មោះ ច១ និងឈ្មោះ ច២ អនុវត្តកាព្វកិច្ចសងជាប្រាក់ទៅឲ្យដើមចោទ ដ ដោយមានមេធាវី ហួត សុវណ្ណ ជាអ្នកតំណាងដោយអាណត្តិនូវៈ

ក. សងប្រាក់មកដើមចោទមានប្រាក់ដើមចំនួន ៥១.៦០០ (ហាសិបមួយពាន់ប្រាំមួយរយ) ដុល្លាអាមេរិក។

ខ. សងការប្រាក់គិតចាប់ពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ក្នុងអត្រាការប្រាក់ ១៥,៦០ (ដប់ប្រាំក្បៀសហុកសិប) ភាគរយ ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ៥១.៦០០ ដុល្លាអាមេរិក តាមកិច្ចសន្យាខ្ចីបរិភោគលេខៈ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ ។

គ. សងការប្រាក់ពិន័យគិតចាប់ពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទូទាត់ចប់ក្នុងអត្រាស្មើនឹង ២ (ពីរ) ដងនៃអត្រាការប្រាក់ដូចមានចែងក្នុងឧបសម្ព័ន្ធ កិច្ចសន្យាខ្ចីបរិភោគលេខៈ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ ។

២. សាលក្រមនេះ អាចអនុវត្តជាបណ្តោះអាសន្នមានគ្រង់ចំនុច ក និង ខ នៃចំណុច១ ។

៣.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

៤.សាលក្រមនេះ ទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២១៩ និងប្រកាសជាសាធារណៈថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩ ចំពោះមុខដើមចោទ និងកំបាំងមុខសហចុងចម្លើយ។ **បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។**

**ចៅក្រម**

**ហត្ថលេខា និងត្រាៈ លី ម៉េង**

---

បានឃើញ

**ចៅក្រម**

លី ម៉េង

បានថតចម្លងត្រឹមត្រូវតាមសាលក្រមដើម

ថ្ងៃព្រហស្បតិ៍ ១០រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

កំណត់សំគាល់៖ សាលក្រមនេះគឺជារឿងក្ដីជាក់ស្ដែង ហើយមិនមែនជាសាលក្រមគម្រូទេ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

**សាលក្រមរដ្ឋប្បវេណី**

លេខ ១៥៣៣ "ញ"

ថ្ងៃសុក្រ ៣កើត ខែមិគសិរ

ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩

សំណុំរឿងរដ្ឋប្បវេណីលេខ ២៧១៩

ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង ៩ និង ០០នាទី ព្រឹក នៅសាលសវនាការទី៣ នៃសាលាដំបូងរាជធានីភ្នំពេញ លើសំណុំរឿងរដ្ឋប្បវេណីលេខ ២៧១៩ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

លោក **លី សុខលេខ** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

លោកស្រី **សាគល ករុណា** ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-ដើមចោទឈ្មោះ ដ ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ មាន ទីលំនៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ ឪពុកដ ម្ដាយឈ្មោះ មាយដ ប្រពន្ធឈ្មោះ បុរពន្ មានកូន ០៣នាក់ ។ (អវត្តមាន)

-ចុងចម្លើយឈ្មោះ ច ភេទប្រុស អាយុ ៣៧ឆ្នាំ ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណ មានទីលំនៅ រាជធានីភ្នំពេញ ។ (អវត្តមាន)

**I.អង្គហេតុ និងចំណុចវិវាទ**

**១-ខ្លឹមសារសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ ៖**

**-ដើមចោទទាមទារឱ្យសាលាដំបូងរាជធានីភ្នំពេញចេញសាលក្រមសម្រេចដូចតទៅ ៖**

-ទាមទារប្រាក់ដើមចំនួន **៧ ៥១១ (ប្រាំពីរពាន់ប្រាំរយដប់មួយ)ដុល្លារអាមេរិក** ពីចុងចម្លើយឈ្មោះ ច ។

-ទាមទារការប្រាក់តាមច្បាប់កំណត់ លើប្រាក់ដើមចំនួន ៧ ៥១១ (ប្រាំពីរពាន់ប្រាំរយដប់មួយ)ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១១៧ រហូតដល់ពេលសងគ្រប់ ពីចុងចម្លើយឈ្មោះ ច ។

-ទាមទារសងប្រាក់ថ្លៃខូចខាត ពេលវេលា ការប៉ះពាល់ សោហ៊ុយចំណាយផ្សេងៗ ចំនួន ១ ០០០ (មួយពាន់)ដុល្លារអាមេរិក ពីចុងចម្លើយឈ្មោះ ច ។

-ទាមទារសាលក្រមប្រកាសអនុវត្តជាបណ្ដោះអាសន្ន ។

-ទាមទារឱ្យចុងចម្លើយទទួលបន្ទុកប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្ដី ។

**២-ខ្លឹមសារសាលក្រមដែលចុងចម្លើយទាមទារឱ្យតុលាការចេញ ៖**

**-ចុងចម្លើយ (អវត្តមាន)**

**២-ការពន្យល់ត្រួសៗអំពីរឿងក្តី**

ដើមចោទឈ្មោះ ជ ប្តឹងទាមទារប្រាក់ពីចុងចម្លើយឈ្មោះ ប នូវប្រាក់ដើមចំនួន៧ ៥១១ (ប្រាំពីរពាន់ប្រាំរយដប់មួយ)ដុល្លារអាមេរិក ដោយផ្អែកទៅលើកិច្ចសន្យាជួលរោងចក្រទឹកកកក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៦

**៣-អង្គហេតុដែលអះអាងដោយដើមចោទ ៖ (អវត្តមាន)**

**៤-អង្គហេតុដែលអះអាងដោយចុងចម្លើយ ៖ (អវត្តមាន)**

**៥-ចំណុចវិវាទ ៖**

## II.ការពិនិត្យភស្តុតាង

**១.ភស្តុតាងជាឯកសាររបស់ដើមចោទ ៖**

-ពាក្យបណ្តឹង ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ ។

-កិច្ចសន្យាជួលរោងចក្រផលិតទឹកកកក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៦ ។

## សំអាងហេតុ

-តាមរយៈដីកាកោះហៅ ឱ្យដើមចោទ និងចុងចម្លើយចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចំនួន ០២លើកមកហើយ ដោយមន្ត្រីទទួលបន្ទុកកិច្ចការ បញ្ជូនបានទៅដល់អាសយដ្ឋានរបស់ដើមចោទ និង ចុងចម្លើយ ដែលមានភ្ជាប់ជូននៅក្នុងពាក្យបណ្តឹង ប៉ុន្តែនៅតែពុំអាចផ្តល់ដំណឹងដល់គូភាគីអំពីការកោះហៅ នេះទេ ឃើញថា ការជូនដំណឹងអំពីការកោះហៅនេះ គឺបានធ្វើអស់ពីលទ្ធភាពក្នុងការបញ្ជូនដីកាហើយ ឃើញថា ដើមចោទ និងចុងចម្លើយ ពុំបានបង្ហាញវត្តមាន តាមការកោះហៅរបស់តុលាការ នៅដំណាក់កាលនីតិវិធីត្រៀម សម្រាប់ការទាញហេតុផលទេ ហេតុនេះ តុលាការអាចបញ្ឈប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយ ភ្លាមៗ ហើយកំណត់នូវកាលបរិច្ឆេទទី១ នៃការទាញហេតុផលដោយផ្ទាល់មាត់បាន ។

-ដើមចោទពុំបានមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការ ត្រូវច្រានចោលការទាមទាររបស់ដើមចោទ ដោយសាលក្រមកំបាំងមុខ ។

(តាមមាត្រា ២០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី )

## សេចក្តីសម្រេចបញ្ចប់

១-ច្រានចោលការទាមទារប្រាក់របស់ដើមចោទឈ្មោះ ជ តាមពាក្យបណ្តឹង ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ២៧១៩ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ ។

២-ឱ្យដើមចោទទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

សាលក្រមនេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ កំបាំងមុខដើមចោទ និងចុងចម្លើយ ប្រកាសជាសាធារណៈនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

*កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ*

ដើមចោទ និងចុងចម្លើយ មានសិទ្ធិប្តឹងទាស់ក្នុងរយៈពេល ០២ (ពីរ)សប្តាហ៍ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ០១(មួយ)ខែ គិតចាប់ពីថ្ងៃបានទទួលសាលក្រមនេះ ។

**ចៅក្រម**

**ហត្ថលេខា និងត្រា : លី សុខលេង**

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃច័ន្ទ ៦កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

**លី សុខលេង**

**ក្រឡាបញ្ជី**

**សាគល ករុណា**

*កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្ដីជាក់ស្ដែង ហើយមិនមែនជាសាលក្រមគម្រូទេ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

********

**សាលាដំបូងរាជធានីភ្នំពេញ**

**********

សាលក្រមរដ្ឋប្បវេណីលេខ: ១៤៩២ "វ"

ចុះថ្ងៃទី ២២-១១-២០១៩

សំណុំរឿងរដ្ឋប្បវេណីលេខ ១១៩៥

ចុះថ្ងៃទី ១២-០៧-២០១៩

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង ៩ និង ០០ នាទីព្រឹក និងប្រកាសសាលក្រមនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដោយមានសមាសភាពដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

- លោកស្រី **ឃី សុខឡូច** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-កញ្ញា **អៀង គឹមណាម** ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

រវាងដើមចោទឈ្មោះ ឥជ ភេទប្រុស ជាអ្នកតំណាងឱ្យធនាគារ ជ សាខាស្រុក ដែលមានទីស្នាក់ការនៅផ្លូវលេខ ខេត្តកណ្ដាល។

-មានលោក **ប៉ា ងួនគា** អត្តលេខ ២៤៩ និងលោក **អ៊ាង សូវសែន** អត្តលេខ ៩៦៣ ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ដែលមានការិយាល័យនៅអគារលេខ រាជធានីភ្នំពេញ។

និងសហចុងចម្លើយមាន៖

១-ឈ្មោះ ច១ ភេទប្រុស កើតថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧០ កាន់អត្តសញ្ញាណប័ណ្ណខ្មែរលេខ ដែលមានទីលំនៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ ឪពុក ច១ ម្ដាយឈ្មោះ ម្ដាយ ច១ ប្រពន្ធឈ្មោះ ប្រពន្ធ ច១ មានកូន០៤នាក់។

២-ឈ្មោះ ច២ ភេទស្រី កើតថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៧៣ កាន់អត្តសញ្ញាណប័ណ្ណខ្មែរលេខ ដែលមានទីលំនៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ ឪពុក ច២ ម្ដាយឈ្មោះ ម្ដាយ ច២ "វ" ប្ដីឈ្មោះ ប្ដី ច២ មានកូន០៤នាក់។

៣-ឈ្មោះ ច៣ ភេទប្រុស កើតថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៩៣ កាន់អត្តសញ្ញាណប័ណ្ណខ្មែរលេខ ដែលមានទីលំនៅ រាជធានីភ្នំពេញ។

៤-ឈ្មោះ ច៤ ភេទប្រុស កើតថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៩៧ កាន់អត្តសញ្ញាណប័ណ្ណខ្មែរលេខ ដែលមានទីលំនៅ រាជធានីភ្នំពេញ។(កូនប្រសារនៅឯខេត្តកំពង់ស្ពឺ ហើយលែងលះជាមួយកូនស្រី)

៥-ឈ្មោះ ច៥ ភេទប្រុស កើតថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៩២ កាន់អត្តសញ្ញាណប័ណ្ណខ្មែរលេខ ដែលមានទីលំនៅភូមិ ។(កូនប្រសារ)

៦-ឈ្មោះ ច៦ ភេទស្រី កើតថ្ងៃទី០២ ខែមិថុនា ឆ្នាំ១៩៩៧ កាន់អត្តសញ្ញាណប័ណ្ណខ្មែរលេខ ដែលមានទីលំនៅភូមិ ។(អ្នកធានា)

**១-សាលក្រមដែលដើមចោទទាមទារ៖**

១-១ បង្គាប់ឱ្យសហចុងចម្លើយសងប្រាក់ដើមចំនួន ១១.៦៤៥,៦៥ $។

១-២ បង្គាប់ឱ្យសហចុងចម្លើយសងមកដើមចោទនូវការប្រាក់ចំនួន ១៤.៤០% ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន ១១.៦៤៥. ៦៥$ គិតពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងគ្រប់ចំនួន ។

១-៣ បង្គាប់ឱ្យសហចុងចម្លើយបង់ប្រាក់ពិន័យចំនួន ២៥%ក្នុងមួយឆ្នាំនៃប្រាក់ដើម គិតពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន។

១-៤ បង្គាប់ឱ្យសហចុងចម្លើយបង់សោហ៊ុយសេវាកម្មច្បាប់ ការខាតបង់ពេលវេលា និងការចំណាយផ្សេងៗលើនីតិវិធីដែលមានសរុបចំនួន ២.០០០ (ពីរពាន់) ដុល្លារអាមេរិក។

១-៥ សុំឱ្យតុលាការប្រកាសសាលក្រមនេះមានអានុភាពអនុវត្តជាបណ្ដោះអាសន្នបាន។

**២-ពន្យល់ត្រួសៗអំពីរឿងក្តី**

កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ឈ្មោះ ច១ ភេទប្រុស ឈ្មោះ ប្រពន្ធ ច១ ភេទស្រី ឈ្មោះ ច៣ ភេទប្រុស ឈ្មោះ ច៤ ភេទប្រុស ឈ្មោះ ច៥ ភេទប្រុស និងឈ្មោះ ច៦ ភេទស្រី បានមកខ្ចីប្រាក់ពីធនាគារ ជ សាខា ស្រុក ចំនួន ១៥.០០០$ សម្រាប់រយៈពេល ៧២ ខែ ដោយមានការប្រាក់ចំនួន ១៤.៤០% ក្នុងមួយឆ្នាំ និងសំណងការខូចខាតចំនួន ២៥ % ក្នុងមួយឆ្នាំ ហើយត្រូវសងរំលស់ការប្រាក់ និងប្រាក់ដើមជារៀងរាល់ខែ។ ក្នុងនោះសហចុងចម្លើយឈ្មោះ ច១ ភេទប្រុស ឈ្មោះ ច២ ភេទស្រី ឈ្មោះ ច៣ ភេទប្រុស ឈ្មោះ ច៤ ភេទប្រុស ឈ្មោះ ច៥ ភេទប្រុស និងឈ្មោះ ច៦ ភេទប្រុស ក៏យល់ព្រមបង្កើតកិច្ចសន្យាហ៊ីប៉ូតែកលើអចលនវត្ថុមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលវត្ថុលេខ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៥ ដែលចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្ដាល ដែលមានទីតាំងស្ថិតនៅ (បច្ចុប្បន្នស្ថិតនៅ រាជធានីភ្នំពេញ) ដើម្បីធានាបំណុលដោយបានចុះបន្ទុកប្រាតិភោគត្រឹមត្រូវ។ ស្រាប់តែនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៨ សហចុងចម្លើយឈ្មោះ ច១ ភេទប្រុស ឈ្មោះ ច២ ភេទស្រី ឈ្មោះ ច៣ ភេទប្រុស ឈ្មោះ ច៤ ភេទប្រុស ឈ្មោះ ច៥ ភេទប្រុស និងឈ្មោះ ច៦ ភេទស្រី មិនបានសងប្រាក់ដើម និងការប្រាក់មកឱ្យធនាគារវិញនោះទេ ទោះបីខាងធនាគារព្យាយាមជូនដំណឹងដើម្បីអនុវត្តកាតព្វកិច្ចយ៉ាងណាក៏ដោយ។

៣- អង្គហេតុដែលអះអាងដោយដើមចោទ:

-ឈ្មោះ ឥជ ជាអ្នកតំណាងឱ្យធនាគារ ជ សាខាស្រុក បានធ្វើសេចក្តី

ថ្លែងការណ៍ថា: ចំពោះពាក្យបណ្តឹងចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ និងសេចក្តីថ្លែងការណ៍ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩របស់លោកមេធាវី អ៊ាង សួរសែន នោះគឺខ្លួននៅតែរក្សាទុកដដែល។ ចំពោះរឿងនេះដើមហេតុដំបូងគឺ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ សហចុងចម្លើយឈ្មោះ ច១ ភេទប្រុស,ឈ្មោះ ច២ ភេទស្រី,ឈ្មោះ ច៣ ភេទប្រុស, ឈ្មោះ ច៤ ភេទប្រុស ,ឈ្មោះ ច៥ ភេទប្រុស និង ច៦ បានមកខ្ចីប្រាក់ពីធនាគារ ដ សាខាស្រុក តាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ដែលមានប្រាក់កម្ចីចំនួន ១៥.000$ (មួយម៉ឺន ប្រាំពាន់ ដុល្លារអាមេរិក) ដោយព្រមព្រៀងគ្នាអនុវត្តសម្រាប់រយៈពេល ៧២(ចិតសិបពីរ)ខែ ជាមួយនឹងអត្រាការប្រាក់ចំនួន ១៤.៤0% ក្នុងមួយឆ្នាំ ហើយត្រូវទូរទាត់សងប្រាក់ដើម និងការប្រាក់ជារៀងរាល់ខែស្មើៗគ្នា។ ចំពោះការខ្ចីប្រាក់នេះគឺបានដាក់វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៥ ដែលចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកណ្តាល តាមកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ និងមានលិខិតធានាដោយតតិយជនឈ្មោះ ច៦ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦។ បន្ទាប់ខ្ចីរួចហើយ សហចុងចម្លើយបានបង់ប្រាក់ដើម និងការប្រាក់ជារៀងរាល់ខែនិងជាធម្មតា ដោយសរុបមានចំនួន ៣.៣៥៤,៣៥$។ ប៉ុន្តែចាប់តាំងពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៨ មក សហចុងចម្លើយមិនបានសងប្រាក់មកខាងធនាគារតាមការកំណត់នូវប្រាក់ដើម និងការប្រាក់នោះទេ។ ចំពោះការមិនបង់ប្រាក់ដើម និងការប្រាក់របស់សហចុងចម្លើយនោះគឺ ខាងធនាគារបានធ្វើលិខិតជូនដំណឹងទៅពួកគាត់ជាច្រើនដងផងដែរ ប៉ុន្តែសហចុងចម្លើយនៅតែមិនមកបង់ប្រាក់ដើម និងការប្រាក់មកខាងធនាគារវិញដដែរ ទើបខាងធនាគារបានដាក់ប្តឹងមកតុលាការតែម្តង។ ដូចនេះដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ខាងធនាគារក្នុងនាមខ្លួនជាអ្នកតំណាងឱ្យខាងធនាគារនៅតែប្តឹងទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារ៖ ១- បង្គាប់ឱ្យសហចុងចម្លើយសងប្រាក់ដើមចំនួន ១១,៦៤៥.៦៥$។ ២-បង្គាប់ឱ្យសហចុងចម្លើយសងមកដើមចោទនូវការប្រាក់ចំនួន ១៤,៤0% ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន ១១.៦៤៥. ៦៥$ គិតពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងគ្រប់ចំនួន ។ ៣-បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ពិន័យចំនួន ២៥%ក្នុងមួយឆ្នាំនៃប្រាក់ដើម គិតពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន។ ៤-បង្គាប់ឱ្យចុងចម្លើយបង់សោហ៊ុយសេវាកម្មច្បាប់ ការខាតបង់ពេលវេលា និងការចំណាយផ្សេងៗលើនីតិវិធីដែលមានសរុបចំនួន ២,000 (ពីរពាន់) ដុល្លារអាមេរិក។ ៥- សុំឱ្យតុលាការប្រកាសសាលក្រមនេះមានអានុភាពអនុវត្តជាបណ្តោះអាសន្នបាន។

**៤- អង្គហេតុដែលអះអាងដោយសហចុងចម្លើយ:**

-ចុងចម្លើយឈ្មោះ ច២ បានធ្វើសេចក្តីថ្លែងការណ៍ថា: ចំពោះការប្តឹងសុំរបស់ធនាគារខាងលើនេះ គឺនាងខ្ញុំទទួលស្គាល់ទាំងអស់ ហើយចំពោះការបង់សងទៅខាងធនាគារវិញគឺនាងខ្ញុំសុខចិត្តទទួលខុសត្រូវតែម្នាក់បានហើយ មិនចាំបាច់ពាក់ព័ន្ធជាមួយអ្នកផ្សេងអីទេ។

-ចុងចម្លើយឈ្មោះ ច១ អវត្តមាននៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដោយហេតុថាសព្វថ្ងៃនេះគឺគាត់ពុំបានរស់នៅជាមួយឈ្មោះ ច២ ទេ។

-សហចុងចម្លើយឈ្មោះ ច១ , ឈ្មោះ ច២ និងឈ្មោះ ច៣ អវត្តមាននៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដោយសារពួកគាត់មិនបានរស់នៅជាមួយនឹងឈ្មោះ ច២ ទេ តែពួកគាត់ក៏បានទទួលដឹងដំណឹងនេះដែរ។

-ចុងចម្លើយឈ្មោះ ច៦ អវត្តមាននៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាត់ ដោយហេតុថា គាត់ចាស់ជរា ហើយគាត់មកពុំកើត តែគាត់ក៏បានទទួលដណឹងនេះដែរដោយសារគាត់រស់នៅជាមួយឈ្មោះ ច២ ។

**៥-ចំណុចវិវាទ: គ្មាន។**

## II.ការពិនិត្យភស្តុតាង

**១. ភស្តុតាងជាឯកសាររបស់ដើមចោទ**

-លិខិតធានា(ការធានាដោយតតិយជន) ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ។(ថតចម្លង)

-កិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦។(ថតចម្លង)

-លិខិតជូនដំណឹងលេខ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨។(ថតចម្លង)

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ របស់ឈ្មោះ ច១ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥។ (ថតចម្លង)

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ របស់ឈ្មោះ ច២ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥។(ថតចម្លង)

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ របស់ឈ្មោះ ច៣ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥។(ថតចម្លង)

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ របស់ឈ្មោះ ច៤ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១២។(ថតចម្លង)

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ របស់ឈ្មោះ ច៥ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៨។(ថតចម្លង)

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ របស់ឈ្មោះ ច៦ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥។(ថតចម្លង)

-លិខិតជូនដំណឹងលើកទី១ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៨ ។(ថតចម្លង)

-លិខិតជូនដំណឹងលើកទី២ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨។(ថតចម្លង)

-លិខិតជូនដំណឹងលើកចុងក្រោយ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨។(ថតចម្លង)

-វិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៥ របស់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកណ្តាល។(ថតចម្លង)

- កាលវិភាគសងប្រាក់នៃកិច្ចសន្យាខ្ចីបរិភោគរវាងធនាគារ ដ និងអ្នកសុំខ្ចីប្រាក់(ថតចម្លង)។

-កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦។ (ថតចម្លង)

*កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ*

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា៖

១-សហចុងចម្លើយឈ្មោះ ច១ ឈ្មោះ ច៣ ឈ្មោះ ច៤ ឈ្មោះ ច៥ និងឈ្មោះ ច៦ មិនបានចូលបង្ហាញខ្លួននៅក្នុងនីតិវិធីរបស់តុលាការទេ តែតុលាការបានធ្វើការកោះហៅ និងបញ្ជូនដីកាកោះទៅឱ្យខាងសហចុងចម្លើយខាងលើត្រឹមត្រូវតាមច្បាប់ដោយបានបញ្ជូនទៅដល់ទីកន្លែងស្នាក់នៅរបស់សហចុងចម្លើយដោយឈ្មោះ ច៣ ជាអ្នកទទួលលើដីកាកោះរបស់តុលាការផងដែរ មានន័យថាតុលាការបានជូនដំណឹងទៅសហចុងចម្លើយ តែសហចុងចម្លើយនៅតែអវត្តមានដោយគ្មានមូលហេតុ ដូច្នេះ តុលាការអាចធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ដោយអវត្តមានសហចុងចម្លើយ ហើយចាត់ទុកថាសហចុងចម្លើយបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទតាមមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២. តាមមាត្រា ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងថា តុលាការត្រូវប្រឹងប្រែងដើម្បីរ៉ាប់រងបណ្តឹងរដ្ឋប្បវេណីឱ្យប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌ និងឆាប់រហ័ស ឯភាគីត្រូវអនុវត្តបណ្តឹងរដ្ឋប្បវេណីដោយសុចរិត និងស្មោះត្រង់។

៣-តាមការអះអាងរបស់ឈ្មោះ ជ ដែលជាអ្នកតំណាងឱ្យភាគីដើមចោទបានបញ្ជាក់ថា កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ឈ្មោះ ច១ ភេទប្រុស ឈ្មោះ ច២ ភេទស្រី ឈ្មោះ ច៣ ភេទប្រុស ឈ្មោះ ច៤ ភេទប្រុស ឈ្មោះ ច៥ ភេទប្រុស និងឈ្មោះ ច៦ បានមកខ្ចីប្រាក់ពីខាងធនាគារ ជ ចំនួន ១៥.០០០$(មួយម៉ឺន ប្រាំពាន់ដុល្លាអាមេរិក) ក្នុងរយៈពេល ៧២(ចិតសិបពីរ)ខែ ជាមួយនឹងអត្រាការប្រាក់ចំនួន ១៤.៤០% ក្នុងមួយឆ្នាំ ដោយបង់ជារៀងរាល់ខែ។ ស្រាប់តែនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៨ សហចុងចម្លើយបានអាក់ខានក្នុងការបង់ប្រាក់ដើម និងការប្រាក់មកខាងធនាគារ ទោះបីខាងធនារគាបានធ្វើលិខិតជូនដំណឹងទៅសហចុងចម្លើយយ៉ាងណាក៏ដោយ ក៏នៅតែមិនសងមកខាងធនាគារដដែរ ដែលការអះអាងនេះ តុលាការអាចជឿបានព្រោះយោងតាម កិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦។

៤-តាមអះអាងរបស់ចុងចម្លើយឈ្មោះ ច២ បានបញ្ជាក់ថា ចំពោះរឿងដែលខាងធនាគារប្តឹងទាមទារប្រាក់ពីខ្លួនដែលជំពាក់ដូចមាននៅក្នុងពាក្យបណ្តឹងចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ នោះខ្លួនទទួលស្គាល់ទាំងអស់។

៥-តាមការអះអាង និងពិនិត្យភស្តុតាងជាឯកសារបញ្ជាក់ថា កិច្ចសន្យាបង្កើតហ៊ីប៉ូតែក របស់ធនាគារ ជ សាខាស្រុក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ លិខិតធានា(ការធានាដោយតតិយជន) ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ឃើញថា សហចុងចម្លើយឈ្មោះ ច១ ភេទប្រុស ឈ្មោះ ច២ ភេទស្រី ឈ្មោះ ច៣ ភេទប្រុស ឈ្មោះ ច៤ ភេទប្រុស ឈ្មោះ ច៥ ភេទប្រុស និងឈ្មោះ ច៦ ភេទស្រី ពិតជាបានខ្ចីប្រាក់ពីធនាគារលើទឹកប្រាក់ចំនួន ១៥.០០០$(មួយម៉ឺន ប្រាំពាន់ ដុល្លារអាមេរិក) ដែលមានអត្រាការប្រាក់ ១៤.៤០% ក្នុងមួយឆ្នាំ ដែលមានរយៈពេល ៧២ ខែ ប្រាកដមែន។

៦-ដើមចោទបានប្តឹងទាមទារប្រាក់ដើមចំនួន ១១.៦៤៥,៦៥$(មួយម៉ឺន មួយពាន់ ប្រាំមួយរយ សែសិបប្រាំដុល្លារអាមេរិក និងហុកសិបប្រាំសេន) និងការប្រាក់ចំនួន ១៤.៤០% ក្នុងមួយឆ្នាំ លើប្រាក់ដើមគិតពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន ដោយហេតុថា ភាគីសហចុងចម្លើយបានបំពានកិច្ចសន្យា និងមិនបានបំពេញកាតព្វកិច្ចនៃការសងប្រាក់ដើម និងការប្រាក់ ដូចមានចែងនៅក្នុង កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ របស់ធនាគារ ជ សាខាស្រុក នោះទេ រហូតមកដល់ពេលនេះ គប្បីតុលាការពិនិត្យ និងសម្រេចតាមការទាមទាររបស់ដើមចោទ។

៧-ធនាគារ ជ សាខាស្រុក និងសហចុងចម្លើយ មានការព្រមព្រៀងគ្នារួចរាល់ ហើយដូចមាននៅក្នុងកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ របស់ធនាគារ ជ សាខាស្រុក ដែលបញ្ជាក់នូវប្រាក់ពិន័យក្នុងអត្រាចំនួន ២៥% ក្នុងមួយឆ្នាំ បន្ថែមលើអត្រាការប្រាក់ ប៉ុន្តែដើមចោទបានប្តឹងទាមទារឱ្យសហចុងចម្លើយសងនូវប្រាក់ពិន័យក្នុងត្រាចំនួន ២៥% ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន ១១.៦៤៥,៦៥$ (មួយម៉ឺន មួយពាន់ ប្រាំមួយរយ សែសិបប្រាំដុល្លារអាមេរិក និងហុកសិបប្រាំសេន) គិតចាប់ពីថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងគ្រប់ចំនួន គប្បីតុលាការសម្រេចតាមការស្នើសុំដោយយោងទៅលើប្រកាសស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិតលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នា២០១១ របស់ទីស្តីការក្រសួងយុត្តិធម៌។

៨.ដើមចោទបានប្តឹងទាមទារថ្លៃសេវាកម្មច្បាប់ ការខាងបង់ពេលវេលា និងការចំណាយផ្សេងៗចំនួន ២.០០០$(ពីរពាន់ដុល្លារអាមេរិក) ការទាមទារនេះ គប្បីតុលាការពុំលើកយកមកពិចារណា និងសម្រេចនោះទេ ដោយហេតុថា ដើមចោទបានប្តឹងទាមទារឱ្យសហចុងចម្លើយសងប្រាក់ពិន័យក្នុងអត្រាចំនួន ២៥%(ម្ភៃប្រាំភាគរយ) នៃប្រាក់ដើមចំនួន ១១.៦៤៥,៦៥$ (មួយម៉ឺន មួយពាន់ ប្រាំមួយរយ សែសិបប្រាំដុល្លារអាមេរិក និងហុកសិបប្រាំសេន) រួចហើយ។

៩-ចំពោះអង្គហេតុនៃការប្តឹងទាមទារនៃរឿងនេះគឺជាការទាមទារសិទ្ធិលើបំណុល ហើយអង្គហេតុបញ្ជាក់លើប្រាក់កម្ចីចំនួន ១១.៦៤៥,៦៥$ (មួយប៊ុន មួយពាន់ ប្រាំមួយរយ សែសិបប្រាំដុល្លារអាមេរិក និងហុកសិបប្រាំសេន) ភាគីសហចុងចម្លើយក៏បានទទួលស្គាល់ផងដែរ គប្បីតុលាការពិចារណាចំពោះការទាមទាររបស់ដើមចោទក្នុងការឱ្យមានការអនុវត្តជាបណ្តោះអាសន្នលើប្រាក់ដើម តាមបញ្ញត្តិមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

១០-ប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ ច១ ភេទប្រុស ឈ្មោះ ច២ ភេទស្រី ឈ្មោះ ច៣ ភេទប្រុស ឈ្មោះ ច៤ ភេទប្រុស ឈ្មោះ ច៥ ភេទប្រុស និងឈ្មោះ ច៦ ភេទស្រី រួមគ្នាសងប្រាក់ទៅឱ្យដើមចោទគឺ ធនាគារ ជ សាខាស្រុក ដែលមានអ្នកតំណាងលោក តជ ដែលមានលោក អ៊ាង សួរសែន និងលោក ប៉ា ងួនគា ជាមេធាវីតំណាងដោយអាណត្តិដូចខាងក្រោម៖

១-១-ប្រាក់ដើមចំនួន ១១.៦៤៥,៦៥$(មួយម៉ឺន មួយពាន់ ប្រាំមួយរយ សែសិបប្រាំដុល្លារអាមេរិក និងហុកសិបប្រាំសេន)។

១-២-ការប្រាក់ចំនួន ១៤.៤០%(ដប់បួន ក្បៀស សែសិប ភាគរយ)ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ១១.៦៤៥,៦៥$(មួយម៉ឺន មួយពាន់ ប្រាំមួយរយ សែសិបប្រាំ ដុល្លារអាមេរិក និងហុកសិបប្រាំសេន) គិតពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន។

១-៣-ការប្រាក់ពិន័យក្នុងអត្រាចំនួន ២៥% (ម្ភៃប្រាំភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន ១១.៦៤៥,៦៥$ (មួយម៉ឺន មួយពាន់ ប្រាំមួយរយ សែសិបប្រាំ ដុល្លារអាមេរិក និងហុកសិបប្រាំសេន) គិតចាប់ពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

២-សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបានចំពោះចំណុចទី ១-១ តែប៉ុណ្ណោះ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ហាចុងចម្លើយឈ្មោះ ច១ ភេទប្រុស ឈ្មោះ ច២ ភេទស្រី ឈ្មោះ ច៣ ភេទប្រុស ឈ្មោះ ច៤ ភេទប្រុស ឈ្មោះ ច៥ ភេទប្រុស និង ឈ្មោះ ច៦ ភេទស្រី ។

សាលក្រមនេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ ចំពោះមុខអ្នកតំណាងឱ្យដើមចោទឈ្មោះ តជ និងចុងចម្លើយឈ្មោះ ច២ កំបាំងមុខសហាចុងចម្លើយឈ្មោះ ច១ ភេទប្រុស ឈ្មោះ ច៣ ភេទប្រុស ឈ្មោះ ច៤ ភេទប្រុស ឈ្មោះ ច៥ ភេទប្រុស និងឈ្មោះ ច៦ ភេទស្រី និងប្រកាសសាលក្រមនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩។

គូភាគីមានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។/

**ចៅក្រម**

ហត្ថលេខា និងត្រា: **ឃី សុខឌួច**

---

**បានឃើញ**

**ចៅក្រម**

**ឃី សុខឌួច**

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ៣កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៩

**ក្រឡាបញ្ជី**

**អៀង គឹមណាម**

# ឧបសម្ព័ន្ធទី៥

## សាលក្រមកំបាំងមុខលើកទី២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
********

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

សាលាដំបូងរាជធានីភ្នំពេញ
**********
សាលក្រមរដ្ឋប្បវេណីលេខៈ "វ"
ចុះថ្ងៃទី
សំណុំរឿងរដ្ឋប្បវេណីលេខៈ
ចុះថ្ងៃទី

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់លើបណ្តឹងទាស់ នៅថ្ងៃទី ខែ ឆ្នាំ លើសំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ ដោយមានសមាសភាពដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

- លោកស្រី ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

- កញ្ញា ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**-រវាងដើមចោទ៖** ខណ្ឌរដ្ឋបាលជលផលរាជធានីភ្នំពេញ ដែលមានអ្នកតំណាងឱ្យឈ្មោះ ភេទស្រី មុខរបរនាយករងខណ្ឌរដ្ឋបាលជលផលភ្នំពេញ មានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ ផ្លូវលេខ បេតេ សង្កាត់បឹងទំពុនទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

-ចុងចម្លើយឈ្មោះ ភេទប្រុស កើតថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៤៩ ជនជាតិខ្មែរ ដែលមានអ្នកតំណាងឱ្យឈ្មោះ ភេទប្រុស អាយុ៥៦ឆ្នាំ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ផ្លូវជាតិលេខ ក្រុមទី៦ ភូមិ៣ សង្កាត់ច្រាំងចម្រេះ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

-លោក ជាមេធាវីតំណាងឱ្យខាងចុងចម្លើយ មានមានអាស័យដ្ឋានផ្ទះលេខ សេ ផ្លូវលេខ សង្កាត់ទូលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**I-អង្គហេតុ និងចំណុចវិវាទ**

**១-សាលក្រមដែលដើមចោទទាមទារ៖** ប្តឹងទាមទារប្រាក់ពីឈ្មោះ ក្នុងការមិនបានបង់ប្រាក់ថ្លៃឈ្នួលចំនួន ៣៨,០០០,០០០៛(សាមសិបប្រាំបីលានរៀលគត់) និងប្រាក់ពិន័យពីការយឺតយ៉ាវចំនួន ១១.៤០០.០០០៛(ដប់មួយលាន និងបួនសែនរៀលគត់) សរុបមានចំនួន ៤៩.៤០០.០០០៛(សែសិបប្រាំបួនលាន និងបួនសែនរៀលគត់)។

**២-ពន្យល់គ្រួសៗអំពីរឿងក្តី៖**

ឈ្មោះ ជាអ្នកទទួលសិទ្ធិកាន់កាប់ឆាយត្រីលេខ៣C រាជធានីភ្នំពេញ សម្រាប់ធ្វើអាជីវកម្មនេសាទក្នុងរដូវឆ្នាំ២០១៥-២០១៦ និង២០១៦-២០១៧ ដោយដេញថ្លៃបានក្នុងតម្លៃ ៣៨.០០០.០០០៛ និងបានកក់ប្រាក់ធានាស្មាគរ៥០% ស្មើនឹង ១៩.០០០.០០០៛។ បន្ទាប់ពីធ្វើអាជីវកម្មបានមួយរដូវក្នុងឆ្នាំ២០១៥-២០១៦ ហើយ ឈ្មោះ

មិនបានបង់ប្រាក់ថ្លៃឈ្នួលចំនួន ៣៨.០០០.០០០៛ នោះទេ ព្រមទាំងត្រូវពិន័យក្នុងការបង់ប្រាក់យឺតយ៉ាវដែលមានចំនួន ១១.៤០០.០០៛ សរុបចំនួន ៤៩.៤០០.០០០៛ ផងដែរ។

៣.**អង្គហេតុដែលអះអាងដោយអ្នកតំណាងឱ្យដើមចោទ៖** ចំពោះពាក្យបណ្តឹង ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៦ និងសាលក្រមរដ្ឋប្បវេណីលេខ "វ" ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ទុកនៅដដែល និងស្នើសុំឱ្យលោកស្រីចៅក្រមសម្រេចច្រានចោលលើបណ្តឹងទាស់របស់ចុងចម្លើយឈ្មោះ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ចោលដោយហេតុថាចុងចម្លើយឈ្មោះ និងអ្នកតំណាងឱ្យចុងចម្លើយឈ្មោះ អវត្តមាន។ ហេតុនេះស្នើសុំឱ្យលោកស្រីចៅក្រមសម្រេចតម្កល់សាលក្រមរដ្ឋប្បវេណីលេខ "វ" ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ទុកនៅដដែល។

៤.**អង្គហេតុដែលអះអាងដោយអ្នកតំណាងឱ្យចុងចម្លើយ៖** ឈ្មោះ ជាអ្នកតំណាងឱ្យចុងចម្លើយអវត្តមាននៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ដោយគ្មានមូលហេតុ ដោយមន្ត្រីបញ្ជូនរបស់សាលាដំបូងរាជធានីភ្នំពេញ បានបញ្ជាក់ថាសាមីខ្លួនបានទទួលដីកាកោះនេះនៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ និងចុងចម្លើយឈ្មោះ ក៏អវត្តមាននៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ដោយគ្មានមូលហេតុ ដោយមន្ត្រីបញ្ជូនរបស់សាលាដំបូងរាជធានីភ្នំពេញបានបញ្ជាក់ថាឈ្មោះ ត្រូវជាប្រពន្ធបានទទួលយកដីកាកោះទុកឱ្យសាមីខ្លួនកាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ រួចហើយ។

## II.**ការពិនិត្យភស្តុតាង**

**១ ភស្តុតាងជាឯកសាររបស់ដើមចោទ**

១.១. ជីវប្រវត្តិសង្ខេបរបស់ឈ្មោះ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥(មួយច្បាប់)។

១.២. លិខិតបញ្ជាក់សមត្ថភាពជំនាញខាងធ្វើអាជីវកម្មនេសាទ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៥(ថតចម្លងមួយច្បាប់)។

១.៣. កិច្ចសន្យាស្តីពីការគោរពតាមបទបញ្ជាក្នុងលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មនេសាទ និងលក្ខខណ្ឌបច្ចេកទេសនានាក្នុងសៀវភៅបន្ទុក ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥(មួយច្បាប់)។

១.៤. កិច្ចសន្យាស្តីពីការបង់ប្រាក់ធានាស្តាពរ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥(មួយច្បាប់)។

១.៥. កិច្ចសន្យាស្តីពីការប្រគល់ប្រាក់ធានាស្តាពរជូនរដ្ឋ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥(មួយច្បាប់)។

១.៦.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះ លេខ ០១០២៧៥០៣០ ចុះថ្ងៃទី០១ ០៤.២០១២។

១.៧. សៀវភៅគ្រួសារ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៧។

១.៨.កំណត់ហេតុស្តីពីការពិភាក្សាកំណត់ថ្លៃឈ្នួលជួលដាយត្រីតាមការព្រមព្រៀងនៅរាជធានីភ្នំពេញ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥(ថតចម្លងមួយច្បាប់)។

១.៩.សេចក្តីសម្រេចស្តីពីការប្រគល់សិទ្ធិកាន់កាប់ដាយត្រីជូនអតិថិជនដែលបានជួលដាយត្រីធ្វើអាជីវកម្មក្នុងអាណត្តិនេសាទ ឆ្នាំ២០១៥-២០១៦ និងឆ្នាំ ២០១៦-២០១៧ ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។(ថតចម្លងមួយច្បាប់)

១.១០. តារាងឧបសម្ព័ន្ធ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥ (មួយច្បាប់)។

១.១១.តារាងទូទាត់ការបង់ប្រាក់ថ្លៃឈ្នួលគន្លងដាយត្រីលេខ ៣C រាជធានីភ្នំពេញ រដូវនេសាទឆ្នាំ ២០១៥-២០១៦ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦(មួយច្បាប់)។

១.១២. តារាងថវិកាថ្លៃឈ្នួលដាយត្រី ប្រាក់ពិន័យ និងប្រាក់ធានាស្ពាតរដាយត្រី រាជធានីភ្នំពេញ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦។(មួយច្បាប់)

១.១៣.សៀវភៅបន្ទុកដាយត្រីលេខ ០៣ សេ រាជធានីភ្នំពេញ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦ (ថតចម្លងមួយច្បាប់)។

១.១៤.ឯកសារឧបសម្ព័ន្ធ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ (ថតចម្លងមួយច្បាប់)

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់លើបណ្តឹងទាស់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា៖

១-តាមពាក្យបណ្តឹងទាស់របស់ចុងចម្លើយឈ្មោះ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩ បានប្តឹងទាស់នឹងសាលក្រមរដ្ឋប្បវេណីលេខ "វ" ចុះថ្ងៃទី ខែ ឆ្នាំ២០ របស់សាលាដំបូងរាជធានីភ្នំពេញ ឃើញថាការប្តឹងទាស់នេះមានមូលហេតុ និងស្ថិតក្នុងអំឡុងពេលប្តឹងទាស់ត្រឹមត្រូវតាមបញ្ញត្តិមាត្រា២០៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី គប្បីតុលាការលើកយកពាក្យបណ្តឹងទាស់នេះមកពិចារណា និងសម្រេចតាមច្បាប់។

២-តាមមាត្រា ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា តុលាការត្រូវប្រឹងប្រែង ដើម្បីធានារ៉ាប់រងបណ្តឹងរដ្ឋប្បវេណីឱ្យប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌ និងឆាប់រហ័ស ឯភាគីត្រូវអនុវត្តបណ្តឹងរដ្ឋប្បវេណីដោយសុចរិត និងស្មោះត្រង់ ដោយយោងតាមមាត្រានេះ តុលាការគប្បីចាត់ការលើសំណុំរឿងដោយពុំអាចរង់ចាំភាគីចុងចម្លើយឈ្មោះ និងឈ្មោះ ដែលជាអ្នកតំណាងឱ្យចុងចម្លើយ ដែលបានទទួលដំណឹងរួចហើយមិនព្រមចូលមកតុលាការបានឡើយ។

៣-តាមសេចក្តីថ្លែងការណ៍របស់ដើមចោទ: ខ្លួននៅតែសុំរក្សាពាក្យបណ្តឹង ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧ និងសាលក្រមរដ្ឋប្បវេណីលេខ "វ" ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ទុកនៅដដែល និងស្នើសុំឱ្យលោកស្រីចៅក្រមសម្រេចច្រានចោលលើបណ្តឹងទាស់របស់ចុងចម្លើយឈ្មោះ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នា២០១៩ ចោលដោយហេតុថា ចុងចម្លើយឈ្មោះ និងអ្នកតំណាងឱ្យចុងចម្លើយឈ្មោះ អវត្តមាន។ ហេតុនេះស្នើសុំឱ្យលោកស្រីចៅក្រមសម្រេចតម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១២១១ "វ" ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ទុកនៅដដែល។

៤-នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ភាគីខាងចុងចម្លើយឈ្មោះ និងឈ្មោះ ដែលជាអ្នកតំណាងឱ្យចុងចម្លើយ នៅតែអវត្តមានដោយគ្មានមូលហេតុ ហើយតុលាការបានធ្វើការបញ្ជូនទៅភាគីចុងចម្លើយដោយបានទទួលដីកាកោះត្រឹមត្រូវ ដូច្នេះតុលាការត្រូវច្រានចោលបណ្តឹងទាស់ដោយសាលក្រមកំបាំងមុខរបស់ចុងចម្លើយម្តងទៀតតាមបញ្ញត្តិមាត្រា ២១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១-ច្រានចោលបណ្តឹងទាស់របស់ឈ្មោះ តំណាងឱ្យឈ្មោះ ចុះថ្ងៃទី ខែ ឆ្នាំ២០១៩។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ "វ" ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

សាលក្រមនេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់លើបណ្តឹងទាស់ នៅថ្ងៃទី ខែ ឆ្នាំ ចំពោះមុខដើមចោទ និងកំបាំងមុខចុងចម្លើយ និងប្រកាសជាសាធារណៈនៅថ្ងៃទី ខែ ឆ្នាំ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ គិតចាប់ពីថ្ងៃបានទទួលលិខិតសាលក្រមនេះ។

**ចៅក្រម**

ហត្ថលេខា និងត្រា:

---

បានឃើញ

**ចៅក្រម**

បានតថចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ ខែមិគសិរ ឆ្នាំឆ្លូវ ត្រីកស័ក ពុទ្ធស័ក ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០២១

ក្រឡាបញ្ជី